01513929

E1/521.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jul-2017, 14:24
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# លើសេចក្តីសន្និដ្ឋានផ្តល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោល

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៥០១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក រ៉ូស្សែល ហាប់គីនស៍
*(Mr. Russell HOPKINS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក ស្រ៊ា រតនៈ

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d’ESTMAEL)*

លោក វីល្លៀម ស្មីត *(Mr.William SMITH)*

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោកស្រី ដូរីន ជិន*(Ms. Doreen CHEN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក ហុង គីមសួន

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោកស្រី ជា លាង | ខ្មែរ |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២/០២ ដែលនឹងធ្វើឡើង នឹងធ្វើសេចក្តីសន្និដ្ឋានដោយសហព្រះរាជអាជ្ញា។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខ ឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧។

មេធាវីការពារក្តីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០២:៥៤]

បានឃើញកំណត់ហេតុពិនិត្យសុខភាព ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈ ឈឺចង្កេះខ្លាំង វិលមុខ និងអស់កម្លាំង និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើបទប្បញ្ញត្តិនេះ និងយោងតាមបទប្បញ្ញាត្តិ -- ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញ១ថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួនជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

[០៩:០៤:០៦]

**លោកស្រី ជា លាង៖**

សូមអរគុណ។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគីទាំងអស់ និងសវនាការទាំងមូល។ នៅក្នុងសវនាការថ្ងៃនេះ យើងបញ្ចប់សវនាការលើកទី២ របស់ នួន ជា និង ខៀវ សំផន។ ខណៈជនជាប់ចោទទាំងពីរនាក់នេះ ត្រូវបានកាត់ទោសរួចហើយ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តចាប់ពីថ្ងៃដំបូងនៃរបបរបស់ខ្លួន នៅពេលដែលមនុស្សរាប់លាននាក់ត្រូវបានបង្ខំឲ្យចាកចេញពីទីប្រជុំជន និងទីក្រុងនានានៃកម្ពុជា ឲ្យទៅកាន់ទីជនបទនោះ ការឈឺចាប់របស់ជនរងគ្រោះនៃរបបខ្មែរក្រហម មិនអាចបញ្ចប់ត្រឹមនេះទេ។ នៅក្នុងសវនាការលើកទី២នេះ យើងស្វែងរកយុត្តិធម៌

សម្រាប់ឧក្រិដ្ឋកម្ម ដែលបានធ្វើឲ្យប្រជាជនកម្ពុជាទូទាំងរបបកម្ពុជាប្រជាធិបតេយ្យបានទទួលរងនូវការឈឺចាប់ ដែលមិនមែនជាផ្នែកនៃសវនាការលើកទី១នោះទេ គឺឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតជាច្រើនទៀត ដែលជនជាប់ចោទទាំងពីរនាក់នេះ ត្រូវបានចោទប្រកាន់បញ្ជូនខ្លួនមកជំនុំជម្រះ។

ការធ្វើឲ្យទៅជាទាសករនៃរបប -- នៃប្រជាជនកម្ពុជា។ នៅតាមបណ្ដាសហករណ៍ និងការដ្ឋាននានា ដែលប្រជាជនកម្ពុជាទាំងនោះ ត្រូវបានដាក់ឲ្យស្ថិតក្រោមការបង្អត់អាហារ ការងារលើសកម្លាំង ជំងឺ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍នៃប្រជាជនចាម និងវៀតណាម អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ និងការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការធ្វើឲ្យមនុស្ស -- ធ្វើមនុស្សឃាតប្រជាពលរដ្ឋខ្មែររាប់សែននាក់នៅតាមបណ្ដាទីកន្លែងអប់រំកែប្រែឡើងវិញ និងមន្ទីរសន្តិសុខនានារបស់កម្ពុជាប្រជាធិបតេយ្យ។

[០៩:០៦:១៩]

ចំពោះអ្នកដែលឆ្ងល់ថា ហេតុអ្វីចាំបាច់មានសវនាការលើកទី២ទៀត បើជនជាប់ចោទត្រូវបានផ្ដន្ទាទោស និងកាត់ឲ្យជាប់ទោសមួយជីវិតរួចហើយ នៅក្នុងសវនាការទី១នោះ? ចម្លើយគឺសាមញ្ញ គឺថាយុត្តិធម៌ត្រូវតែមានសម្រាប់ជនរងគ្រោះពីបណ្ដាមន្ទីរសន្តិសុខនានារបស់ខ្មែរក្រហម សម្រាប់ជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ សម្រាប់ភូមិនានានៃគ្រួសារចាម និងវៀតណាម ដែលត្រូវបានគេសម្លាប់យ៉ាងរង្គាល និងសម្លាប់ -- សម្រាប់ជនរងគ្រោះ ដែលសេរីភាពជាមូលដ្ឋាន និងសេចក្ដីថ្លៃថ្នូររបស់មនុស្សទាំងអស់ត្រូវបានគេដកហូត និងធ្វើឲ្យទៅជាទាសករនៅតាមសហករណ៍ និងការដ្ឋានការងារដោយបង្ខំនានារបស់បក្សកុម្មុយនីស្តកម្ពុជា។

ដំណើរការនៃការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះរាប់លាននាក់ នៃអំពើយង់ឃ្នងរបស់ខ្មែរក្រហម គឺមិនងាយស្រួលឡើយ មិនឆាប់រហ័យ និងក៏មិនដូចការគិតនោះដែរ។ កិច្ចស៊ើបសួរទៅលើឧក្រិដ្ឋកម្មនានានៅក្នុងសំណុំរឿង០០២ បានចាប់ផ្ដើមតាំងពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១០ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានដឹកនាំនូវការស្ដាប់ចម្លើយសាក្សីជាង១.០០០នាក់ និងទទួលបានពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងបណ្ដឹងជនរងគ្រោះជាង៨.០០០ពាក្យបណ្ដឹង។

[០៩:០៧:៥៨]

សវនាការលើកទី១ លើជនជាប់ចោទបានចាប់ផ្ដើមតាំងពីចុងឆ្នាំ២០១១ តែ១ឆ្នាំជាងបន្តិចប៉ុណ្ណោះ ក្រោយការចេញដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត និងត្រូវបានបញ្ចប់ដោយ

អំណះអំណាងបិទកិច្ចពិភាក្សាដេញដោលក្នុងខែតុលា ឆ្នាំ២០១៣។ អំណះអំណាង បើកិច្ចពិភាក្សាដេញដោលនៅក្នុងសវនាការនេះ បានចាប់ផ្ដើមក្នុងខែតុលា ឆ្នាំ២០១៤ ហើយសវនាការស្ដាប់សក្ខីកម្មបានចាប់ផ្ដើមនៅក្នុងខែមករា ឆ្នាំ២០១៥ ហើយបានបញ្ចប់នៅដើមខែមករា ឆ្នាំ២០១៧នេះ។

ជារួមសម្រាប់សវនាការទាំងពីរ អង្គជំនុំជម្រះសាលាដំបូងបានស្ដាប់សក្ខីកម្មពីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ចំនួន២៧៨នាក់ គឺ៩២នាក់នៅក្នុងអំឡុងនៃសវនាការលើកទី១ និង១៨៦នាក់នៅក្នុងសវនាការនេះ។

អង្គជំនុំជម្រះបានទទួលយកជាភស្តុតាងនូវឯកសារជាង១៦.០០០ឯកសារ ដែលរួមមានឯកសារសហកាលពីសម័យកម្ពុជាប្រជាធិបតេយ្យ ដូចជា សារទូរលេខ និងរបាយការណ៍ដែលបានផ្ញើទៅមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា និងតាមបណ្ដាភូមិភាគ និងអង្គការកម្ពុជាប្រជាធិបតេយ្យផ្សេងទៀត កំណត់ហេតុនៃកិច្ចប្រជុំ ការបោះពុម្ពផ្សាយទង់បដិវត្ត និងទស្សនាវដ្ដីយុវជនយុវនារីបដិវត្ត និងកំណត់ហេតុពីគុកស-២១ និងស្រុកត្រាំកក់ បទសម្ភាសន៍ សុន្ទរកថា និងសេចក្ដីថ្លែងការណ៍របស់ នួន ជា និង ខៀវ សំផន និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដែលបានដឹកនាំធ្វើដោយសហចៅក្រមស៊ើបអង្កេត មជ្ឈមណ្ឌលឯកសារ ឌី.ស៊ី.ខែម និងអង្គការដទៃទៀត និងបោះពុម្ពផ្សាយផ្សេងទៀត ដោយអ្នកជំនាញ ដែលបានធ្វើការស្រាវជ្រាវអំពីរបបខ្មែរក្រហម។

[០៩:១០:១៦]

ផ្ទុយពីអ្វីដែលយើងបានស្ដាប់ពីមេធាវីការពារក្ដី ករណីនេះ គឺតែងតែនិយាយថា ភស្តុតាងគឺជាឯកសារដែលនៅសេសសល់ពីសម័យកាលកម្ពុជាប្រជាធិបតេយ្យ និងសក្ខីកម្មពីជនរងគ្រោះ និង អតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលជារួមបានប្រាប់យើងអំពីការពិតដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ ភស្តុតាងនេះហើយ មិនមែនជារឿងនិទានរបស់អ្នកណាម្នាក់នោះទេ តែបញ្ជាក់អំពីឧក្រិដ្ឋកម្មនានា ដែលជនជាប់ចោទត្រូវទទួលខុសត្រូវ គឺភស្តុតាងនេះហើយ ដែលនឹងផ្ដោតលើសេចក្ដីសន្និដ្ឋានរបស់យើងក្នុងពេល២ថ្ងៃខាងមុខនេះ។ ភស្តុតាងនេះហើយ ដែលលោកប្រធាន និងអង្គជំនុំជម្រះបានស្ដាប់សវនាការជាង៥ឆ្នាំមកនេះ គឺជាមូលដ្ឋានសម្រាប់សាលក្រមរបស់លោក លោកស្រីចៅក្រមនៅក្នុងសំណុំរឿងនេះ។ ភស្តុតាងមិនមែនជារឿងនិទានទេ ការពិតមិនមែនជាការឃោសនាទេ។ អង្គហេតុមិនមែនជាទ្រឹស្ដីនៃសមគំនិតឡើយ។

ថ្ងៃនេះ ខ្ញុំនឹងចាប់ផ្ដើមជាមួយនឹងការពិភាក្សាអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ចំពោះ

ឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅតាមបណ្ដាការដ្ឋាន និង សហករណ៍នានា រួមទាំងការធ្វើឱ្យទៅជាទាសករ អំពើអមនុស្សធម៌ និងការធ្វើទុក្ខបុកម្នេញខាងសាសនា ចំពោះពុទ្ធសាសនិកជន។ សហការីរបស់ខ្ញុំនឹងពិភាក្សាផងដែរ អំពីឧក្រិដ្ឋនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើរំលោភសេពសន្ថវៈ។ បន្ទាប់ពីនេះ សហការីអន្តរជាតិរបស់ខ្ញុំនឹងលើកឡើងអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅតាមបណ្ដាមន្ទីរសន្តិសុខនានា អំពីអំពើប្រល័យពូជសាសន៍ និង អំពើបញ្ចោគន្លឹះដទៃទៀត ដូចជា សហឧក្រិដ្ឋកម្មរួមជាដើម។

ការធ្វើឱ្យទៅជាទាសករនៅតាមការដ្ឋាន និងសហករណ៍។ ឧក្រិដ្ឋកម្មមួយដែលបានធ្វើឱ្យប៉ះពាល់ដល់ប្រជាជនកម្ពុជាគ្រប់រូប ដែលបានឆ្លងកាត់របបខ្មែរក្រហម គឺការធ្វើឱ្យទៅជាទាសករនៃប្រជាជននៅតាមសហករណ៍ និងការដ្ឋានការងារ ដែលប្រជាជនត្រូវបានគេដាក់ឱ្យស្ថិតក្រោមលក្ខខណ្ឌការងារដោយបង្ខំយ៉ាងឃោរឃៅ និង ការរស់នៅយ៉ាងអមនុស្សធម៌ តាមរយៈនៃការដកហូតសិទ្ធិសេរីភាពជាមូលដ្ឋានទាំងអស់។

[០៩:១៣:០៨]

ផលប៉ះពាល់នៃឧក្រិដ្ឋកម្មនេះ ទៅលើប្រជាជនកម្ពុជា មិនអាចនិយាយបំផ្លើសបានឡើយ។ សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប ដែលមិនទាន់ធ្លាប់ស្ថិតនៅក្រោមការត្រួតត្រារបស់ខ្មែរក្រហម បានដឹងហើយថា ជីវិតត្រូវបានបញ្ចប់នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ មុខរបរ ឬការងាររបស់អ្នក ផ្ទះសម្បែងរបស់អ្នក សាសនារបស់អ្នក ជីវិតគ្រួសារនិងមិត្តភាពរបស់អ្នក សំខាន់គឺអ្វីៗគ្រប់យ៉ាងសម្រាប់បម្រើឱ្យជីវិតប្រចាំថ្ងៃ ប្រកបដោយអត្ថន័យរបស់ប្រជាជនកម្ពុជា ត្រូវបានដកហូតអស់ដោយរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាផ្នែកមួយនៃការផ្លាស់ប្ដូរសង្គមដ៏ហួសហេតុ និងដាច់ខាតបំផុតនៅក្នុងសម័យទំនើប។ ទោះអ្នកជាអ្វីក៏ដោយ នៅមុនឆ្នាំ១៩៧៥ ជាគ្រូបង្រៀន ជាវេជ្ជបណ្ឌិត ជាព្រះសង្ឃ ជាអ្នកជំនួញ ជាកម្មកររោងចក្រកាត់ដេរ អ្នកត្រូវបានគេបង្ខំឱ្យបោះបង់ចោលជីវិតបែបនោះ ហើយឱ្យចាកចេញពីផ្ទះរបស់អ្នកទៅកាន់សហករណ៍ ឬការដ្ឋានការងាររបស់ខ្មែរក្រហម ក្លាយជាកសិករធ្វើស្រែ ឬជាកម្មករលើកទំនប់ ជីកប្រឡាយ ឬគម្រោងការងារដូច្នេះដទៃទៀត។

ក្នុងករណីនេះ ជនជាប់ចោទត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនានា ដែលជាប់ទាក់ទងទៅនឹងទីតាំងការដ្ឋានចំនួនបួនដែរ គឺការដ្ឋានទំនប់ត្រពាំងថ្ម និងការដ្ឋានទំនប់១មករា ការដ្ឋានការងារព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងសហករណ៍នានាក្នុងស្រុកត្រាំកក់។ ខ្ញុំនឹងពិភាក្សាអំពីទីតាំង

ការដ្ឋាននីមួយៗទាំងនេះ ប៉ុន្តែជាដំបូង ខ្ញុំសូមចាប់ផ្តើមលើកអំពីប្រភេទនៃឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ និងមូលហេតុដែលនាំឲ្យ នួន ជា និង ខៀវ សំផន មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មនៃការធ្វើឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ ទាក់ទងនឹងការដ្ឋាន និងសហករណ៍ទាំងនោះ។

ឧក្រិដ្ឋកម្មនៃការធ្វើឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗ។ តើអ្វីទៅជាឧក្រិដ្ឋកម្មនៃការធ្វើទៅជាទាសករ? វាគឺជាការអនុវត្តអំណាចទៅលើជនណាម្នាក់ ដូចជាកម្មសិទ្ធិ ឧទាហរណ៍ដូចជាការកេងប្រវ័ញ្ច ដើម្បីផលចំណេញខាងសេដ្ឋកិច្ចតាមរយៈពលកម្ម តាមរយៈការត្រួតត្រា ឬការដើរហើរនិងបរិស្ថានជុំវិញ។ តាមរយៈការដកហូតនូវសិទ្ធិសេរីភាពរបស់ពួកគេ និងតាមរយៈការរារាំងមិនឲ្យរត់គេចខ្លួន ពីតំបន់ដែលស្ថិតក្រោមការត្រួតត្រារបស់អ្នកផ្សេងជាដើម។ ពលកម្មការងារដោយបង្ខំ កើតឡើងនៅពេលដែលវាបានបង្ហាញថា ជនរងគ្រោះគ្មានជម្រើសពិតប្រាកដ ថាតើពួកគេគួរ ឬមិនគួរធ្វើការងារនោះ។ ឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀត រួមមាន ភាពខុសគ្នាជាច្រើននៃអំពើ ឬកំហុសអកម្ម ដែលបណ្តាលឲ្យមានការប៉ះពាល់ខាងផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ចំពោះជនរងគ្រោះ ដូចជាការឃុំឃាំងមនុស្សនៅតាមបណ្តាទីតាំងនានាដែលមាន កង្វះខាត់ម្ហូបអាហារ ទឹក លក្ខខណ្ឌវេជ្ជសាស្ត្រ និងអនាម័យ។

[០៩:១៧:០៤]

ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ។ ហេតុអ្វីបានជាជនជាប់ចោទ ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៃការធ្វើឲ្យទៅជាទាសករ នៅតាមសហករណ៍ និងការដ្ឋាននានា និងអំពើអមនុស្សធម៌ ដែលប្រជាជនបានទទួលរងនៅតាមបណ្តាទីតាំងដែលបានចោទប្រកាន់? ទី១ ដូចបានចែងកំណត់យ៉ាងពិស្តារនៅក្នុងសេចក្តីសន្និដ្ឋានបិទកិច្ចស៊ើបសួរដេញដោលរបស់យើង នួន ជា និង ខៀវ សំផន គឺជាផ្នែកនៃក្រុមតូចមួយ នៃមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលជាអ្នកបានសម្រេចថា ប្រជាជនកម្ពុជាទាំងអស់ នឹងត្រូវបានបង្ខំឲ្យលះបង់ជីវិតរបស់ពួកគេ បង្ខំឲ្យចាកចេញពីផ្ទះសម្បែង និងភូមិឋានរបស់ពួកគេ និងបង្ខំឲ្យក្លាយទៅជាកសិករ ឬកម្មករនៅតាមសហករណ៍ ឬការដ្ឋាននានានៃកម្ពុជាប្រជាធិបតេយ្យ។ សេចក្តីសម្រេចទាំងអស់នេះ ត្រូវបានធ្វើឡើងនៅឯសន្និបាតបក្ស និងក្នុងកិច្ចប្រជុំរបស់គណៈកម្មការមជ្ឈិម ដែលបានចូលរួមដោយបុគ្គលជនជាប់ចោទទាំងពីរនាក់ រួមទាំងកិច្ចប្រជុំសំខាន់ៗមិនអាចខ្វះបាន ដែលបានធ្វើនៅភ្នំពេញក្នុងខែមេសា ខែឧសភា ឆ្នាំ១៩៧៥ នៅក្រោយបក្សកុម្មុយនីស្ត

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

កម្ពុជាបានឡើងកាន់អំណាច។

ទាំង ខៀវ សំផន និង ទាំង នួន ជា សុទ្ធតែបានសារភាពថា ប្រជាជនត្រូវបានបង្ខំ ឬបង្គាប់ឲ្យទៅរស់នៅ និងធ្វើការនៅតាមសហករណ៍ និងគ្មានសិទ្ធិសេរីភាពមែន។ សូមបញ្ចាំង*ស្លាយ*ទី១។ នៅក្នុងសាលសវនាការនេះ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ នៅក្នុងការឆ្លើយតបមួយនឹងសំណួរថា៖ "តើប្រជាជនមានជម្រើសក្នុងការចាកចេញពីសហករណ៍ ឬក៏កន្លែងស្នាក់កន្លែងផ្សេងទៀតដែរឬទេ?" នួន ជា ឆ្លើយថា ខ្ញុំសូមដកស្រង់៖ "បើនៅក្នុងសហករណ៍ហើយ អត់មានសេរីភាពចេញទៅឯណាទៀតទេ ត្រូវធ្វើការនៅក្នុងសហករណ៍។" ខៀវ សំផន បានសារភាពក្នុងសៀវភៅទាំងពីររបស់គាត់ថា ការបង្ខិតបង្ខំត្រូវបានប្រើដើម្បីបង្ខំឲ្យប្រជាជនកម្ពុជាទៅក្នុងសហករណ៍ ហើយគាត់បាននិយាយដូចគ្នា ក្នុងពេលធ្វើសម្ភាសដែលមានថតសំឡេងដូចតទៅ។ សូមចាក់ខ្សែអាត់ទី១។

[០៩:១៩:៥២]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ទាល់តែបង្ខំសិន។ ដំបូង ទាល់តែបង្ខំសិន ឲ្យចូលសហករណ៍ ឲ្យធ្វើសហករណ៍តាមស្ម័គ្រចិត្តគ្មានណាចូលទេ។ សូម្បីតែចំពោះសហករណ៍កម្រិតខ្ពស់នេះ សូម្បីតែកសិករក្រក៏មិនទទួលដែរ។ ពីព្រោះ ធ្វើហើយវាអត់បានផលអ្វីខ្លួនឯង គឺទៅបើកអង្ករហូបពីគេដដែល។ ដូច្នេះ ទាល់តែបង្ខំសិន។ អារឿងបង្ខំហ្នឹងរឿងអីហ្នឹង ហ្នឹងហើយដែលវានាំឲ្យមានផលប៉ះពាល់ដល់កសិករស្លូតត្រង់ខ្លះដែរក្នុងរឿងហ្នឹង ប៉ុន្តែត្រូវអីចឹង ជៀសមិនផុតទេ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[០៩:២០:៥២]

ធាតុផ្សំមួយនៃធាតុផ្សំគន្លឹះនានានៃឧក្រិដ្ឋកម្ម នៃការធ្វើឲ្យទៅជាទាសករ គឺការអនុវត្តការត្រួតត្រាលើប្រជាជនដែលជាជនរងគ្រោះ។ ហើយភស្តុតាងដែលមាននៅចំពោះមុខលោកប្រធាន លោកលោកស្រីចៅក្រម បានបង្ហាញឲ្យឃើញថា ការត្រួតត្រាមនុស្សគឺជាមូលហេតុដ៏ចម្បងសម្រាប់ការអនុវត្តគំនិតនៃសហករណ៍របស់មេដឹកបក្សកុម្មុយនីស្តកម្ពុជា។ ទង់បដិវត្តចេញខែធ្នូ ឆ្នាំ១៩៧៥ នៅក្នុងចំណុចដែលនិយាយអំពីការរៀបរាប់ រៀបចំសហករណ៍ និងការលុបបំបាត់ទីផ្សារ និងកម្មសិទ្ធិឯកជននិយាយថា វិធាននេះគឺការ គឺជាផ្លូវបត់មួយសម្រាប់បដិវត្ត ដោយសារប្រជាជនពឹងផ្អែកបដិវត្ត ហើយបដិវត្តក៏គ្រប់គ្រងគេបាន។

ហើយ*ស្លាយ*ទី៤។ ខៀវ សំផន សារភាពនៅក្នុងសៀវភៅរបស់គាត់ថា សហករណ៍គឺចាំបាច់ចំពោះខ្មែរក្រហម ដោយសារគេអនុញ្ញាតឲ្យបក្សកុម្មុយនីស្តកម្ពុជាក្តាប់ស្រូវបាន ក្តាប់សេដ្ឋកិច្ចបាន ក្តាប់មនុស្សបាន។

សូមបន្ត*ស្លាយ*ទី៧។ ហើយនៅក្នុងសុន្ទរកថាមួយធ្វើឡើងដោយ នួន ជា នៅក្នុងខែមករា ឆ្នាំ ១៩៧៧ ដែលនិយាយអំពីផែនការរបស់បក្ស ដើម្បីពង្រឹងនិងពង្រីកសហករណ៍ និងធ្វើឲ្យសហករណ៍ទៅជាកំពែង កំពែងដែកទូទាំងប្រទេស។ ជនជាប់ចោទបានសង្កត់ធ្ងន់អំពីមាគ៌ាយុទ្ធសាស្ត្រសំខាន់ៗដើម្បីក្តាប់ប្រជាជន។

លោកប្រធាន លោក លោកស្រីចៅក្រម ក៏បានស្តាប់ពីសាក្សីជំនាញមួយចំនួនរួចហើយពីសវនាការទាំងពីរ។ សក្ខីកម្មសាក្សីទាំងនោះ គាំទ្រយ៉ាងពេញទំហឹងចំពោះការសន្និដ្ឋានថា គោលនយោបាយនានារបស់បក្សកុម្មុយនីស្តកម្ពុជាមានតម្លៃស្មើទៅនឹងធ្វើឲ្យទៅជាទាសករ។ ហ្វីលីព ស្បូត នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ បានថ្លែងថា ខ្ញុំសូមដកស្រង់៖ "ជារដ្ឋទាសករ ដែលថាប្រជាជនគ្មានមនុស្ស មិនមានការជ្រើសរើស មិនមានលុយចាយអ្វីនោះទេ។ ហើយគេមិនអាចសម្រេចថា ធ្វើការម៉េច ហូបចុកម៉េចទេ គឺគេកំណត់ឲ្យអ្នកទាំងអស់នោះទាំងអស់។"

[០៩:២៣:៤៤]

ក្នុងសៀវភៅរបស់គាត់មានចំណងជើងថា ប៉ុល ពត, ប្រវត្តិសាស្ត្រនៃសុបិនអាក្រក់ លោក ស្បូត បានសរសេរថា៖ "ដូចគ្នានឹងទាសករពិតដែរ ប្រជាជនក្នុងប្រទេសកម្ពុជារបស់ ប៉ុល ពត ត្រូវបានគេដកហូតនូវការគ្រប់គ្រងទាំងអស់លើវាសនាផ្ទាល់ខ្លួនរបស់គេ ធ្វើឲ្យគេមិនអាចសម្រេចលើការហូបចុក កន្លែងដេក កន្លែងរស់នៅ ឬសូម្បីតែអ្នកដែលខ្លួនចង់រៀបការជាមួយ។"

ហើយ ហង់រី ឡូកា បានផ្តល់សក្ខីកម្មដូចខាងក្រោម។ នៅក្នុងសវនាការថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៦៖ "មានការធ្វើឲ្យមនុស្សបាត់ភាពជាមនុស្ស ដោយសារខ្លួនហ្នឹង មិនអាចមានសិទ្ធិអ្វីទាំងអស់ មិនមានម្ចាស់ការអ្វីទាំងអស់ មិនអាចមានសិទ្ធិសម្រេចអ្វីទាំងអស់ ទាក់ទងនឹងប្រពន្ធរបស់ខ្លួន ពីជីវិតមនោសញ្ចេតនារបស់ខ្លួន យើងលែងជាមេគ្រួសារ យើងលែងជាអ្នកគ្រប់គ្រងពេលវេលារបស់យើង គឺថាយើងមិនដឹងថា ថ្ងៃហ្នឹងយើងត្រូវធ្វើអ្វីខ្លះ ដោយមានផែនការរបស់ខ្លួនទេ។ ត្រូវតែគោរពផែនការរបស់មេដឹកនាំខ្មែរក្រហមតាមមូលដ្ឋាន។ គេវាយជួងពីព្រលឹមអ៊ីចឹងទៅ ឲ្យត្រូវងើបក្នុងពេលជាមួយគ្នា ចេញទៅធ្វើការជាមួយគ្នា គឺថាជាទូទៅ អត់បានញុំាបាយពេលមុនចេញទៅធ្វើការនោះ ព្រោះថាដឹងញុំា

លើកទី១គឺនៅថ្ងៃត្រង់។ អ៊ីចឹងយើងអត់មានសិទ្ធិទាំងជ្រើសរើសការងាររបស់ខ្លួនផង។ នេះជាការចាំបាច់សេរីភាពរបស់អ្នកជនបទ ជាការដាក់ប្រជាជនឲ្យក្លាយទៅជាទាសករ។”

[០៩:២៥:៤០]

នៅក្នុងសៀវភៅរបស់ ប៉ុល ពត ប៉ែន ឃៀរនិន បានរៀបរាប់អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដូចតទៅ៖ “គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ គឺដកហូតពីប្រជាកសិករនូវចំណុចបី ក្នុងចំណោមពិសេសដែលត្រូវការ និងសំខាន់បំផុតក្នុងជីវភាពរស់នៅរបស់ប្រជាកសិករ គឺដីធ្លី គ្រួសារ និងសាសនា។ ប្រជាជនកម្ពុជាទាំងមូលបានក្លាយជាពលករគ្មានប្រាក់កំរៃ ដែលមានកាតព្វកិច្ចចូលរួមធ្វើកសិកម្មដោយខានពុំបាន។”

ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មនៃការឲ្យទៅធ្វើជាទាសករ និងអំពើអមនុស្សធម៌ ក៏កើតចេញពីការព្រមព្រៀង និងការរួមចំណែករបស់ពួកគេនៅក្នុងការអនុវត្តគោលនយោបាយមហាលោតផ្លោះ មហាអស្ចារ្យរបស់បក្សកុម្មុយនីស្តកម្ពុជាផងដែរ។ អនុលោមតាមអ្វីដែលប្រជាជនកម្ពុជា ត្រូវបានគេដាក់ទិសដៅការងារឲ្យផលិតស្រូវឲ្យផលិតស្រូវឲ្យបានបីតោនក្នុងមួយហិកតា និងដើម្បីកសាងប្រព័ន្ធធារាសាស្ត្រដ៏ធំទូទាំងប្រទេស។ ក្នុងស្ថានភាពដ៏សែនវក់វីមួយដូចជា ហ្វីលីព ស្សូត បានពិពណ៌នាថា “ក្នុងល្បឿនដ៏លឿនបំផុត”។

នៅក្នុងសេចក្តីថ្លែងមួយដែលបានធ្វើឡើងនៅក្នុងតុលាការនេះ កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ខៀវ សំផន បានរៀបរាប់អំពីផែនការបដិវត្តន៍សង្គមនិយមថា ដំបូងត្រូវយល់ព្រមពីមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក្នុងកិច្ចប្រជុំរបស់គណៈកម្មការមជ្ឈិមក្នុងខែឧសភា ឆ្នាំ១៩៧៥ នៅក្នុងព្រះវិហារព្រះកែវមរកត។ តាមពាក្យសម្តីរបស់ ខៀវ សំផន ថាកម្ពុជាត្រូវកសាងប្រទេសឲ្យលឿន ដើម្បីកុំឲ្យវៀតណាមដេញទាន់គ្រាប់លេប ជាលទ្ធផលដីធ្លីទាំងអស់ វាជាកម្មសិទ្ធិរបស់សហករណ៍។ ហើយការធ្វើទំនប់ ធ្វើប្រឡាយវារហ័ស។

[០៩:២៨:០៥]

*ស្លាយ*ទី១០។ លក្ខខណ្ឌដែល ខៀវ សំផន ជាសមាជិកបម្រុងនៃគណៈកម្មការមជ្ឈិមនៅពេលនោះ និងទើបបានក្លាយជាសមាជិកពេញសិទ្ធិនៅក្នុងខែមករា ឆ្នាំ១៩៧៦ តែគាត់បានពាក់ព័ន្ធនឹងកិច្ចការគណៈកម្មការមជ្ឈិមរួចស្រេចតាំងពីឆ្នាំ១៩៧៥។ ដូចបានទទួលស្គាល់ពីមុនដោយសហជីវិនរបស់គាត់ដែលជាមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា អៀង សារី។ អតីតលេខាភូមិភាគកណ្តាល កែ ពក ដែល

ជាមេដឹកនាំបក្សកុម្មុយនីស្តម្នាក់ ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនេះដែលបានសម្រេច ការកសាងឲ្យលឿនតាមលឿនមហាលោតផ្លោះ មហាអស្ចារ្យ បាននិយាយថា ខ្ញុំសូមដកស្រង់៖ "អង្គប្រជុំឯកភាពគ្នាទាំងស្រុង ហើយ នួន ជា បានសារភាពប្រាប់ ថេត សម្បត្តិ ថាគាត់យល់ស្របតាមផែនការឲ្យទៅជា -- ទៅឲ្យបានលឿនជាងមុន។"

ជនជាប់ចោទបានដឹងយ៉ាងច្បាស់នូវអត្ថន័យនៃសេចក្តីសម្រេច និងគោលនយោបាយទាំងនោះសម្រាប់ប្រជាជនដែលត្រូវបានបង្ខំឲ្យធ្វើការកសាងសង់ប្រព័ន្ធស្រោចស្រពដ៏ច្រើនមហិមា និងដាំដុះបានស្រូវបីតោនក្នុងមួយហិកតា។ ដើម្បីសម្រេចឲ្យបានគោលនយោបាយមហាលោតផ្លោះ មហាអស្ចារ្យរបស់បក្ស ពួកគេបានដឹងថា ខ្លួនបានកំពុងតែជំរុញហួសហេតុពេកចំពោះប្រជាជនដែលមិនមានអាហារគ្រប់គ្រប់ ឬការថែទាំវេជ្ជសាស្ត្រពេញលេញ។ ពួកគេបានដឹងថា ចំនួនការងារច្រើនហួសហេតុនៃគោលនយោបាយមហាលោតផ្លោះ មហាអស្ចារ្យនោះ នឹងនាំមកទុក្ខវេទនាដល់ប្រជាជន និងលក្ខខណ្ឌលំបាក និងអមនុស្សធម៌ដែលក្នុងករណីខ្លះនាំឲ្យមានការស្លាប់បាត់បង់ជីវិត។

[០៩:៣០:១៨]

សារាចររបស់បក្សចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥ បានកត់សម្គាល់ថា ប្រជាជនបានកំពុងធ្វើការខ្លាំងណាស់ មួយថ្ងៃធ្វើការ១៥ម៉ោង ដែលប៉ះពាល់ដល់សុខភាពប្រជាជនយើង។ សារាចរនេះក៏បានកត់សម្គាល់ផងដែរថា នៅតែមានកង្វះខាតអាហារនិងថ្នាំសង្កូវដែលនាំឲ្យឈឺថ្កាត់ ស្គមស្គាំង គ្រុនចាញ់ ខ្វះស្បៀងអាហារ។ ហើយទោះបីជាមានបញ្ហានេះក្តី មេដឹកនាំបក្សបានបន្តបង្កើនល្បឿនគោលយោ-បាយមហាលោតផ្លោះ មហាអស្ចារ្យ។ ពួកគេបានកំណត់ទិន្នផលស្រូវ៣តោនក្នុងមួយហិកតា ដែលបន្ទាប់មកទៀត ពួកគេបានដំឡើងដល់៣តោនកន្លះ។ ពួកគេបានរុញច្រានប្រជាជនដែលទន់ខ្សោយនិងស្រែកឃ្លានឲ្យទៅធ្វើការកាន់តែខ្លាំងថែមទៀត ដើម្បីកសាង -- ដើម្បីសាងសង់ទំនប់ឲ្យកាន់តែច្រើន និងធំជាងមុន។ គម្រោងប្រព័ន្ធស្រោចស្រពសំខាន់ៗ ដូចជា ទំនប់ត្រពាំងថ្ម ទំនប់១មករា ត្រូវបានកំណត់ថា សមរភូមិក្តៅ។ និយាយបែបសាមញ្ញ គឺប្រជាជនត្រូវបានធ្វើឲ្យទទួលរងទុក្ខវេទនាតាមរយៈការបង្ខំឲ្យធ្វើការខ្លាំងហួសហេតុ ដោយមិនមានអាហារ ឬថ្នាំសង្កូវគ្រប់គ្រាន់។

ជនជាប់ចោទទាំងពីររូបបានដើរតួនាទីសកម្មនៅក្នុងរឿងនេះ តាមរយៈសុន្ទរកថា និងវគ្គអប់រំនយោបាយ ដែលនៅក្នុងនោះពួកគេបានណែនាំកម្មាភិបាលនិងកម្មករឲ្យអនុវត្តនិងធ្វើតាមផែនការរបស់បក្ស ដូចមានបង្ហាញពិស្តារនៅក្នុងសារណាសវនាការរបស់សហព្រះរាជអាជ្ញា។ ទាំង នួន ជា ទាំង

ខៀវ សំផន បានបើកវគ្គអប់រំនយោបាយអំពីគោលនយោបាយមហាលោតផ្លោះ មហាអស្ចារ្យ។ ពួកគេបានជួយធានាដល់ការរៀបចំសហករណ៍ ការអនុវត្តគោលនយោបាយពាគោនក្នុងមួយហិកតា និងការសាងសង់ទំនប់ និងជីកប្រឡាយទឹកក្នុងល្បឿនមួយដែលអង្គការរំពឹងទុក។ ពួកគេបានអះអាងថាប្រជាជនដែលស្រេកឃ្លាន អស់កម្លាំង ធ្វើការកាន់តែខ្លាំងទៅ ខ្លាំងទៅទៀត ដើម្បីបំពេញ និងបំពេញលើសផែនការប្រចាំឆ្នាំរបស់បក្ស នៅក្នុងពេលជាមួយគ្នាដែលពួកគេកំណត់របបអាហារលើអ្នកធ្វើការទាំងអស់នោះ។

នៅក្នុងវគ្គអប់រំនយោបាយដែលបានចូលរួមដោយដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន នោះ ទាំង ខៀវ សំផន និងទាំង នួន ជា បានប្រាប់កម្មាភិបាលបក្សថា អ្នកដែលធ្វើពត់ជាឈឺ ត្រូវចាត់ទុកថាជាខ្មាំង ដែលក្បត់បក្ស។ ខៀវ សំផន ក៏បានណែនាំកម្មាភិបាលនានា អំពីរបៀបដែលការងារនិងលក្ខខណ្ឌរស់នៅគាបសង្កត់ អាចត្រូវបានប្រើដើម្បីដកខ្មាំងបក្សចេញ។

*ស្លាយ*១១។ នេះជាអ្វីដែល អែម អឿន បានប្រាប់តុលាការនេះអំពីសុន្ទរកថារបស់ ខៀវ សំផន។ "ត្រង់នេះ ខ្ញុំសូមជម្រាបពីបញ្ហាថា អ្វីយ៉ាងណាៗនោះ ខ្ញុំដឹងតែគោលការណ៍ដែលគាត់ឲ្យធ្វើ គឺខ្ញុំចាំបានថា ដំណើរគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា -- បក្សកុម្មុយនីស្ត ពេលនោះគឺថាដើម្បីវែកមុខវែកមាត់សត្រូវស៊ីរូងផ្ទៃក្នុងរបស់យើង វាទាល់តែយើងបង្កើនការងារឲ្យខ្ពស់ ធ្វើការងារឲ្យច្រើន សម្រាកឲ្យតិច ស៊ីបាយឲ្យតិច ធ្វើការងារឲ្យច្រើន អ៊ីចឹងនោះឯងទើបចេញមុខមាត់អ្នកលាក់ខ្លួនពីក្នុងបក្ស។ នេះគឺពាក្យសម្តីដែលគាត់លើកឡើងក្នុងឱកាសនោះ។ ហើយខ្ញុំឮអ៊ីចឹងក៏ភ័យ ខ្ញុំពិចារណាទៅណាមកណាទាំងមិត្តខ្ញុំ ក៏ទាំងខ្ញុំក៏ដូចគ្នា មានតែភាពភ័យខ្លាចប៉ុណ្ណោះឯង។"

[០៩:៣៤:៥២]

សាក្សីផ្សេងទៀត បានរៀបរាប់ស្រដៀងគ្នាអំពីវគ្គអប់រំនយោបាយ ដែលនៅក្នុងនោះជនជាប់ចោទបានកំណត់ថា ជាខ្មាំងចំពោះអ្នកដែលមិនបានធ្វើការខ្លាំង គ្រប់គ្រាន់ ឬក៏ខ្ជិលធ្វើការ។ ជនជាប់ចោទខ្លួនឯងផ្ទាល់ បានសារភាពអំពីរបៀបដែលផែនការហួសហេតុរបស់បក្សបណ្តាលឲ្យមានការលំបាក និងទុក្ខវេទនាដល់ប្រជាជន។

នៅក្នុងបទសម្ភាសន៍ខែតុលា ឆ្នាំ២០០៧ ជាមួយវិទ្យុសំឡេងសហរដ្ឋអាមេរិក ខៀវ សំផន បានសុំឲ្យពន្យល់ អំពីមូលហេតុបញ្ជូនប្រជាជនទៅកាន់ជនបទ ត្រូវបានបង្ខំធ្វើការជាទម្ងន់ និងមានរហូតដល់ដាច់បាយស្លាប់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*ស្លាយ*១៦។ ជាការឆ្លើយតប គាត់បានកត់សម្គាល់ថា ប្រទេសជាច្រើនដូចជាចិន និងវៀតណាម បានផលិតមិនដល់១តោន ១ហិកតាក្នុងមួយឆ្នាំ។ ដូច្នេះ ប្រជាជនកម្ពុជាត្រូវខំ ហើយខំកាលនោះ គេកំណត់ថា ឲ្យបាន៣តោនក្នុង១ហិកតា។ បន្ទាប់មក គាត់បានរៀបរាប់អំពីគំនិតរបស់គាត់នៅក្នុងរបបនោះចំពោះការលំបាកដែលត្រូវដាក់ទៅលើប្រជាជនកម្ពុជា ដើម្បីសម្រេចឲ្យបាននូវផែនការរបស់បក្ស។ ទាំងនេះ គឺជាសម្ដីរបស់គាត់។ *ស្លាយ*១៩៖ "ខ្ញុំក៏ដឹងថា មិនងាយបានទេ ទាល់តែស្រោចស្រពឲ្យបានពេញស្រែ ហើយស្ទូងស្រែឲ្យបានបីដងឯណោះ។ ហើយបើនិយាយពីទិន្នផលស្រូវ ដោយសារប្រើជីប្រើអីខ្លះ អាចបាន ក្នុងបីបួនឆ្នាំទៀត។ ប៉ុន្តែទាល់តែខំមែនទែនណ៎ា ទាំងឈឺ ទាំងជា ល្មមៗ។"

ហើយ*ស្លាយ*២២។ "ដូច្នេះខំធ្វើការមែនទែន ដើម្បីរត់ឲ្យលឿន ហើយចេះតែទន្ទេញថា រត់ឲ្យលឿន ឲ្យលឿន មុនសង្គ្រាម ក៏ថារត់ឲ្យលឿន មុនសង្គ្រាម បើរំដោះយឺតតែ មួយថ្ងៃពីរ គេរំដោះទាំងពីង ហើយលោកប៉ាន់ខ្លួនឯងទៅ មិនបាច់និយាយទេ អាហ្នឹង។ រស់ក្នុងសភាពអត់អាហារ គិតមើលៗ អ្នករត់បាយ ក៏អត់បាយ អ្នកហូបមិនគ្រប់ ក៏ហូបមិនគ្រប់ ហើយខំរត់ណា គិតមើលៗ ដូច្នេះវាខ្វះបាយ វាខ្វះថ្នាំសង្កូវ វាខ្វះអី ឯខ្ញុំ ខ្លួនខ្ញុំផ្ទាល់ ខ្ញុំគិតគូរខាងថ្នាំសង្កូវ។"

នួន ជា ក៏បានដឹងនៅក្នុងបទសម្ភាសន៍របស់គាត់ថា គោលនយោបាយលោតផ្លោះ មហាអស្ចារ្យ -- មហាលោតផ្លោះ មហាអស្ចារ្យរបស់បក្សកុម្មុយនីស្តកម្ពុជាលឿនពេក និងថា តម្រូវការរបស់បក្សចំពោះប្រជាជនខ្ពស់ពេក។

[០៩:៣៨:១០]

*ស្លាយ*២៨៖ នៅក្នុងបទសម្ភាសន៍នៅក្នុងខែមេសា ឆ្នាំ២០០៧ ជនជាប់ចោទ បានប្រាប់អ្នករាយការណ៍ជនជាតិអាល្លឺម៉ង់ថា "យើងចង់បានច្រើនពេក លឿនពេក។ យើងមានគោលដៅខ្ពស់ពេក តម្រូវការរបស់យើងចំពោះប្រជាជនខ្ពស់ពេក។ យើងគិតថា យើងបានត្រូវតែអនុវត្តប្រទេសឲ្យបានឆាប់។"

*ស្លាយ*៣១៖ ហើយនៅក្នុងបទសម្ភាសន៍របស់គាត់ ជាមួយនឹង ថេត សម្បត្តិ, នួន ជា បានធ្វើការសារភាពស្រដៀងគ្នានេះដែរ ដោយបានថ្លែងថា របបយើងត្រូវបានបំពេញ -- ត្រូវបានបំផ្លាញទំនងដោយហេតុថា យើងដើរលឿនពេក។ ហើយមហាលោតផ្លោះរបស់យើង លឿនពេក។ ទំនងជាយើងដើរលឿងជាងអ្វីប្រជាជនចង់បាន។ ពួកគេចង់ហូបអាហារជាមួយក្រុមគ្រួសារ មិនចង់ហូបអាហារនៅក្នុងសហករណ៍ទេ។"

តើជនជាប់ចោទបានការពារខ្លួនឯងយ៉ាងដូចម្ដេច ប្រឆាំងនឹងការចោទប្រកាន់ទាំងអស់នេះ? ជា

ញ៉ើកញ៉ាប់ ពួកគេបានអះអាងថា ពួកគេមិនបានដឹងអំពីទុក្ខវេទនារបស់ប្រជាជនដែលខ្លួនគ្រប់គ្រងនោះទេ។ ថាពួកគេ មិនបានដឹងថា ប្រជាជនកំពុងអត់អាហារ មិនបានដឹងថា ពួកគេកំពុងត្រូវបានបង្ខំឱ្យធ្វើការដល់ស្លាប់នោះទេ។ ប៉ុន្តែយើងបានបញ្ជាក់នៅក្នុងសវនាការទាំងនេះថា ពួកគេពិតជាបានដឹងអំពីរឿងទាំងអស់នេះ។ ពួកគេបានដឹងគ្រប់យ៉ាង ពួកគេជាអង្គការភ្នែកម្នាស់ ដែលអាចមើលឃើញគ្រប់យ៉ាង។ ទាំង នួន ជា ទាំង ខៀវ សំផន បានធ្វើដំណើរទូទាំងប្រទេស និងជាញ៉ើកញ៉ាប់បានទៅទស្សនាការដ្ឋាន និងសហករណ៍ ដោយរួមទាំងទីតាំងជាក់លាក់ ដែលជាមូលដ្ឋានសម្រាប់ការចោទប្រកាន់ព្រហ្មទណ្ឌនានានៅក្នុងសំណុំរឿងនេះ ដូចដែលខ្ញុំនឹងពិភាក្សានៅពេលបន្តិចទៀតនេះ។

នៅក្នុងសវនាការនេះ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ នួន ជា បានរៀបរាប់អំពីរបៀបនៅក្នុងការធ្វើដំណើរជាមួយ ក្នុងចំណោមការធ្វើដំណើរនានារបស់គាត់ គាត់បានឃើញកម្មករដើរទៅស្រែនៅម៉ោងបួនព្រឹក។ អតីតបរមរតនកោដ្ឋ នរោត្តម សីហនុ បានផ្ដល់បទសម្ភាសន៍ជាច្រើនរៀបរាប់អំពីដំណើររបស់ទ្រង់ទៅកាន់ទីជនបទជាមួយនឹង ខៀវ សំផន ដែលនៅក្នុងនោះ ទ្រង់បានបញ្ជាក់យ៉ាងច្បាស់ថា ការធ្វើឱ្យប្រជាជនកម្ពុជាទៅជាទាសករក្នុងលក្ខខណ្ឌវេទនា អមនុស្សធម៌ មានសភាពជាក់ស្ដែងណាស់។ នៅក្នុងឃ្លីបភាពយន្តនេះ អ្នកនឹងឮពីការរៀបរាប់មួយក្នុងចំណោមរឿងរ៉ាវទាំងនោះ។ សូមចាក់វីដេអូលេខ២។

[០៩:៤១:២០]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*(និយាយជាភាសាបារាំង និងអង់គ្លេស)*

[០៩:៤២:១៨]

លោកប្រធាន លោក លោកស្រីចៅក្រម អ្វីដែលអតីតព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ បានទតឃើញក្នុងដំណើររបស់ទ្រង់នេះ ខៀវ សំផន ក៏អាចមើលឃើញដូចគ្នាដែរ។

សហព្រះរាជអាជ្ញាក៏បានបញ្ជាក់អំពីការរាយការណ៍របស់របបនេះ ដែលមានប្រសិទ្ធភាពក្នុងរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលតាមរយៈនោះ របាយការណ៍ជាលាយលក្ខណ៍អក្សរលម្អិតត្រូវបានបញ្ជូនជាប្រចាំតាមរយៈទូរលេខ ឬនីរសារពីគ្រប់ភូមិភាគ និងស្ថាប័នរបស់កម្ពុជាប្រជាធិប-តេយ្យទៅកាន់មេដឹកនាំមជ្ឈិមបក្សនៅក្នុងក្រុងភ្នំពេញ។ ទោះបីជាការខិតខំប្រឹងប្រែងរបស់មេដឹកនាំខ្មែរក្រហម ដើម្បីបំផ្លាញឯកសារទាំងអស់នោះមុនពេលគេចខ្លួនចេញពីទីក្រុងភ្នំពេញក្នុងខែមករា ឆ្នាំ១៩៧៩

ក៏ដោយ ក៏មួយចំនួននៃកំណត់ត្រាទាំងនោះនៅសេសសល់ ហើយឯកសារទាំងនោះបានបង្ហាញហួសពីវិមតិសង្ស័យថា នួន ជា, ខៀវ សំផន និងមេដឹកនាំបក្ស -- មជ្ឈិមបក្សផ្សេងទៀតនៅក្នុងក្រុងភ្នំពេញបានទទួលដំណឹងតាមរយៈមេដឹកនាំភូមិភាគ អំពីការចាប់ខ្លួន និងការសម្លាប់នានាក្នុងតំបន់របស់ពួកគេ។ ពួកមេដឹកនាំទាំងនោះបានដឹងថា មនុស្សនៅតាមជនបទបានប្រឈមមុខទៅនឹងជំងឺ និងភាពអត់ឃ្លានដោយសារតែការផ្គត់ផ្គង់អាហារមិនគ្រប់គ្រាន់ និងការធ្វើការងារហួសកម្លាំង។

[០៩:៤៤:១៦]

ដូចគ្នានឹងឧទាហរណ៍មួយចំនួននោះដែរ នៅថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៧៦ លេខាភូមិភាគកណ្ដាលឈ្មោះ កែ ពក បានរាយការណ៍ថា ប្រជាជននៅភូមិភាគឧត្តរទាំងមូលមានជំងឺគ្រុនក្ដៅ ចុក -- ចុករាកជាច្រើន ដោយសារធ្វើការក្ដៅពេក ហើយគាត់បានស្នើឱ្យបន្ថយពេលវេលាធ្វើការ។ ដូចគ្នាទៅនឹងរបាយការណ៍ផ្សេងៗទៀតផ្ញើទៅកាន់មជ្ឈិម របាយការណ៍របស់ កែ ពក ត្រូវបានចម្លងជូន នួន ជា មន្ទីរ៨៧០ និងសំណុំបណ្ណសារឯកសាររបស់មជ្ឈិម។ ជាអកុសល វាបង្ហាញយ៉ាងច្បាស់តាមរយៈសក្ខីកម្មរបស់អ្នកដែលបានធ្វើការនៅទំនប់១មករា ឆ្នាំ១៩៧៧ ថាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងភ្នំពេញមិនខ្វល់ខ្វាយចំពោះសំណើរបស់ កែ ពក ដែលថា ម៉ោងធ្វើការត្រូវកាត់បន្ថយនោះទេ។

*ស្លាយ*៣៤ ក្នុងខែឧសភា ឆ្នាំ១៩៧៧ ភូមិភាគពាយ័ព្យបានរាយការណ៍ទៅកាន់អង្គការថា មានការខ្វះខាតនៅក្នុងតំបន់ជាច្រើន និង ថាប្រជាជនមូលដ្ឋានភាគច្រើននៅក្នុងភូមិភាគនោះ ទទួលបានតែបបររាវប៉ុណ្ណោះ។ នៅក្នុងខែមិថុនា ក្នុងឆ្នាំដដែលនោះ ភូមិភាគនិរតីបានរាយការណ៍ថា ស្រុកខ្លះ និងឃុំមួយចំនួនត្រូវបានជួបប្រទះការខ្វះខាត និងថាប្រជាជននៅក្នុងខេត្តកំពត កំពង់ស្ពឺ និងតាកែវ កើតជំងឺអាសន្នរោគ និងខ្លះទៀតបានស្លាប់។

*ស្លាយ*៣៦ នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៨ លេខាភូមិភាគឧត្តរឈ្មោះ កង ចាប ហៅ សែ បានរាយការណ៍ទៅកាន់គណៈ៨៧០ ថាឆ្នាំនេះ ជាទូទៅក្នុងតំបន់ព្រះវិហារកន្លែងភាគច្រើនត្រូវអត់បាយ។ និងនៅក្នុងខែឧសភា ឆ្នាំ១៩៧៨ នៅក្នុងសេចក្ដីរាយការណ៍មួយពីលេខាភូមិភាគពាយ័ព្យ រស់ ញឹម ទៅកាន់អង្គការ៨៧០ ញឹម បានរាយការណ៍ថា ការផ្គត់ផ្គង់ស្រូវទៅកាន់តំបន់៥ អស់ហើយ ហើយតំបន់១ និងតំបន់៤ នឹងអស់នៅខែក្រោយ។

ជនជាប់ចោទបានទទួលរបាយការណ៍ទាំងអស់នេះ មិនត្រឹមតែតាមរយៈការសរសេរប៉ុណ្ណោះទេ តែថែមទាំងការប្រជុំជាប្រចាំដែលបានធ្វើឡើងនៅមន្ទីរថ្នាក់ដឹកនាំមជ្ឈិមបក្ស ក-១ ក្នុងក្រុងភ្នំពេញផង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែរ ដែលនៅទីនោះមេដឹកនាំភូមិភាគ និង តំបន់បានមករាយការណ៍អំពីតំបន់របស់ខ្លួន និង ដើម្បីទទួលសេចក្ដីណែនាំពីមជ្ឈិម។

លោកប្រធាន លោក លោកស្រីចៅក្រម បានស្ដាប់សក្ខីកម្មអំពីការប្រជុំទាំងនេះ ពីកម្មាភិបាលដែលបានធ្វើការនៅមន្ទីរ ក-១ អឿន តាន ដែលជាប្រធានកងការពារខាងក្នុងនៅ ក-១, សួត្រ ទៀង ដែលជាអង្គរក្ស និង ជានីរសារផ្ទាល់របស់ នួន ជា។ អ្នកយាម ក-១ ឈ្មោះ ស វី និង សេង លីថេង ដែលជាអ្នកយាមនៅ ក-១ និងជាក្មួយប្រុសរបស់ ប៉ុល ពត។ សាក្សីទាំងអស់នេះ បានបញ្ជាក់ថា មេដឹកនាំភូមិភាគ និងតំបន់ បានចូលរួមប្រជុំជាប្រចាំនៅភ្នំពេញ ជាមួយនឹង ប៉ុល ពត, នួន ជា, ខៀវ សំផន និងកម្មាភិបាលមជ្ឈិមផ្សេងទៀត។ ហើយលោក លោកស្រីចៅក្រម បានស្ដាប់សក្ខីកម្មពីមេដឹកនាំភូមិភាគ ឬតំបន់ម្នាក់ ដែលរួចជីវិត ដែលបានមកចូលរួមនៅក្នុងការប្រជុំបែបនេះ គឺ សៅ សារុន ដែលជាអតីតលេខាតំបន់ស្វយ័ត១០៥ ដែលបានរៀបរាប់អំពីការធ្វើដំណើររបស់គាត់ទៅកាន់ទីក្រុងភ្នំពេញដើម្បីចូលរួមការប្រជុំ ដែលក្នុងនោះ គាត់បានជួប និង បានរាយការណ៍ទៅកាន់ ប៉ុល ពត, នួន ជា, ខៀវ សំផន និង សុន សេន។

[០៩:៤៨:៥៩]

ជាងនេះទៀត សូម្បីតែក្នុងចំណោមកំណត់ហេតុមួយចំនួនតូច ដែលនៅសេសសល់នៃការប្រជុំគណៈអចិន្ត្រៃយ៍ពីពាក់កណ្ដាលឆមាសទី១នៃឆ្នាំ១៩៧៦នោះ យើងមានភស្ដុតាងជាឯកសារបញ្ជាក់ថា (*ស្លាយ*៣៨) ការប្រជុំទាំងនេះ ត្រូវបានធ្វើឡើយ គឺកំណត់ហេតុនៃការប្រជុំមួយត្រូវបានធ្វើឡើងនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦ ដែលនៅក្នុងការប្រជុំនោះ អនុលេខាភូមិភាគឧត្តរ និង លេខាតំបន់សៀមរាប និងព្រះវិហារ បានមកទីក្រុងភ្នំពេញ ដើម្បីរាយការណ៍អំពីការផលិតស្រូវ ការផ្គត់ផ្គង់ស្បៀង ការសាងសង់ទំនប់ និងប្រឡាយ សុខភាពរបស់ប្រជាជន និងការចាប់ខ្មាំងនៅក្នុងតំបន់របស់ពួកគេ។ តើនរណាជាមេដឹកនាំមជ្ឈិម ដែលពួកគេរាយការណ៍ឱ្យនោះ? *ស្លាយ*៣៩ ១) សមមិត្តលេខាគឺ ប៉ុល ពត, ២) សមមិត្តអនុលេខាគឺ នួន ជា, ៣) សមមិត្ត ហែម គឺ ខៀវ សំផន និង៤) សមមិត្ត ឌឿន គឺ ស៊ើ វ៉ាស៊ី ហៅ ឌឿន ជាមនុស្សម្នាក់ដែល ខៀវ សំផន បានសារភាពថា ជាសមាជិកម្នាក់ផ្សេងទៀត ជាមួយគាត់នៅក្នុងមន្ទីរ៨៧០។ កំណត់ហេតុទាំងនោះកត់ត្រាថា លេខាតំបន់សៀមរាប (១០៦) សុទ្ធបានរាយការណ៍ទៅកាន់ ប៉ុល ពត, នួន ជា, ខៀវ សំផន និង ឌឿន អំពីសភាពការប្រព័ន្ធភ្លឺ អំពីផលស្រូវ អំពីជីវភាពប្រជាជន និងសភាពខ្មាំង។ *ស្លាយ*៤០ រួមទាំងបញ្ហាប្រជាជនឈឺច្រើននៅក្នុងការដ្ឋាន បាក់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កម្លាំង៤០ភាគរយ ហើយក៏មានកើតអ៊ុតស្វាយ និងអាសន្នរោគ។ *ស្លាយ*៤១ លេខាតំបន់ព្រះវិហារ តំបន់១០៣ ហង្ស បានរាយការណ៍ទៅមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាថា៖ "បងប្អូនប្រជាជននៅការដ្ឋានឈឺគ្រុនច្រើន។" គាត់ក៏បានរាយការណ៍ផងដែរថា "មនុស្ស១០០នាក់ ដែលបានព្យាយាមរត់ ត្រូវបានចាប់ខ្លួនតាំងពីខែមករា។" ជាការឆ្លើយតបទៅនឹងរបាយការណ៍ទាំងនោះ លេខាតំបន់នោះត្រូវបានណែនាំឱ្យសាងសង់ភ្លឺស្រែបន្ថែមទៀត និងត្រូវកំណត់ចំនួនការផ្គត់ផ្គង់អាហារ។

[០៩:៥១:៤៨]

លោកប្រធាន លោក លោកស្រីចៅក្រម ផ្អែកលើភស្តុតាងទាំងអស់នេះ វាច្បាស់ហួសពីវិមតិសង្ស័យថា នួន ជា, ខៀវ សំផន, ប៉ុល ពត និងមេដឹកនាំមជ្ឈិមបក្សផ្សេងទៀត នៅក្នុងក្រុងភ្នំពេញបានដឹង និងបានគ្រប់គ្រងខ្ពស់បំផុតលើការងារ និងលក្ខខណ្ឌរស់នៅ ដែលប្រជាជននៅក្នុងសហករណ៍ និងការដ្ឋានរបស់កម្ពុជាប្រជាធិបតេយ្យត្រូវស្ថិតនៅក្រោមនោះ។

ពេលនេះ ខ្ញុំនឹងត្រឡប់ទៅទីតាំងឧក្រិដ្ឋកម្មជាក់លាក់ ដែលជាប្រធានបទនៃការជំនុំជម្រះនេះ។ ពេលនេះ សហព្រះរាជអាជ្ញាលើកឡើងភស្តុតាងនានា ទាក់ទងទៅនឹងទំនប់ត្រពាំងថ្ម។ នៅ*ស្លាយ*៤២៖ ទំនប់ត្រពាំងថ្ម ត្រូវបានកសាងឡើងដោយកងចល័តតំបន់ និងកងចល័តស្រុក នៅក្នុងស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះនៃតំបន់៥ របស់ភូមិភាគពាយ័ព្យ។ ដំណាក់កាលទី១ នៃទំនប់ដ៏ធំធាងនេះ ដែលរួមបញ្ចូលទាំងទំនប់១០ -- ទំនប់បណ្ដោយប្រវែង១៤គីឡូម៉ែត្រ នៅផ្នែកខាងកើតនៃអាងស្តុក និងទំនប់ប្រវែង៨,៥គីឡូម៉ែត្រនៅផ្នែកខាងត្បូង ត្រូវបានសាងសង់ឡើងក្នុងរយៈពីរបីខែ ក្នុងអំឡុងពេលពាក់កណ្ដាលឆមាសទី១ នៅឆ្នាំ១៩៧៧។ កម្មករត្រូវបានណែនាំដោយអ្នកគ្រប់គ្រងទីតាំងនោះ ឈ្មោះ តាវ៉ាល់ ថាទំនប់នេះ ត្រូវបញ្ចប់ក្នុងឆ្នាំ១៩៧៧ ដើម្បីសម្រេចឱ្យបានផែនការមហាលោតផ្លោះ មហាអស្ចារ្យ។

[០៩:៥៣:៤១]

*ស្លាយ*៤៥ ហើយនៅពេលដែលសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ទំនប់នេះ ក្នុងខែធ្នូ ឆ្នាំ១៩៧៧ លេខាភូមិភាគពាយ័ព្យ រស់ ញឹម បានកត់សម្គាល់ថា ទំនប់នេះ ត្រូវបានសាងសង់ឡើង ដើម្បីឆ្លើយតបទៅនឹងសេចក្ដីអំពាវនាវរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដើម្បីកសាងគម្រោងអាងស្តុកទឹកដ៏ធំមួយនេះ។

*ស្លាយ*៤២ ក្នុងអង្គជំនុំជម្រះនេះ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ជាការឆ្លើយតបទៅនឹង

សំណួរមួយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ សំផន បានទទួលស្គាល់ថា គាត់ធ្លាប់បានទៅពិនិត្យទីកន្លែងត្រពាំងថ្ម បន្ទាប់ពីការរៀបរាប់ពីគោលនយោបាយមហាលោតផ្លោះ មហាអស្ចារ្យ ដែលត្រូវបានយល់ព្រមដោយគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជានៅខែឧសភា ឆ្នាំ១៩៧៥ ជនជាប់ចោទរូបនេះ បាននិយាយថា ខ្ញុំសូមដកស្រង់៖ “វាលឿន ធ្វើទំនប់ក៏លឿន ជីកប្រឡាយក៏លឿន ហើយខ្ញុំបានឃើញអ៊ីចឹងមែន នៅឆ្នាំ៧៦ ដែលខ្ញុំមានឱកាសចេញពីភ្នំពេញម្ដងៗ ខ្ញុំបានឃើញទំនប់ ដូចជាត្រពាំងថ្ម ដូចជាទំនប់ខាងលិចបាត់ដំបង។ បើទំនប់ត្រពាំងថ្មវិញ ហាក់ដូចជាសមុទ្រនៅកណ្ដាលវាលដែលពីដើមហួតហែង។”

ខៀវ សំផន ក៏បានទទួលស្គាល់ផងដែរ នូវដំណើរទស្សនកិច្ចរបស់គាត់ឆ្ពោះទៅកាន់ទំនប់ត្រពាំងថ្ម នៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះរបស់គាត់ ដែលគាត់បានរៀបរាប់ខ្លួនឯងថា បានចាប់ចិត្តដោយគ្រាន់តែឃើញប្រព័ន្ធទំនប់ប្រឡាយ។ ការដ្ឋានត្រពាំងថ្ម បានទៅធ្វើទស្សនកិច្ចដោយមេដឹកនាំដទៃទៀត បក្សកុម្មុយនីស្តកម្ពុជា រួមទាំង ប៉ុល ពត ផងដែរ។ វាជាទីកន្លែងមួយដែលការសាងសង់របស់វាត្រូវបានរាយការណ៍ជាទៀងទាត់នៅក្នុងរបាយការណ៍ភូមិភាគពាយ័ព្យ ជូនទៅមន្ទីរ៨៧០។ វាជាទីកន្លែងមួយដែលការសាងសង់របស់វាត្រូវបានមេដឹកនាំមជ្ឈិម បានដឹងច្បាស់ គ្រប់គ្រាន់ល្មមនឹងរៀបរាប់លម្អិតបាន នៅក្នុងសេចក្ដីពិស្ដារនៃទស្សនាវដ្ដីយុវជន យុវនារីបដិវត្ត លេខប្រចាំខែកក្កដា សីហា ឆ្នាំ១៩៧៧។

នៅក្នុងអំឡុងពេលនៃសវនាការនេះ អស់លោក លោកស្រីចៅក្រម បានស្ដាប់សក្ខីកម្មពីអតីតកម្មករ និងកម្មាភិបាលនៅត្រពាំងថ្មចំនួន១៥នាក់ រួមទាំងអតីតអនុប្រធាននៃកងចល័តតំបន់៥ ប្រធានកងអនុសេនាធំមួយចំនួន និងអ្នកយាមម្នាក់ដែលបានចាត់តាំងឲ្យទៅការដ្ឋាននោះ។ សក្ខីកម្មរបស់ពួកគេដែលស៊ីគ្នាទៅនឹងការស្ដាប់ចម្លើយសាក្សីជាច្រើននាក់ផ្សេងទៀត បង្ហាញថាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទីនេះ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់។ ដូចជាករណីនៅការដ្ឋានផ្សេងទៀត ដែលជាផ្នែកនៃមហាលោតផ្លោះ មហាអស្ចារ្យ បក្សកុម្មុយនីស្តកម្ពុជាដែរ។ កម្មករនៅទំនប់ត្រពាំងថ្មបានធ្វើការជាច្រើនម៉ោង ព្រឹក ថ្ងៃ និងយប់ ដោយមានការលំបាក ហើយមានការសម្រាកតិចតួច។

[០៩:៥៧:៣៥]

*ស្លាយ៤៩*។ សែន សុផុន, ស៊ុត សុផល និង សម ស័ក្ត ទាំងអស់គ្នាបានធ្វើការពីព្រលឹមអុលចាប់ពីម៉ោងបី ឬបួនភ្លឺ ហើយធ្វើការរហូតដល់ម៉ោងដប់ ឬដប់មួយយប់។ យី ឡែស្វូវ បានផ្ដល់សក្ខីកម្ម

ថា កងរបស់គាត់ត្រូវធ្វើការរៀងរាល់យប់។ ហើយ ឡុត សួយ ដែលបានធ្វើការជាមួយ ជាអ្នកយាមនៅកន្លែងនោះបានបញ្ជាក់ថា ប្រជាជនបានធ្វើការនៅពេលយប់ គឺធ្វើការងាររៀងរាល់ថ្ងៃ ទាល់តែទំនប់នោះរួចបានគេឱ្យយើងផ្លាស់កន្លែងយើង។ ប្រធានកងអនុសេនាធំ ឈុំ សេង បានផ្តល់សក្ខីកម្មថា ក្នុងអំឡុងពេលវាយលុកការងារខ្លាំង ពេលខ្លះខ្លាំង ពេលខ្លះកម្មករបានធ្វើការអត់មានពេលសម្រាកទេ ពីរបីថ្ងៃជាប់គ្នា ដោយមិនមានការសម្រាកនោះទេ។ ធ្វើការងារច្រើនម៉ោងបែបនេះ ដែលបានដាក់ទៅលើពលករ និងនៅពេលខ្លះត្រូវបានត្រួតពិនិត្យដោយ ខៀវ សំផន ក្នុងពេលដំណើររបស់គាត់ទៅមើលត្រពាំងថ្ម និងការដ្ឋានផ្សេងទៀតក្នុងខេត្តនានា។

[០៩:៥៨:០២]

*ស្លាយ៥៥* នៅក្នុងសៀវភៅពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជារបស់ ខៀវ សំផន បានផ្តល់នូវការរៀបរាប់អំពីអ្វីដែលគាត់បានឃើញនៅអំឡុងពេលទស្សនកិច្ចរបស់គាត់ដូចតទៅ៖ “ត្រង់នេះខ្ញុំនឹងឃើញរឿងប្រមូលប្រជាជនទៅសង់ទំនប់ជីកប្រឡាយ គេវាយជួងដាស់ប្រជាជនតាំងពីម៉ោងបីបួនភ្លឺ។ ឯពីល្ងាចហូបបាយរួម ដល់ម៉ោងដប់ពីរយប់មិនទាន់ហើយផង។ ក្នុងអំឡុងពេលធ្វើការ១៥ម៉ោងជាងក្នុងមួយថ្ងៃ ប្រជាជនដែលត្រូវបានចាត់តាំងឱ្យទៅកន្លែងទំនប់ត្រពាំងថ្ម ត្រូវបានបង្ខំឱ្យធ្វើការពិបាកយាប់យឺនក្រៃលែង។

*ស្លាយ៥៨* ភាគច្រើនត្រូវបានចាត់ឱ្យទៅជីកដីដោយប្រើចបកាប់ បន្ទាប់មកត្រូវរែកដី ដោយមានកម្ពស់២០ទៅ -- ទម្ងន់ពី២០ទៅ៤០គីឡូក្រាម ទៅដាក់ខ្នងទំនប់ដែលមានកម្ពស់១០ម៉ែត្រ។ ការកំណត់ប្រចាំថ្ងៃតាមធម្មតារបស់ពួកគេ គឺត្រូវជីក និងរែកដីចំនួន៣ម៉ែត្រគូប។ សាក្សីជាច្រើននាក់បានផ្តល់សក្ខីកម្មថា ពលករនោះត្រូវបានគំរាមកំហែងដោយការដាក់ទណ្ឌកម្ម រួមទាំងការបង្អត់អាហារទៀតផង បើពួកគេខកខានមិនបានធ្វើតាមការកំណត់នោះទេ។ ម្ហូបអាហារសម្រាប់ពលករត្រពាំងថ្មមិនបានទ្រទ្រង់គ្រប់គ្រាន់នោះទេ ដោយមកពីតម្រូវការខាងរាងកាយបំពេញការងារយ៉ាងខ្លាំង។ ម្ហូបអាហារភាគច្រើនមានតែបបរមួយចានចង្កឹះតូច ម្តងម្កាល គេឱ្យហូបបាយ។ សម ស័ក្ត បានផ្តល់សក្ខីកម្មថា ការស្រេកឃ្លានរបស់គាត់ គឺមានយ៉ាងលើសលប់នៅពេលដែលគាត់និយាយថា នឹងប្តូរជីវិតដើម្បីបាយមួយវែ្កត មាន់ស្ងោរមួយចុះ។ ផ្ទុយទៅនឹងអំណះអំណាងរបស់មេធាវីការពារក្តី ដែលថាកម្មាភិបាលមូលដ្ឋានគឺត្រូវទទួលខុសត្រូវចំពោះការរំលោភលើពលករ។ របបអាហារតិចតួច និងធ្វើការជាច្រើនម៉ោង គឺគ្រាន់ -- គឺកាន់តែអាក្រក់ទៅ អាក្រក់ទៅ មិនប្រសើរឡើងសោះនៅក្រោយកម្មាភិបាល

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មូលដ្ឋានត្រូវបានបោសសម្អាត និងដាក់ជំនួសដោយកម្មាភិបាលនិរតីនៅពាក់កណ្តាលឆ្នាំ១៩៧៧។

ដូចដែលលោកប្រធាន លោក លោកស្រីចៅក្រមបានស្តាប់ពីសាក្សីជាច្រើននាក់មកហើយ ដូចជា ឡុត សួយ និង មុន មុត ជាដើម។ កម្មករនៅកន្លែងនេះ មិនអាចរកទឹកផឹកបានគ្រប់គ្រាន់ទេ ហើយត្រូវផឹកទឹកកខ្វក់ពីក្នុងអណ្តូងជិតនោះដើម្បីបំបាត់ការស្រេកឃ្លាន -- ស្រេកទឹក។

ជាថ្មីម្តងទៀត ភស្តុតាងបានបង្ហាញដល់មេដឹកនាំកំពូលបក្សកុម្មុយនីស្តកម្ពុជា ថាបានដឹងពីរឿងទាំងនេះយ៉ាងច្បាស់។ នៅក្នុងសេចក្តីថ្លែងជាសាធារណៈរបស់គាត់នៅខែធ្នូ ឆ្នាំ១៩៧៧ ស្តីអំពីទំនប់ត្រពាំងថ្ម លេខាភូមិភាគពាយ័ព្យ ញឹម បានទទួលស្គាល់ថា គ្រោះរាំងស្ងួតបានកើតឡើងនៅពេលយើងចាប់ផ្តើមសាងសង់អាងស្តុកទឹក ហើយថាពលកររាប់ម៉ឺននាក់នៅឯកន្លែងសាងសង់មិនមានទឹកហូបគ្រប់គ្រាន់ឡើយ។

[១០:០២:៥១]

*ស្លាយ*៥៩៖ ទស្សនាវដ្តីយុវជន យុវនារីបដិវត្ត។ ទស្សនាវដ្តីយុវជន យុវនារីបដិវត្ត លេខប្រចាំខែកក្កដា ឆ្នាំ១៩៧៧ ក៏បានយោងដល់ការខ្វះទឹកផងដែរនៅឯការដ្ឋាននេះដែលបានថ្លែងថា៖ “យោងតាមលក្ខណៈភូមិសាស្ត្រដែលជាវាលរាបស្រឡះធេង គ្មានបឹងត្រពាំង ហើយកម្លាំងក៏មានច្រើនរាប់ម៉ឺននាក់យ៉ាងនេះ នៅការដ្ឋានត្រពាំងថ្មមានចោទបញ្ហាខ្វះដែលយុវជន យុវនារីយើងត្រូវប្រយុទ្ធថែមទៀត ក្រៅពីប្រយុទ្ធនឹងភារកិច្ចស្នូលប្រចាំឆ្នាំ ជាក់ស្តែងគឺប្រយុទ្ធនឹងការខ្វះខាតទឹកប្រើប្រាស់។ បញ្ហាដូចគ្នានេះនៃយុវជន យុវនារីបដិវត្ត ក៏មានបញ្ហាផងដែរនូវការដឹងឮរបស់មេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាអំពីការងារច្រើនម៉ោង និងដោយការដាក់ទណ្ឌកម្មដែលបានដាក់ទៅលើពលករទំនប់ត្រពាំងថ្មដោយការកត់សម្គាល់ថា ពួកគេត្រូវជីក និងរែកដីទាំងយប់ទាំងថ្ងៃ ក្រោមកំដៅថ្ងៃចែងចាំងពេញមួយរដូវប្រាំង ក្នុងគោលបំណងដើម្បីសម្រេចផែនការរបស់បក្ស។

វាជាការច្បាស់ណាស់ដែលចេញពីភស្តុតាងនេះ លោកប្រធាន លោក លោកស្រីចៅក្រម ថាមេដឹកនាំបក្សនៅភ្នំពេញ ត្រូវបានជ្រួតជ្រាបពីលក្ខខណ្ឌនេះទាំងស្រុងដែលប្រឈមដោយពលករដែលត្រូវបានដាក់ការងារឲ្យសង់ទំនប់ត្រពាំងថ្មនេះ។ ថ្ងៃធ្វើការងារមិនចេះចប់ និងហូបអាហារមិនគ្រប់គ្រាន់ និងត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើសុខភាព និងសុខុមាលភាពរបស់ពលករនៅត្រពាំងថ្មនេះ ពួកគេបានក្លាយទៅជាស្គមស្គាំង និងថមថយកម្លាំង។ ស៊ុត សុផល បានផ្តល់សក្ខីកម្មថា គាត់បានស្គមកំព្រឹង ស្គមដូចយើង បើមនុស្សបច្ចុប្បន្នដូចជាចង់ស្មើរជាងមនុស្សកើតអេដស៍ទៅទៀត។ សុខភាពទន់ខ្សោយ និង

លក្ខខណ្ឌរបស់ពលករ មិនអាចត្រូវបានរំលងពី ខៀវ សំផន និងមេដឹកនាំបក្សផ្សេងទៀតដែលបានមកធ្វើទស្សនកិច្ចនៅទីកន្លែងនោះបានទេ។

*ស្លាយ*០៣ អ្នកដឹកនាំម្នាក់ក្នុងចំណោមពួកគេ មេដឹកនាំ អ៊ឹម ចែម បានប្រាប់ ឌី.ស៊ី.ខេម នូវអ្វីដែលគាត់បានសង្កេតឃើញនៅពេលដែលគាត់បានទៅទស្សនកិច្ចនៅត្រពាំងថ្ម។ នៅក្រោយការចាត់តាំងជាលេខាស្រុកព្រះនេត្រព្រះនៅពាក់កណ្ដាលឆ្នាំ១៩៧៧ ខ្ញុំសូមដកស្រង់៖ "ហើយខ្ញុំទៅដល់កន្លែងនោះមើលទៅវេទនាហ្មង វេទនាត្រង់ថាយុវជន យុវនារីតាមការដ្ឋានហ្នឹង យុវជនខ្លះ ដែលឈឺស្គមស្គាំងហ្នឹងហើយមើលខ្ញុំដើរមើលសព្វប្រជាជនដែលជម្លៀសទៅភ្នំពេញអីភាគច្រើន គឺអត់មានអីហូប ឈឺ។" អ៊ឹម ចែម បានរៀបរាប់ថា ប្រជាជនឃ្លានខ្លាំងពេករហូតដល់ហូបផ្លែនិងស្លឹកឈើពុល និងទទួលស្គាល់ថាប្រជាជនស្លាប់ និងអត់អីស៊ី។"

[១០:០៦:៣៦]

លក្ខខណ្ឌមួយផ្សេងទៀតដែល ខៀវ សំផន មិនអាចភ្លេចបាននៅអំឡុងពេលដំណើរទស្សនកិច្ចរបស់គាត់ទៅកាន់កន្លែងនោះ គឺសត្វរុយដែលមាននៅគ្រប់ទីកន្លែងដោយមកពីមិនមានអនាម័យ និងមិនមានបង្គន់ត្រឹមត្រូវ។ សាក្សី សែម សុផុន បានផ្តល់សក្ខីកម្មថា បើនិយាយពីរុយវិញ រោមបបរឡើងជិតឈឹង។ សម ស័ក្ត បានរៀបរាប់ពីរបៀបដែលអាវគាត់ ខោគាត់ចៃពេញខ្លួន។ ការខ្វះអាហាររូបត្ថម្ភនៅឯកន្លែងនោះ ក៏បណ្ដាលឲ្យមានការហើមខ្លួនប្រាណរបស់ពលករផងដែរ។ សម ស័ក្ត បានផ្តល់សក្ខីកម្មថា ជើងរបស់គាត់ហើម ហើយគាត់ដើរទៅអន្ទិលៗ។ អតីតអ្នកយាម ឡុត ស៊្វយ បានផ្តល់សក្ខីកម្មថា កម្មករស្គមស្គាំង ក៏វាហើមស្គម ពីព្រោះវាហូបមិនបានដិតដល់ គាត់បានរៀបរាប់ពីជង្គង់របស់ពលករមួយចំនួនត្រូវឡើងហើម និងធំជាងក្បាលទៀត។ ហើយថានៅពេលដែលគាត់សុំថ្នាំគេលេប គេឲ្យតែថ្នាំអាចម៍ទន្សាយលេប ម៉េចនឹងបាត់។

សាក្សីជាច្រើនទៀតបានរៀបរាប់ថា ប្រជាជនដែលបានធ្វើការដល់ចំណុចមួយត្រូវដួលរលំដោយសារអស់កម្លាំង រួមទាំងប្រធានកងអនុសេនាធំ ឈុំ សេង និងអតីតប្រធានសេដ្ឋកិច្ចកងចល័តតំបន់ ឈិត យឿក ដែលបានផ្តល់សក្ខីកម្មថា គាត់បានឃើញដោយផ្ទាល់ភ្នែករបស់គាត់ ថាមានមនុស្សដួលនៅពេលដែលកំពុងធ្វើការ ដងខ្លួនរបស់គាត់សន្លប់។ ស៊ុត សុផល បានឃើញពលករដួលមកពីការងារច្រើន ព្រោះវាសឹងតែរាល់ថ្ងៃទៅហើយ។ ខ្លះក្នុងចំណោមនោះមិនអាចធ្វើឲ្យដឹងខ្លួនឡើងវិញបានទេ។ ខ្លួនគាត់ផ្ទាល់បានអស់កម្លាំងពេករហូតដល់ពេលខ្លះគាត់ងងុយដេក ផ្អែកនឹងដងចបត្រសេះរបស់

គាត់ ហើយគាត់បានពន្យល់ថា ហេតុអ្វីបានជាគាត់ត្រូវបន្តធ្វើការងាររហូតដល់អស់កម្លាំងពីខ្លួនដូច្នេះថា "វាឈឺទាំងគេ ឈឺទាំងខ្ញុំនឹងឯង ប៉ុន្តែមិនដែលហ៊ានសម្រាកទេ ឈឺយ៉ាងម្តេច ធ្វើការទាំងឈឺ លុះត្រាតែដួលងាប់តែម្តង អាហ្នឹងបានឈប់ធ្វើ ឲ្យតែនៅឈឺយ៉ាងម៉េចនៅតែធ្វើ បើគេប្រើយើងមិនធ្វើ គេថាវាឈឺសតិអារម្មណ៍។"

[១០:០៩:៣២]

លោកប្រធាន លោក លោកស្រីចៅក្រម វាមិនមានការសង្ស័យទៀតទេដែលជារឿង នេះជាការងារបែបទាសករ។ ប្រជាជនដែលបានបញ្ជាឲ្យទៅធ្វើការនៅត្រពាំងថ្ម គ្មានជម្រើសទេ ពួកគាត់មិនអាចប្រកែក មិនធ្វើការនៅកន្លែងនោះបានទេ ហើយពួកគាត់មិនអាចចាកចេញបានដែរ សូម្បីតែទៅលេងក្រុមគ្រួសារក៏មិនបានដែរ។ ដូចដែលលោកប្រធាន លោក លោកស្រីចៅក្រមធ្លាប់បានឮពី ញ៉ឹក ផល ធ្វើទាំងកម្លាំងចិត្ត បើកម្លាំងកាយអត់មាន គឺកម្លាំងខ្លាចស្លាប់ហ្នឹងតែម្តង មិនហ៊ានតវ៉ាជាមួយអង្គការទេ។ មុន មុត បានផ្តល់សក្ខីកម្មថា កម្មករត្រូវបានគេប្រព្រឹត្តមកលើខ្លួនដូចគោ ដូចក្របី។ ដោយការពន្យល់ថា "ចេះតែលើកៗរាល់ថ្ងៃ ផុតនេះទៅឯណោះ ផុតពី រួចផ្ទះនេះទៅឯណោះ ផុតពីអីនោះ ទៅឯណោះទៀត មិនដឹងថាពេលណា ថ្មើរណាទេ"។

ការដ្ឋានទំនប់ត្រពាំងថ្ម ត្រូវបានល្បាតដោយអ្នកយាមប្រដាប់ដោយកាំភ្លើងសេ.កា.សេ។ ម្នាក់ក្នុងចំណោមនោះ គឺធ្លាប់បានមកបង្ហាញខ្លួននៅចំពោះមុខលោកប្រធាន លោក លោកស្រីចៅក្រម ឡុត សួយ បានផ្តល់សក្ខីកម្មថា៖ "អង្គភាពយាមកាមត្រូវបានចាត់តាំងមើលកងចល័តនោះរត់ឆ្លងដែន ឆ្លងទំនប់។" នៅពេលដែលពលករបានព្យាយាមរត់គេច អ្នកយាមត្រូវបានចាត់តាំងឲ្យចាប់បញ្ជូនទៅឲ្យតាមវរៈ តាមកងរបស់គេវិញ។

[១០:១១:២៥]

លោក លោកស្រីចៅក្រម ភស្តុតាងពីកន្លែងនោះគឺច្បាស់ហើយ ពលករស្គមកំព្រឹង ដែលបានបង្ខំឲ្យធ្វើការតាមកម្លាំងកាយ ដោយយ៉ាប់យ៉ឺនក្រៃលែង ចាប់ពីព្រលឹមរហូតដល់ម៉ោងដប់ ឬដប់មួយយប់ដែលបានរំពឹងថា នឹងរស់រានមានជីវិតលើរបបមួយចំណែកតូច ត្រូវបានបង្ខំចិត្តធ្វើការដកហូតទាល់ពួកគេដួល និងត្រូវបានគេស្វែងរកចាប់ ដោយអ្នកយាមប្រដាប់អាវុធ បើពួកគេព្យាយាមរត់គេច។ រឿងនេះគឺអ្វីដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានស្វែងរក ធ្វើឲ្យបានសម្រេចនូវផែនការមហាលោតផ្លោះមហាអស្ចារ្យរបស់ពួកគេ។

ឧក្រិដ្ឋកម្មមនុស្សជាតិនេះ ស្តីពីការធ្វើឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានបង្ហាញសក្ខីកម្មយ៉ាងជាក់លាក់ហួសពីវិមតិសង្ស័យ។ ភស្តុតាងពីទំនប់ត្រពាំងថ្ម ក៏បានបង្ហាញពីសក្ខីកម្មអំពីឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញខាងនយោបាយផងដែរ។ អតីតប្រធានកងអនុសេនាធំ ឈុំ សេង បានផ្តល់សក្ខីកម្មជូនដល់អង្គជំនុំជម្រះអំពីការប្រជុំមួយ ដែលបានធ្វើឡើងដោយអ្នកទទួលខុសត្រូវការដ្ឋាន តាវ៉ាល់ ដែលប្រធានកងអនុសេនាធំ និងកងវរសេនាតូចត្រូវបានណែនាំឲ្យតាមដាន និងស្វែងរកបុគ្គលនានានៅក្នុងកងរបស់ខ្លួន ដែលជាអតីតទាហាន លន់ នល់ ឬជាបញ្ញវន្ត។

ឈុំ សេង បានទទួលស្គាល់ថា ពួកប្រធានត្រូវបានផ្តល់នូវសិទ្ធិអំណាច អាចសម្លាប់មនុស្សបានជាខ្មាំង ដែលត្រូវសម្លាប់ចោល រួមមានអតីតទាហាន បុគ្គលដែលប្រឆាំងនឹងអង្គការ--

[១០:១៣:៤០]

**ប្រធានអង្គជំនុំ៖**

បាទចង់ឲ្យសម្រាក ប៉ុន្តែកណ្តាលទី ចង់រកកន្លែងចុះសិនទៅ បានយើងសម្រាកទៅ វាសមរម្យ។

**លោកស្រី ជា លាង៖**

ដោយសារនៅវែង អ៊ីចឹងខ្ញុំសូមចប់មួយកថាខណ្ឌទៀត ហើយចាំសម្រាក ឬមួយ – ចាស អរគុណ។ ផុត -- ខ្ញុំ មួយកំណាត់ អានឡើងវិញ។

ភស្តុតាងពីទំនប់ត្រពាំងថ្ម ក៏បង្ហាញពីសក្ខីកម្មអំពីឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញខាងនយោបាយផងដែរ។ អតីតប្រធានកងអនុសេនាធំ ឈុំ សេង បានផ្តល់សក្ខីកម្មជូនដល់អង្គជំនុំជម្រះ អំពីការប្រជុំមួយ ដែលបានធ្វើឡើងដោយអ្នកទទួលខុសត្រូវការដ្ឋាន តាវ៉ាល់ ដែលប្រធានកងអនុសេនាធំ និងកងវរសេនាតូច ត្រូវបានណែនាំឲ្យតាមដាន និងស្វែងរកបុគ្គលនានានៅក្នុងកងរបស់ខ្លួន ដែលជាអតីតទាហាន លន់ នល់ ឬបញ្ញវន្ត។ ឈុំ សេង បានទទួលស្គាល់ថា ពួកប្រធាន ត្រូវបានផ្តល់នូវសិទ្ធិអំណាច អាចសម្លាប់មនុស្សបាន ជាខ្មាំងដែលត្រូវសម្លាប់ចោល រួមមានអតីតទាហាន បុគ្គលដែលប្រឆាំងនឹងអង្គការ និងភ្នាក់ងារយួន ឬ សេ.អ៊ី.អា។

សូមអនុញ្ញាតឈប់ប៉ុណ្ណេះ ដើម្បីទៅតស្រួល អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងសម្រាក ខ្ញុំសូមសួរទៅសហព្រះរាជអាជ្ញាជាតិបន្តិច យើងបានស្តាប់នូវការបង្ហាញក្នុងសេចក្តីសន្និដ្ឋាននេះ គឺបង្ហាញជា*ស្លាយ* ប៉ុន្តែ*ស្លាយ*នេះបានបង្ហាញរួចហើយ

ដោយមិនបានបង្ហាញនូវអត្តសញ្ញាណឯកសារទេ។ អាចំណុចដែល *ឃ្លូត*យកមកដាក់បង្ហាញនេះ យើងមើលមធ្យោបាយនេះ អាចមានបញ្ហាប្រឈមនៅក្នុងការពិនិត្យជាក់ស្តែងដែរ ហើយគួរតែត្រូវបានបង្ហាញនូវអត្តសញ្ញាណឯកសារ រួមទាំងលេខ ERN ឬក៏លេខទំព័រផងដែរ ដើម្បី -- ព្រោះអានេះ ជា *ឃ្លូត* យកពីឯកសារភស្តុតាងដែលបានពិភាក្សាដេញរួចហើយ។

[១០:១៦:០៣]

បញ្ហាទី២ ទំនងជាត្រូវបាន គួរតែត្រូវបានចែកចាយនូវ*ស្លាយ*នេះ ដល់អង្គជំនុំជម្រះ និងភាគីពាក់ព័ន្ធ ដើម្បីឲ្យភាគីហ្នឹង បានពិនិត្យមើលផងដែរ ពីព្រោះដូចជា សម្តេច សីហនុ យោងទៅសម្តេច សីហនុ អ៊ីចឹង ខាងភាគីជាតិដូចខ្ញុំហ្នឹង អត់ចេះបារាំងទេ។ អ៊ីចឹងខ្ញុំឃើញគាត់និយាយភាសាបារាំង ដូចអត់ដឹងថាម៉េចដែរ។ ហើយការសង្ខេបហ្នឹងបាន ប៉ុន្តែអានេះគ្រាន់តែជាការបង្ហាញទេ ដល់សំខាន់គឺខ្លឹមសារនៃពាក្យពេចន៍ហ្នឹង យើងអត់បានធ្វើការបញ្ជាក់ទេ ហើយមិនដឹងថាតើយោងទៅក្នុងការរៀបចំការពិចារណានុ៎ង យ៉ាងដូចម្តេច?

នេះសូមឲ្យពិនិត្យបញ្ហាពីរចំណុចនេះឡើងវិញ ដើម្បីឲ្យរៀបចំហ្នឹងឲ្យបានល្អ។ ហើយភាគីប្រហែលជាមិនខុសពីខ្ញុំទេ តាមមើល ព្រោះអាចមានបញ្ហាដែរ បើទៅតាមបញ្ហានេះមិនទាន់ របៀបព្រោះរបៀបធ្វើនេះ គឺអាចខុសពី បច្ចេកទេសខុសពីមុន។ អ៊ីចឹងសូមឲ្យពិនិត្យពីរចំណុចនេះ។ បាទ ទី១ គឺបញ្ហាកំណត់អត្តសញ្ញាណលេខដែលឯកសារ ដែល*ឃ្លូត*ចេញមក ធ្វើដាក់*ស្លាយ*បង្ហាញនេះ ហើយ និងទី២ គឺរឿងគួរតែត្រូវបានចែកចាយនូវ*ស្លាយ*មកជូនភាគីពាក់ព័ន្ធ រួមទាំងអង្គជំនុំជម្រះផងបាទ។

[១០:១៧:២០]

**លោកស្រី ជា លាង៖**

បន្ទាប់ទៅទៀត ខ្ញុំនឹងផ្តល់ជូននូវឯកសារលេខ ដូចជា E ប៉ុន្មាន លេខប៉ុន្មានហ្នឹង ជាមួយនឹង*ស្លាយ*ហ្នឹងតែម្តង។ ខ្ញុំមាន អត់អីទេ ខ្ញុំផ្តល់ជូនអង្គជំនុំជម្រះបាន។ ដោយឡែកឃ្លីបហ្នឹង ចំពោះសម្តេច រតនកោដ្ឋហ្នឹង គឺមានតែមួយហ្នឹង ដោយសារ ខ្ញុំអត់បានស្តាប់ជាខ្មែរដែរទេ គឺខ្ញុំស្តាប់ក្នុងនេះ ខ្ញុំឮជាភាសាអង់គ្លេសដូចគ្នា។ អ៊ីចឹង តើអង្គជំនុំជម្រះទាមទារដើម្បីយកជាភាសាខ្មែរ ឬមួយក៏យ៉ាងម៉េចអាហ្នឹង? ចាំ--

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវបង្ហាញជាសាធារណៈ ហើយខ្មែរនិយាយ ហើយដល់ពេលខ្មែរនិយាយចេញបារាំង ចុះ

វាមិនដឹងថា ដោយសារយ៉ាងម៉េចវាបញ្ហាដែរ អ៊ីចឹង ហើយសាធារណជនក៏ដូចខ្ញុំដែរ ហើយចង់ដឹងថា បើសិនជាវានៅអ៊ីចឹង បាននន័យថា សម្ដីហ្នឹងអត់ត្រូវបានបកប្រែទេ បើខ្ញុំយល់ អត់មានបានបកប្រែទេ ព្រោះមិនមែនជាសម្ដីរបស់អ្នកនិយាយទេ សម្ដី*ប្រូត*អ៊ីចឹងមក អ៊ីចឹងវាអត្ថន័យ ដោយសារយើងយកទៅបញ្ជ្រាបបញ្ចូលទៅក្នុងឯកសារ នៅក្នុងយោងជាឯកសារភស្ដុតាងដែលថា យកពិចារណាសម្រេចសរសេរសាលក្រមហ្នឹងយ៉ាងដូចម្ដេច។

[១០:១៨:២៨]

**លោក នីកូឡាស គូមជែន៖**

លោកប្រធានពាក់ព័ន្ធទៅនឹងបញ្ហានៃការបកប្រែលើបញ្ហានេះ យើងខ្ញុំនឹងបញ្ចាំង<ខ្សែភាពយន្តខ្លីៗ>ជាភាសាអង់គ្លេស ឬជាភាសាបារាំង ឬក៏ជាភាសាខ្មែរ ហើយយើងខ្ញុំយល់ឃើញថា <យើងរំពឹងថា អ្នកបកប្រែ អាចបកផ្ទាល់>បើសិនណានេះ <>តាម*ទាណែល* <ភាសារៀងខ្លួន>។ នេះ<គឺជា> វីដេអូឃ្លីបគឺ E3/3113R <ចាប់ផ្ដើមនៅនាទី ២៩:៣២ ដែលជា>វីដេអូឃ្លីបរបស់សម្ដេចព្រះរតនកោដ្ឋ<សីហនុ។> យើងខ្ញុំនឹងផ្ដល់ឯកសារយោង<>ទាំងអស់នេះ <គឺលេខ E3> ដោយសារថា សាធារណជនក៏មិនយល់ដែរ ថាតើ E3 ហ្នឹងមានន័យថាម៉េច<> ប្រហែលជាមិនចាំបាច់<ផ្ដល់>ទេមើលទៅ ប៉ុន្តែយើងមានឯកសារ E3 <ទាំង>នេះ។ អ៊ីចឹង <បញ្ហាចោទគឺថា តើយើងអាចផ្ដល់ឯកសារទាំងនោះដល់សហព្រះរាជអាជ្ញារបស់ខ្ញុំទាន់ពេលសម្រាប់វគ្គបន្ទាប់ទៀត ឬយ៉ាងណា។>

**លោក វ៉ិចទ័រ កូប៉េះ៖**

បាទ លោកប្រធាន ជាការពិតហើយ យើងខ្ញុំក៏ចង់លើកឡើងអំពីបញ្ហានេះដែរ ព្រោះយើងខ្ញុំបានរៀបចំ<>សេចក្ដីសន្និដ្ឋានផ្ទាល់មាត់របស់យើងខ្ញុំនេះ ដោយមិនបានយោងច្រើនទៅលើឯកសារ E3 ទេ <ដើម្បីធ្វើឱ្យដំណើរលើកឡើងទឡ្ហីករណ៍ទៅបានរលូន> ហើយបើពិចារណាទៅលើអង្គហេតុនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោល គឺថាយើងបានយោងទៅលើឯកសារ E3 ពាក់ព័ន្ធទាំងអស់។ ឥឡូវនេះ គឺជាបំណងរបស់អង្គជំនុំជម្រះទេ បើសិនណាជាយើងដកស្រង់សម្ដី<បុគ្គល>ណាម្នាក់ <ឬពេលណាយើងដកស្រង់ឯកសារ>គឺថាយើងត្រូវតែបង្ហាញជូនអង្គជំនុំជម្រះនូវឯកសារ E3 <អ៊ីចឹង វានឹងធ្វើឱ្យលើកឡើងទឡ្ហីករណ៍យើងកាន់តែយឺត ហើយខ្ញុំគិតថា ដូចគ្នាដែរចំពោះខាងព្រះរាជអាជ្ញា។>។ <>ហេតុដូច្នេះឯង យើងខ្ញុំមិនបានក្រោកឈរជំទាស់ទេ នៅពេលដែលវីដេអូឃ្លីបនេះ ត្រូវបានយកមកបញ្ចាំង។ ដោយសារថា យើងខ្ញុំដឹង<ហើយ>ថា ខ្សែវីដេអូទាំងអស់នេះ<មាននៅក្នុងសារណាបញ្ចប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការសួរដេញដោលនេះ ហើយយើងក៏ដឹងថា វា>យកមកពីខាងណា<ដែរ>។ <ដូច្នេះ ប្រហែលវាជាបញ្ហាមួយដែលយើងគួរតែសម្រេចនាពេលឥឡូវនេះ។>

**ប្រធានអង្គជំនុំ៖**

អញ្ជើញ! អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

<គ្រាន់តែជាការកត់សម្គាល់មួយប៉ុណ្ណោះ។> ខ្ញុំឃើញថា រូបដែលបញ្ចាំងនៅលើអេក្រង់នោះ ឃើញនៅផ្នែកខាងក្រោមនៃរូបភាពទាំងអស់នោះៗ អានមិនដាច់ទេ ឯកសារ E3 ហើយនិងលេខ ERN អីជាដើមនេះ អានមិនដាច់ទេ។ ឥឡូវនោះ គឺថាយឺតពេលបន្តិចហើយ ក៏ប៉ុន្តែវាមានប្រយោជន៍ដើម្បីធ្វើយ៉ាងណា ដើម្បីឲ្យលេខយោងទាំងអស់នោះយើងមើលឃើញ<ច្បាស់ជាងហ្នឹង>។ អ្វីដែលសំខាន់សម្រាប់អង្គជំនុំជម្រះហ្នឹង គឺថាឯកសារដែលយើងត្រូវប្រើនោះ យើងច្បាស់ថា ជាឯកសារដែលបានដាក់បង្ហាញជូនអង្គជំនុំជម្រះ <ហើយ>ជំនុំជម្រះ<ទទួលយក>រួច<>ហើយ។

[១០:២១:៣៥]

**លោក នីកូឡាស គូមជែន៖**

<សូមអរគុណ។ លោក លោកស្រីចៅក្រម ប្រហែលវាជាដំណោះស្រាយមួយ តែខ្ញុំគិតថា យើងមិនអាចអនុវត្តវាបានទេនៅពេលសម្រាកបន្ទាប់នេះ ប៉ុន្តែប្រាកដណាស់ នៅចុងបញ្ចប់នៃថ្ងៃនេះ> យើងអាចផ្តល់ដល់ភាគីនានា នូវឯកសារខ្សែអាត់ <និង>វីដេអូដែល<យើង>ចង់ប្រើប្រាស់សម្រាប់រយៈពេលពីរ<>ថ្ងៃខាងក្រោយនេះ <ដោយមានលេខE3 ជាមួយនឹងប្រភពឯកសារនានា ដោយ>ខ្ញុំនឹងដាក់ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួម ហើយភាគីនានា គាត់អាចចូលពិនិត្យមើល <ហើយដាក់ឯកសារខ្សែអាត់-វីដេអូរបស់ខ្លួន> ហើយ<>ផ្ញើអ៊ីម៉ែល<ដោយប្រាប់អំពីប្រភពឯកសារទាំងនោះ។ អ៊ីចឹងប្រហែលយើងមិនចាំបាច់ទៅដកស្រង់លេខ>ឯកសារ<>E3 <ក្នុងអំឡុងពេលនៃការដាក់បង្ហាញឯក-សារនោះទេ>។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការបញ្ជាក់នេះ។ បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២២ នាទី ដល់ម៉ោង ១០:៤០ នាទី)*

[១០:៤០:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុនផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាជាតិ សូមបញ្ជាក់ថាអ្វីដែលបាន -- ខ្ញុំបានលើកលើងហ្នឹងបានដោះស្រាយរួចហើយ អ៊ីចឹងមិនមានបញ្ហាអីទេ សូមបន្តទៅទៀតចុះដើម្បីឲ្យបានឆាប់។ ហើយសូមបញ្ជាក់ថា ភាគីទាំងអស់រួមទាំងសហព្រះរាជអាជ្ញាផង គឺសូមឲ្យប្រកាន់ខ្ជាប់ខ្លួននៅតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះដែលបានណែនាំនៅក្នុងឯកសារ E457/7 ហើយបានបញ្ជាក់ជូនរំឭកដល់ភាគីរួចហើយ កាលពីម្សិលមិញអំពីការប្រើប្រាស់ឯកសារ។

បាទ សូមអញ្ជើញបាទ!

[១០:៤១:៤៧]

**លោកស្រី ជា លាង៖**

ចាស សូមអរគុណ។ ហើយអរគុណច្រើនសម្រាប់ដំណោះស្រាយដែលមានការ អម្បាញ់មិញទាក់ទងនឹងការឯកសារនេះ ដូច្នេះអរគុណច្រើន។ ហើយយើងនឹងធ្វើតាមអ៊ីម៉ែលគ្រប់ភាគីទាំងអស់ ក៏ដូចជាអង្គជំនុំជម្រះនូវឯកសារយោងនេះ។

ហើយសូមអនុញ្ញាតបន្តទៀត ទាំងឈុំ សេង, ទាំងឡុយ ហ៊ុយ -- ឈុយ ហ៊ុយ ដែលជាប្រធានកងអនុសេនាធំផ្សេងទៀត បានកំណត់អត្តសញ្ញាណទាហាន លន់ នល់ នៅក្នុងកងរបស់ខ្លួនដែលត្រូវបានដកចេញ និងត្រូវបានបាត់ខ្លួន។ ឡូត សួយ ដែលជាទាហាននៅស្រុកភ្នំស្រុក នៅមុនពេលការចាត់តាំងឲ្យទៅទំនប់ត្រពាំងថ្ម បានផ្តល់សក្ខីកម្មថា បក្សកុម្មុយនីស្តកម្ពុជាបានចម្រាញ់ អ្នកដែលបានជាប់ខ្សែបណ្តាញទាហាន លន់ នល់ ហើយដកចេញយកទៅសម្លាប់ចោល។ ហើយគាត់បានកំណត់អត្តសញ្ញាណអតីតទាហានលន់ នល់ ដែលបានធ្វើការនៅទំនប់ត្រពាំងថ្ម ដែលត្រូវបានចាប់ខ្លួន និងត្រូវបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាត់ខ្លួន។

ការធ្វើទុកបុកម្នេញអតីតទាហាននៃរបបនៅក្នុងតំបន់នេះ ក៏ត្រូវបានផ្តល់សក្ខីកម្មផងដែរ ដោយ សែន សុផន ដែលបានរកឃើញនៅក្រោយការវិលត្រឡប់មកកាន់ភូមិកំណើតរបស់គាត់វិញថា ឪពុកម្តាយនិងបងប្អូន ត្រូវបានសម្លាប់ ដោយសារតែអតីតមុខតំណែងរបស់ឪពុកគាត់ ជាអនុសេនីយទោ លន់ នល់។ ដូចជាគ្រប់តំបន់ និងអង្គការទាំងអស់របស់កម្ពុជាប្រជាធិបតេយ្យដែរ។ ការចាប់ទាហាន និងមន្ត្រីផ្លូវការនៃអតីតរបបលន់ នល់ ត្រូវបានរាយការណ៍ជូនទៅមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅភ្នំពេញ។

ជាឧទាហរណ៍ នៅខែឧសភា ឆ្នាំ១៩៧៧ របាយការណ៍ពីភូមិភាគពាយ័ព្យបានរៀបរាប់ពីកិច្ចប្រឹងប្រែងបន្តទៀត ក្នុងការចាប់ខ្លួនអតីតទាហាន ដូចជា ស័ក្តិ១ ស័ក្តិ២ ស័ក្តិ៣ រហូតដល់ស័ក្តិ៤ ដែលកប់នៅតាមសហករណ៍។ អង្គជំនុំជម្រះក៏ធ្លាប់បានស្តាប់សក្ខីកម្ម ស្តីពីការចាប់ខ្លួននិងការសម្លាប់ពលករនៅកន្លែងនេះ។ យី ឡៃស្រូវ ក៏បានផ្តល់សក្ខីកម្មថា គាត់ធ្លាប់បានឃើញមានការចាប់ខ្លួនមនុស្សចំនួន១៥នាក់ មានបុរសនិងស្ត្រី។ ហើយគាត់បានរៀបរាប់ថា គាត់បានឮសូរសំឡេងអ្នកទាំងនោះស្រែកឲ្យជួយ នៅពេលដែលពួកគាត់ត្រូវបានគេវ៉ៃរហូតទាល់តែស្លាប់។ ស៊ុត សុផល ធ្លាប់បានឃើញកងឈ្លបវ៉ៃពលកររហូតដល់ស្លាប់ពីរដង ហើយធ្លាប់បានចូលរួមកប់សាកសពពលករទាំងនោះនៅក្នុងរណ្តៅ។ សាក្សីទាំងពីរនាក់ផ្សេងទៀត តក់ ប៊ុយ និងប្រធានកងអនុសេនាធំ ឈុំ សេង ក៏បានរៀបរាប់ផងដែរថា ពួកគាត់ធ្លាប់បានជួយកប់សាកសពមិត្តភក្តិពលករនៅកន្លែងនោះដែរ។ ឈុំ សេង បានផ្តល់សក្ខីកម្មថា "នៅពេលហ្នឹងក៏មានការឈឺច្រើន តែមួយចំនួនហ្នឹងក៏គេយកទៅវ៉ៃចោល ដូចថាយើងឈឺសតិអារម្មណ៍។" គាត់បានរៀបរាប់អំពីការសម្លាប់ពលករចំនួន១១នាក់ ដែលគេបានពិសោធរកភាពខ្វាក់នៅពេលយប់ ជារឿងមួយដែលត្រូវបានផ្តល់សក្ខីកម្មត្រូវគ្នាផងដែរជាមួយនឹងសាក្សីបីរូបផ្សេងទៀត។ ទាំង ឈុំ សេង ទាំង ឡុត សួយ បានផ្តល់សក្ខីកម្មពីការចាប់ខ្លួន និងការបញ្ជាឲ្យសម្លាប់ចោលដែលចេញមកពីប្រធានកន្លែងត្រពាំងថ្ម ពី តាវ៉ាល់។

[១០:៤៥:៣៨]

បន្តទៀតនេះសូមបង្ហាញអំពីភស្តុតាងពាក់ព័ន្ធនឹងទំនប់១មករា។ *ស្លាយ*លេខ៦៨ ទំនប់១មករា គឺជាទំនប់មានប្រវែង៦០គីឡូម៉ែត្រដែលបានកសាងនៅលើស្ទឹងជីនិត ក្នុងស្រុកបារាយណ៍ និងស្រុកសន្ទុកនៃភូមិភាគកណ្តាលនៅឆ្នាំ១៩៧៧ ដូចទំនប់អាងត្រពាំងថ្មដែរ។ ទំនប់១មករា ត្រូវបានកំណត់ថាជាស

មរភូមិក្ដៅដែល មាស ឡៃហួរ បានផ្ដល់សក្ខីកម្មថា កម្មករជាញឹកញាប់ត្រូវធ្វើការដល់យប់ រហូតដល់ពាក់កណ្ដាលអធ្រាត្រ និងត្រូវរត់ពេលរែកដី។ ខ្សែអាត់វីដេអូនេះ ដែលជាវីដេអូដើមរបស់មាស ឡៃហួរ និងដើមបណ្ដឹងរដ្ឋប្បវេណី ថៅ ឡាង នៅក្នុងអំឡុងសវនាការបង្ហាញពីទីតាំងការដ្ឋានទំនប់១មករា។ សូមចាក់វីដេអូលេខ៣។

[១០:៤៧:១០]

*(ការបង្ហាញឯកសារជារូបភាព)*

*(បញ្ចប់ការបង្ហាញឯកសារជារូបភាព)*

[១០:៤៩:០៩]

លោក លោកស្រីបានឃើញតាមរយៈវីដេអូនេះ ច្រាំងដ៏ចោទដែលប្រជាជនធ្វើការនៅទីនោះ និងដីក្នុងបង្គីដែលកម្មករកំពុងសែង ឥតឈប់ឈរនៅពាសពេញទីតាំងដ៏ធំសម្បើមនេះ។ ការដ្ឋានទំនប់១មករា ត្រូវបាន នួន ជា, ប៉ុល ពត និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀតបានទៅពិនិត្យមើល។ លេខាភូមិភាគកណ្ដាល កែ ពក ជាអ្នកទទួលខុសត្រូវក្នុងការកសាងទំនប់នេះ ហើយគាត់បានមកពិនិត្យមើលទីតាំងនេះសឹងតែរៀងរាល់ថ្ងៃ និងបានរាយការណ៍ជូនមេដឹកនាំមជ្ឈិមបក្សនៅភ្នំពេញស្ដីពីការដ្ឋាននេះ។

ការចុះមកពិនិត្យរបស់ នួន ជា នៅលើការដ្ឋានទំនប់១មករានេះ ត្រូវបានបញ្ជាក់អះអាងក្នុងសាលសវនាការនេះ ទាំងដោយកងការពារផ្ទាល់របស់គាត់ សូត្រ ទឿង ដែលជាអ្នកដែលបានអមដំណើរ នួន ជា ទៅតាមបណ្ដាខេត្តនានារៀងរាល់ពីរឬបីខែម្ដង។ និង ស៊ូ សឿន អតីតលេខាស្រុកនិងជាប្រពន្ធរបស់ កែវ ពក។ សូត្រ ទឿង បានផ្ដល់សក្ខីកម្មថា នួន ជា បានមកពិនិត្យមើលទីតាំងទំនប់យ៉ាងជិតដែលគាត់អាចមើលឃើញថា គេកសាងមិនបានល្អទេ និងថាគាត់បានផ្ដល់ការណែនាំដល់អ្នកដែលទទួលខុសត្រូវចំពោះគម្រោងនេះ។ គាត់បានផ្ដល់សក្ខីកម្មថា នួន ជា បានចុះពិនិត្យការដ្ឋានទំនប់នេះ ខ្ញុំសូមដកស្រង់៖ “ជាញឹកញាប់ណាស់”។

នៅក្នុងខ្សែវីដេអូបន្ទាប់នេះ លោក លោកស្រីចៅក្រមបានឃើញ នួន ជា ពិនិត្យការដ្ឋានមួយដែលមានមនុស្សកំពុងលើកទំនប់ ឬជីកប្រឡាយ ខណៈដែលវីដេអូនេះគ្រាន់តែជាវីដេអូខ្លីមួយ ប៉ុន្តែលោក លោកស្រីនឹងបានឃើញថា នួន ជា មិនមែនសម្លឹងមើលកម្មករពីចម្ងាយទេ គឺគាត់នៅទីនោះតែម្ដង នៅក្នុងចំណោមកម្មករដែលកំពុងតែរែកដី។ សុំចាក់វីដេអូលេខ៤។

*(ការបង្ហាញឯកសាររូបភាព)*

[១០:៥១:៣៦]

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព ដូចគ្នានឹងករណី ខៀវ សំផន ដែរ នួន ជា មានឱកាសយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងការសង្កេតលើការពិតនៃការដ្ឋានពលកម្មការងារដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា។ តំបន់១មករា ដែលស្ថិតនៅលើដងស្ទឹងជីនិត បានក៏បានឮទៅដល់ ខៀវ សំផន ផងដែរ ដោយសារគាត់ធ្លាប់លើកនៅក្នុងសុន្ទរកថាមួយដែលគាត់បានថ្លែងជូនកម្មាភិបាល និងកម្មករ រាប់ពាន់នាក់នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ដែលបានផ្សាយតាមវិទ្យុកម្ពុជាប្រជាធិបតេយ្យ។ ក្នុងសុន្ទរកថានោះ ខៀវ សំផន បានបង្ហាញយ៉ាងច្បាស់ពីការដឹងឮរបស់គាត់អំពីស្ថានភាពរបស់កម្មករដែលកំពុងធ្វើការនៅទំនប់ស្ទឹងជីនិត និងទីតាំងផ្សេងទៀត។

*ស្លាយ*លេខ៦៩ គាត់និយាយថា ខ្ញុំសូមដកស្រង់៖ "នៅទូទាំងប្រទេស ការដ្ឋានសាងសង់ទាំងអស់នឹងបង្ហាញតាមផែនការឆ្នាំ១៩៧៧ នៅបំណាច់ខែឧសភានេះ។ គម្រោងទាំងនេះ រួមមានទាំងទំនប់ស្រោចស្រពវាលស្រែពេញមួយឆ្នាំ ហើយមានទឹកនៅព្រែកត្នោត ជីនិត និងស្ទឹងផ្សេងទៀត។ ទំនប់ទឹកនីមួយៗ មានកម្មករធ្វើការប្រហែលជា១០.០០០, ២០.០០០, ៣០.០០០នាក់។ យើងគ្មានគ្រឿងម៉ាស៊ីនទេ។ យើងធ្វើការងារគ្រប់យ៉ាងពឹងផ្អែកជាសំខាន់ទៅលើកម្លាំងប្រជាជនយើង ទោះជាបាត់ដៃទទេក៏ដោយ ក៏ពួកគេអាចធ្វើការងារបានគ្រប់យ៉ាងបានដែរ។" សុន្ទរកថាដដែល ក៏បង្ហាញពីរបៀបដែល ខៀវ សំផន បានរួមចំណែកក្នុងការអនុវត្តផែនការមហាលោតផ្លោះ មហាអស្ចារ្យរបស់បក្ស ដែលតាមរយៈសេចក្តីថ្លែងការណ៍នានាដែលយល់ស្របតាមផែនការរបស់បក្សក្នុងការកសាងទំនប់ធំៗដូចជា ទំនប់អាងត្រពាំងថ្ម និងទំនប់១មករា នៅក្នុងរយៈពេលតែប៉ុន្មានខែជាដើម។

[១០:៥៣:៣៩]

*ស្លាយ*៧៥ គាត់និយាយថា៖ "អាងស្តុកទឹកប្រឡាយ និងព្រែកជីកដែលយើងបានបញ្ចប់នាពេលបច្ចុប្បន្ននេះ នឹងចំណាយច្រើនឆ្នាំណាស់ក្នុងការសាងសង់ឲ្យបានចប់ បើសិនជាយើងរង់ចាំអ្នកជំនាញឯកទេសកសិករសម័យមុន កសាងឲ្យយើងនោះ ក្រឡេកមើលទំនប់ទំនប់ព្រែកត្នោត ឆ្នាំមុនយើងបានចំណាយពេលតែមួយខែដើម្បីបានទឹកស្ទឹងព្រែកត្នោត។ ទោះបីយើងចំណាយពេលត្រឹមតែ៥ ឬ១០ឆ្នាំក្នុងការកសាង -- ក្នុងកសាងទំនប់និងអាងស្តុកទឹកក៏គ្មានបញ្ហាឡើយ។" នេះជាសេចក្តីថ្លែងការណ៍មួយដ៏គួរឲ្យចាប់អារម្មណ៍។ ខៀវ សំផន មានឆន្ទៈទទួលយកការបូជាមនុស្សដែលចំបាច់សម្រាប់ការកសាង

ទំនប់តែមួយខែ ទោះបីជាទំនប់ទាំងនោះ ត្រូវចំណាយពេលក្នុងការកសាងរហូតដល់៥ឆ្នាំក៏ដោយ គាត់ និងមេដឹកនាំបក្សដទៃទៀត មិនមានការរួញរាក្នុងការកេងប្រវ័ញ្ចនិងរំលោភបំពានកម្លាំងរបស់កម្ពុជា សម្រាប់ការចំណេញក្នុងរយៈពេលខ្លី។ សម្រាប់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ការឈឺចាប់របស់ប្រជាជនគ្មានបញ្ហាទេ។

*ស្លាយ*៨១៖ ខៀវ សំផន បានបញ្ចប់សុន្ទរកថាខែមេសា ឆ្នាំ១៩៧៧ របស់គាត់ត្រឹមការនិយាយអំពីការចោទ -- ពីការប្រកាន់ជំហរអំពាវនាវឲ្យប្រជាជនបន្តធ្វើការឲ្យកាន់តែខ្លាំងក្លាថែមទៀត ដើម្បីបំពេញ ឬបំពេញឲ្យបានលើស ផែនការបង្កបង្កើនផលឆ្នាំ១៩៧៧ របស់បក្ស។

លោកប្រធាន លោក លោកស្រីចៅក្រម សុន្ទរកថានេះឆ្លុះបញ្ចាំងពីអ្វីដែល ខៀវ សំផន, នួន ជា និងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀតចង់បាន អ្វីដែលពួកគេបានធ្វើផែនការ និងអ្វីដែលពួកគេបានបង្គាប់បញ្ជាឲ្យសាងសង់ទំនប់ឲ្យបានឆាប់រហ័សជាងនរណាៗទាំងអស់ ដែលធ្លាប់ធ្វើបានកន្លងមក ទោះជាត្រូវចំណាយមនុស្សប៉ុន្មាននាក់ក៏ដោយ។ ដូចអតីតអនុប្រធានកងចល័តតំបន់៥ បាននិយាយថា៖ "យើងក្តាប់ចល័តដូចតែយើងក្តាប់ទ័ត យើងឲ្យឈ្នះប៉ុន្មានខែឲ្យដាច់ៗ យើងប្តេជ្ញា។ ហើយយើងដឹកនាំកម្លាំងធ្វើម៉េចឲ្យរួច អ្នកឯងធ្វើមិនរួចគឺមិនបាន បានប្រជាជនត្រូវទទួលការលំបាកនោះខ្លាំងដែរ។"

[១០:៥៦:១២]

អ្វីដែលជាបទពិសោធន៍របស់កម្មករនៅទំនប់១មករា និងត្រពាំងថ្ម គឺជាលទ្ធផលផ្ទាល់នៃសេចក្តីសម្រេចចិត្តផែនការ និងការបញ្ជារបស់មេដឹកនាំមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដូចបានរៀបរាប់នៅក្នុងសុន្ទរកថានេះដោយ ខៀវ សំផន។ ឧទាហរណ៍ -- សូមទោស ឧក្រិដ្ឋកម្មដែលធ្វើឲ្យប្រជាជនរងគ្រោះ មិនមែនបណ្តាលមកពីភាពលើសហួសកំណត់ ឬការខកខានរបស់មេដឹកនាំតាមមូលដ្ឋាននោះទេ។ ឧក្រិដ្ឋកម្មទាំងនោះ គឺជាលទ្ធផលដែលកើតចេញពីមេដឹកនាំនៅភ្នំពេញ ដែលមានបំណងចង់ធ្វើឲ្យទៅជាទាសករ ដែលបានដកហូតសេរីភាពជាមូលដ្ឋានរបស់ប្រជាជន បង្ខំពួកគាត់ឲ្យជាប់ទាក់ទងទៅនឹងពលកម្មពិបាកយ៉ាងខ្លាំង នៅក្នុងលក្ខខណ្ឌអមនុស្សធម៌បំផុត ហើយនិងយកអាយុជីវិតរបស់ពួកគាត់ក្នុងករណីចាំបាច់ ដើម្បីសម្រេចបាននូវគោលបំណងរបស់បក្ស។

លោកប្រធាន លោក លោកស្រីចៅក្រម ធ្លាប់បានស្តាប់សក្ខីកម្មរបស់អតីតកម្មករ និងកម្មាភិបាលចំនួន១៣នាក់ ដែលមកពីការដ្ឋានទំនប់១មករារួចមកហើយ។ កម្មករប្រមាណជាង៣០.០០០នាក់ នៅការដ្ឋាននេះ រួមទាំងក្មេងៗផង ដូចជាដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា ដែលគាត់បានផ្តល់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សក្ខីកម្មថា គាត់មានអាយុ១២ឆ្នាំប៉ុណ្ណោះនៅពេលដែលគាត់បានធ្វើការសាងសង់នៅទំនប់នោះ។ ក្មេងៗ នៅការដ្ឋាននេះបានធ្វើការដូចជាមនុស្សពេញវ័យដូច្នេះដែរ គឺរែកដី។ ហើយការប្រើពលកម្មកុមារ ត្រូវបានគេដឹង និងត្រូវបានគេយល់ព្រមដោយមេដឹកនាំកំពូលរបស់បក្សកុម្មុយនីស្តកម្ពុជា។ បទឧទ្ទេសនាម នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ដូចដែលលោកប្រធាន លោក លោកស្រីចៅក្រមធ្លាប់បានដឹងពីមុនរួចមកហើយថា ខៀវ សំផន បានអបអរសាទរនូវការប្រើប្រាស់ពលកម្មកុមារនេះ ដោយបានថ្លែងថា៖ “កូនក្មេងរបស់កម្ពុជាសប្បាយនឹងរើសដីធម្មជាតិ ជួយកសាងទំនប់ និងខឿនទំនប់ការពារទឹក ជីកអាងស្តុកទឹក និងជីកប្រឡាយ។” ហើយក្មួយរបស់ ប៉ុល ពត ឈ្មោះ សេង លីថេង បានផ្តល់សក្ខីកម្មនៅក្នុងសវនាការនេះថា ក្មេងៗត្រូវបានគេឃើញធ្វើការនៅការដ្ឋានទំនប់១មករា នៅពេលដែលគាត់បានទៅធ្វើទស្សនកិច្ចនៅទីនោះជាមួយនឹង ប៉ុល ពត។

លោក លោកស្រីចៅក្រម សាក្សីនានាដែលបានផ្តល់សក្ខីកម្មអំពីទំនប់១មករា បានរៀបរាប់អំពីការធ្វើឲ្យទៅជាទាសករក្នុងលក្ខខណ្ឌអមនុស្សធម៌យ៉ាងពិតប្រាកដ។ នោះដូចគ្នាបេះបិទទៅនឹងបទពិសោធន៍នានារបស់កម្មករនៅត្រពាំងថ្ម ដូចគ្នាទៅនឹងត្រពាំងថ្មដែរ កម្មករបានចាប់ផ្តើមធ្វើការមុនថ្ងៃរះ ហើយកងភាគច្រើនបានធ្វើការដល់ម៉ោង១០, ១១យប់។ ដូចដែលលោក លោកស្រីចៅក្រមបានស្តាប់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩១៥ *(ស៊ីក)* ថា៖ “ព្រោះអីមកដល់ហ្នឹង វាៗសឹងថាម៉ោងប្រហែលជាកណ្តាលអធ្រាត្រហើយ ខ្ញុំពុំបានធ្វើអ្វីកើតទៀតទេ មានតែដាក់ខ្លួនឃ្លីបភ្លឹបទៅហើយមិនដឹងថាម៉េច ដូចអារម្មណ៍មួយថា មិនទាន់បានគេងហ្នឹងឲ្យបានស្ងប់អ្វីមួយផង ស្រាប់តែពួកញ្ញែស្រែកទៀតហើយ។ កម្មករចំនួនកំណត់អាចម៍ដីចាប់ពី១ ទៅ ៤ម៉ែត្រគូប ដែលពួកគេត្រូវរែកដោយទម្ងន់៣០ទៅ៤០ -- ៣០គីឡូក្រាម ពីបាតប្រឡាយទៅខ្នងទំនប់។ អ្នកដែលឈឺញឹកញាប់ ឬត្រូវបានគេកំណត់ថាខ្ជិល ឬក៏មិនអាចបំពេញតាមចំនួនកំណត់បាន ត្រូវទទួលទណ្ឌកម្ម។” ដូចដែលបានផ្តល់ដោយ អ៊ុត សេង ថាកម្មករខ្លះ ត្រូវបានដាក់ទណ្ឌកម្មដោយការចាត់តាំងឲ្យទៅរកកងពិសេស ដែលត្រូវធ្វើការច្រើនម៉ោង ទទួលបានរបបអាហារតិចជាងមុន និងដែលក្នុងកងនោះពួកគេត្រូវបានវាយរំពាត់។ ដូចត្រពាំងថ្មដែរ កម្មករនៅទំនប់១មករា ទទួលបានអាហារបរិភោគស្ដួចស្ដើង។ ជាធម្មតាមានតែបបររាវ ឬសម្លទឹករាវៗ ភាគច្រើនស្គមស្គាំង ឬហើមខ្លួន ពួកគេឈឺជាប្រចាំ ដោយជំងឺគ្រុន រាកមួលគ្រុនចាញ់ ឬអាសន្នរោគ ប៉ុន្តែទទួលបានតែថ្នាំអាចម៍ទន្សាយតែប៉ុណ្ណោះ និងមិនមានថ្នាំសង្កូវមានប្រសិទ្ធភាពនោះឡើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:០០:៥៧]

កូនប្រុសរបស់លេខាភូមិភាគ កែ ពក បានរៀបរាប់នៅក្នុងការស្តាប់ចម្លើយមួយជាមួយនឹងសហចៅក្រមស៊ើបអង្កេត មុនពេលមរណភាពរបស់គាត់ថា បានឃើញមនុស្សឈឺនៅការដ្ឋាននេះ និងបានទទួលស្គាល់ថា អ្នកខ្លះបានស្លាប់ដោយសារការខ្វះថ្នាំសង្កូវ។ អតីតអ្នកមើលការខុសត្រូវទីតាំងឈ្មោះ អៀង ឆាំ ក៏បានទទួលស្គាល់ផងដែរថា មនុស្សបានស្លាប់ដោយសារតែអាហារមិនគ្រប់គ្រាន់ និងកង្វះខាតអនាម័យ និងគ្រូពេទ្យ ដែលមានការបណ្តុះបណ្តាល។

ដូចគ្នាទៅនឹងត្រពាំងថ្មដែរ អនាម័យនៅទំនប់១មករា មិនមានអត្ថិភាពនោះទេ ហើយសត្វរុយមាននៅគ្រប់ទីកន្លែង។ លេខាស្រុក ស៊ូ សឿន បានសារភាពថា មិនមានបង្គន់ និងថាកម្មកររាប់ម៉ឺននាក់បត់ជើងតាមព្រៃតាមផ្សៃ។ អតីតកម្មករឈ្មោះ អ៊ុន រ៉ន បានផ្តល់សក្ខីកម្មថា រាងកាយរបស់គាត់ ពេលខ្លះកើតចៃ។ ហើយ ហ៊ុន សិត្ថានី បានរៀបរាប់ថា៖ "សម្លមួយវែកណា ដែលពួកគេបរិភោគមានសត្វរុយជាច្រើន"។ កែ អ៊ុន ដែលជាក្មួយប្រុស និងជាអ្នកបើកឡានរបស់លេខាភូមិភាគ កែ ពក បានរៀបរាប់ដូចខាងក្រោម នូវអ្វីដែលគាត់បានឃើញ នៅពេលគាត់បានបើកឡានដឹកពូរបស់គាត់ទៅកាន់ការដ្ឋាននោះថា៖ "ពេលហ្នឹងមានមនុស្សប្រហែលរាប់ម៉ឺននាក់កំពុងតែធ្វើការ។ ពួកគេធ្វើការងារយ៉ាងវេទនាពិសេសស្រីៗនៅពេលមានរដូវ គ្មានទឹកសម្អាតខ្លួនទេ អ្នកខ្លះមានរុយរោមគូទ។ នៅការដ្ឋានមានរុយច្រើនណាស់ ដូចជាឃ្មុំយ៉ាងអ៊ីចឹង។" នេះគឺជាអ្វីដែលអ្នកបើកបរម្នាក់បានឃើញ នៅពេលដែលគាត់បានមកកាន់ការដ្ឋាននេះ ហើយវាក៏ជាអ្វីដែល នួន ជា និងមេដឹកនាំបក្សផ្សេងទៀត ដែលបានទៅមើលនៅទីតាំងនោះបានឃើញផងដែរ។ អ្នកមិនអាចលាក់បាំង -- អ្នកមិនអាចលាក់បាំងសត្វរុយរាប់ម៉ឺនក្បាលនោះបានទេ។ អ្នកមិនអាចលាក់បាំងក្លិនចេញមកពីការបន្ទោបង់នៅលើដីរបស់កម្មករ៣០.០០០នាក់នៅជុំវិញការដ្ឋាននោះទេ។ ក្តីអាម៉ាស់ជាក់ស្តែង ដែលកម្មករជាស្ត្រីបានប្រឈមមុខនោះ ត្រូវបានផ្តល់សក្ខីកម្មបញ្ជាក់ដោយប្រភពជាច្រើន *ស្លាយ៨៤* រួមមាន ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ដែលបានរៀបរាប់ពីរបៀបដែលគាត់ និងកម្មករផ្សេងទៀតនៅទំនប់១មករា ត្រូវបានគេប្រព្រឹត្តមកលើក្នុងរូបភាពដូចវត្ថុ ជាជាងលក្ខណៈជាមនុស្ស។ "មានគេធ្វើបាបមិត្តៗពួកខ្ញុំនឹងភ្នែក ដោយសារការឈឺ គ្នាឈឺ សុំឈប់ គេមិនឲ្យឈប់។ គ្នាថា គ្នារាក គ្នាឈឺពោះ គេមិនឲ្យឈប់ទេ ប្រាប់ថា ខ្ញុំវាឈឺមែន តមាត់គេ គេវ៉ៃ នៅនឹងភ្នែកនាងខ្ញុំ។ ដល់អ៊ីចឹងនាងខ្ញុំមិនហ៊ាន ទោះបីឈឺជាំ ក៏សុខចិត្តទ្រាំ តែពួកយើងមិនហ៊ានមើលដូចជាលួចតែអាណិតក្នុងចិត្ត។ ដូច្នេះទិដ្ឋភាពទាំងអស់នេះ ខ្ញុំខំប្រឹង ខ្ញុំមិនហ៊ានឈប់។ ទោះបីនារីៗត្រូវ

តែមានរដូវ -- ត្រូវតែមានរដូវ មានអីឈឺពោះ ក៏មិនដែលបានឈប់ ហើយក៏គ្មានស្អីជាអនាម័យ។ យើងរស់ដូចសត្វដូចធាតុ។”

[១១:០៤:២២]

ដូចគ្នាទៅនឹងការដ្ឋានត្រពាំងថ្ម និងការដ្ឋាន និងសហករណ៍ផ្សេងទៀតនៃកម្ពុជាប្រជាធិបតេយ្យ កម្មករនៅទំនប់១មករា ត្រូវបានធ្វើការឲ្យទៅ -- ឲ្យធ្វើទៅជាទាសករ ពួកគេមានជម្រើសក្នុងការធ្វើការនៅទីនោះទេ ហើយរាល់ទិដ្ឋភាពនៃជីវិតរបស់ពួកគេ ត្រូវបានត្រួតត្រាទាំងស្រុងដោយបក្ស។ ពួកគេមិនមានសេរីចាកចេញពីការដ្ឋាន ឬសូម្បីតែដើរហើរជុំវិញនោះដោយសេរី។ ដូចលោក លោកស្រីចៅក្រមបានឮពីសាក្សីនានា ដែលបានធ្វើការនៅការដ្ឋាននេះ និងពីអ្នកទស្សនាដូចជា ក្មួយប្រុសរបស់ ប៉ុល ពត ឈ្មោះ សេង លីថេង ថាឈ្លប និង យុទ្ធជនកាន់កាំភ្លើងវែងម៉ាកអា.កា ដើរល្បាតការដ្ឋានដើម្បីការពារកុំឲ្យកម្មករគេចវេះពីការងារ ឬរត់គេច។ អ៊ុំ ជី ដែលជាប្រធានកងចល័តមានកម្មករ៥០០នាក់ បានផ្តល់សក្ខីកម្មអំពីការប្រជុំដែលគាត់បានចូលរួម ដែលក្នុងនោះមេដឹកនាំតំបន់៤២ និងស្រុកបារាយណ៍ បានបញ្ជាក់យ៉ាងច្បាស់អំពីជោគវាសនារបស់កម្មករ និងការអនុវត្តតាមផែនការរបស់អង្គការ មិនអាចអនុវត្តតាមផែនការរបស់អង្គការ។ បើអ្នកណាមិនគោរពបញ្ជា គឺថាគេទុកជាខ្មាំង សម័យហ្នឹងគឺជោគវាសនាទាំងអស់ហ្នឹងដែលបានកើតឡើង គឺថាគេនឹងកម្ទេច ពីព្រោះស្ទះនឹងចលនារបស់គេកសាងសម័យនុ៎ង។ លោក លោកស្រីចៅក្រម បានស្តាប់លេខាស្រុកឈ្មោះ ស៊ូ សឿន ទទួលស្គាល់ថា គាត់បានទទួលរបាយការណ៍ពីមេឃុំទាំងអស់របស់គាត់ ទាក់ទងនឹងការដែលកម្មករត្រូវបានយកចេញ និងបាត់ខ្លួន។

[១១:០៦:១៤]

ការដ្ឋានបន្ទាប់ ខ្ញុំនឹងលើកឡើងពីការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។ *ស្លាយ៨៧* នេះជាកន្លែងលត់ដំមួយ ប្រើសម្រាប់ដាក់វិន័យ និង លត់ដំទាហានដែលមកពីកងពលឃោធាដែលបានបោសសម្អាត វាត្រូវបានប្រព្រឹត្តដោយកងពល៥០២ នៃកងទ័ពបដិវត្តន៍ និងត្រូវបានបង្កើតឡើងដោយគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា តាមកិច្ចប្រជុំជាច្រើនដែលបានចូលរួមដោយទាំង នួន ជា និង ខៀវ សំផន ក៏ដូចជាការដ្ឋានផ្សេងទៀត ដែលយើងបានពិភាក្សាថ្ងៃនេះដែរ វាត្រូវបានទស្សនកិច្ចដោយមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាជាច្រើន រួមមាន ខៀវ សំផន និងសមាជិកអចិន្ត្រៃយ៍ដទៃទៀត។

អង្គជំនុំជម្រះបានស្ដាប់សក្ខីកម្មសាក្សី និង ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន១០នាក់ ទាក់ទងនឹងលក្ខខណ្ឌការងារនៅកន្លែងនេះ ដែលបានបង្កើតឡើងដោយគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា។ កម្មករដែលត្រូវបានបញ្ជូនទៅទីនោះ ដើម្បីលត់ដំ ជាចម្បងគឺទាហានដែលមកពីកងពល ឬតំបន់នានាដែលមិនទុកចិត្តដោយអ្នកដឹកនាំបក្ស ដូចជាកងពល៣១០ និង៤៥០នៃកងទ័ពជិវត្តន៍កម្ពុជា និងភូមិភាគឧត្តរ និងភូមិបូព៌ា។ ពួកគេ គឺជាបុគ្គលដែលត្រូវបានចោទប្រកាន់ថា មានប្រវត្តិរូបមិនល្អ ឬមានជាប់ទាក់ទងនឹងកម្មាភិបាលដែលត្រូវបានចាប់ខ្លួន។ សាក្សី កែវ គីន ត្រូវបានបញ្ជូនឲ្យទៅកាន់កន្លែងនេះ ពីព្រោះឪពុករបស់គាត់ធ្លាប់ជាអនុប្រធានឃុំនៃរបបមុន ប្រជាជនដែលត្រូវបានបង្ខំឲ្យធ្វើការនៅទីនោះ រួមមានទាំងទាហានពិការ ឬរបួសផងដែរ ដូចជា សាក្សីសវនាការ កែវ លឿ ផងដែរ។

[១១:០៨:១២]

កម្មករនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង បានសាងសង់ផ្លូវយន្តហោះរត់ចំនួនពីរខ្សែ ដែលមានបណ្ដោយ២.៤គីឡូម៉ែត្រ ហើយមានរូងបញ្ជាការដ្ឋានក្រោមដីដ៏ធំ និងបន្ទប់ជាច្រើន ដែលត្រូវបានសាងសង់ឡើងដោយការបំផ្ទុះចំហៀងភ្នំ។ ការងារចាប់ផ្ដើមពីព្រលឹម ហើយបន្តទៅដល់យប់ ដោយមានភ្លើងដាក់រាយនៅតាមកន្លែងនោះ។ មិនមានថ្ងៃឈប់សម្រាកទេ។ ម្ហូបអាហារដែលបានផ្ដល់ឲ្យតែពីរដងក្នុង១ថ្ងៃនោះ គឺមិនគ្រប់គ្រាន់សម្រាប់កម្មកររស់នៅបានទេ បានក្លាយទៅជាស្គមស្គាំង និងឈឺ។ ជាការផ្ទុយគ្នាទាំងអស់ អ្នកបច្ចេកទេសចិននៅកន្លែង មានម្ហូបគេបរិបូណ៌ រួមមាន នំប៉ុង និងមីគាវ ហើយជប់លៀងប្រចាំសប្ដាហ៍ ដែលពួកគេផឹកស្រាបៀរ ដូចដែលលោកប្រធាន លោក លោកស្រីចៅក្រម បានឮពី ចាន់ ម៉ន ជាអ្នកជំនួយការឲ្យអ្នកតម្រួតពិនិត្យទីកន្លែងនោះ។

សាក្សីនានាដែលបានផ្ដល់សក្ខីកម្មចំពោះមុខលោក លោកស្រីចៅក្រម បានរៀបរាប់អំពីការនឿយហត់អស់កម្លាំងពីការងារដែលពួកគេត្រូវបានបង្ខំឲ្យធ្វើ នៅទីតាំងវាលយន្តហោះនេះ។ កែវ លឿ បានផ្ដល់សក្ខីកម្ម ខ្ញុំសូមដកស្រង់៖ “ខ្ញុំបាទ ទទួលអារម្មណ៍ថា ខ្ញុំបាទហាក់ដូចជាមនុស្សស្លាប់នៅពេលនោះ អត់មានសង្ឃឹមថា បានរស់រានមានជីវិតទៅជួបអ្នកមានគុណរបស់ខ្ញុំបានទេ។ នឹកឃើញថា ថ្ងៃណាមួយហ្នឹង គឺត្រូវស្លាប់ដោយសារការងារពលកម្ម ឬដោយអាហារមិនគ្រប់គ្រាន់។” គាត់បានផ្ដល់សក្ខីកម្មថា៖ “ប្រជាជនត្រូវតែបន្តធ្វើការ សូម្បីតែពេលឈឺ បើមិនដូច្នេះទេ ពួកគេចោទថាខ្ជិល” និងបានរៀបរាប់ថា បានឃើញកម្មករជាច្រើនដួលសន្លប់។

ដើមបណ្ដឹងរដ្ឋប្បវេណី គង់ សៀក ដែលជាកម្មការិនីម្នាក់ នៅការដ្ឋាននេះ បានផ្ដល់ភស្តុតាងដូច

តទៅ ជូនលោកប្រធាន លោក លោកស្រីចៅក្រម កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥។ “យើងចេះតែខំប្រឹងទៅ ជីកមិនប៉ានឈប់ទេ ប្រឹងប្រែង ទោះពងដៃ ក៏នៅតែខំប្រឹង ប្រឹងធ្វើ ប្រឹងលើក។” គាត់ក៏បានរៀបរាប់អំពីស្ថានភាពផ្សេងៗ និងរូបរាងរបស់គាត់ និងកម្មករផ្សេងៗទៀត ខ្ញុំសូមដកស្រង់៖ “យើងគឺសុទ្ធតែស្គម ហើយនៅតែក្បាល ហើយនិងក្បាលជង្គង់ទេ។ ដើរទ្រេតទ្រោតហើយ ហើយការងារគឺចេះតែប្រឹងខ្លាចស្លាប់ គឺខំនាំគ្នាចេះតែធ្វើហើយ ធ្វើទៅហើយនោះ ទោះបីបែកដៃ បែកជើង ទោះបីគ្រុនឈឺបន្តិចបន្តួច ក៏អត់ប៉ានដែរ អត់ប៉ានឈប់ទេ ហើយខ្លួនស្គម គឺគ្មានកម្លាំងទេ។ ទាំងគេទាំងខ្ញុំ គឺគ្មានកម្លាំងទេ ប៉ុនចេះតែទៅ។”

កម្មការិនីម្នាក់ទៀត នៅព្រលានយន្តហោះនេះ គឺដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ក៏បានរៀបរាប់ពីស្ថានភាពដ៏អាក្រក់នៅទីតាំងការដ្ឋាននេះដែរ។ ពីរបៀបដែលរូបគាត់ និងកម្មករ កម្មការិនីដទៃទៀត គឺចៃកើតពេញក្បាលទាំងអស់ និងពីរបៀបដែលពួកគាត់ត្រូវផឹកទឹកមិនស្អាតពីថ្លុកទឹកដែលពួកគេងូត។

លោក លោកស្រីចៅក្រម ក៏បានឮផងដែរ អំពីការងារដ៏គ្រោះថ្នាក់ដែលគេបានប្រើ ការកេងប្រវ័ញ្ចចំពោះអ្នកដែលគេដាក់ទិសដៅឲ្យបំផ្ទុះរូងក្រោមដីនៃផ្នែកខាងជើងភ្នំតារាជ។ សាក្សីបួននាក់បានផ្តល់សក្ខីកម្មអំពីកម្មកររងរបួស ឬស្លាប់ដោយអំបែងថ្មខ្ទាតត្រូវ ដោយសារពួកគេមិនអាចរត់ទាន់អំបែងផ្ទុះថ្មដែលខ្ទាតមកក្រោយការផ្ទុះ។ ហ៊ីម ហន បានផ្តល់សក្ខីកម្មថា ដោយសារប្រភេទការងារដ៏គ្រោះថ្នាក់ ប្រធានការដ្ឋានចាត់កម្លាំងពីភូមិភាគបូព៌ា ហើយចាត់ចែងលើការបំផ្ទុះនេះ។ ពេលសួរពីក្រុមមេធាវីការពារក្តី គាត់បាននិយាយថា *ស្លាយ*៩១៖ “នេះជាវិធីសម្លាប់មួយ ដែលមិនអាចប្រកែកបានហើយត្រូវតែធ្វើ។ ឆ្នូននេះ មិនងាយនឹងទៅដាក់ដោយងាយៗនោះទេ តែពេលនេះ កម្លាំងទាំងនេះ ស្លាប់ប៉ុន្មាន ក៏គេអត់ស្តាយដែរ អ៊ីចឹងការផ្ទុះក្តី អីក្តីហ្នឹងគឺកម្មវិធីធ្វើហ្នឹង វាទាន់ហន់។ ខ្សែបញ្ឆេះខ្លី ថ្មផ្ទុះ ឆ្នូនផ្ទុះភ្លាម និងអំបែងត្រូវធ្លាក់មកត្រូវមនុស្សហ្នឹងស្លាប់ ឬក៏របួសជាហូរហែមក។ ខ្ញុំ អានេះ ខ្ញុំមិនបានធ្វើផ្ទាល់ដៃទេ ប៉ុន្តែខ្ញុំគិតថា កម្មវិធីនេះ សកម្មភាពនេះ ដើម្បីសម្លាប់មនុស្សទេ។”

[១១:១៣:១៧]

ភស្តុតាងចំពោះមុខលោក លោកស្រីចៅក្រម ក៏បញ្ជាក់អំពីការធ្វើឲ្យទៅជាទាសករនៃកម្មករកម្មការី នៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ដែលពួកគាត់គ្មានសិទ្ធិសេរីភាពក្នុងការចាកចេញពីទីតាំងការដ្ឋាននេះឡើយ និងត្រូវបានតាមដានជាប្រចាំ ដោយកងអង្គភាពយាមកាម។ ហ៊ីម ហន បានផ្តល់

សក្ខីកម្មថា "កម្មករ កម្មការី បើកំណត់ឲ្យនៅកន្លែងណា គឺឲ្យនៅកន្លែងហ្នឹង"។ និងថាការដ្ឋាននេះ បើតាមសម្ដីគាត់ គឺជាគុកឥតជញ្ជាំង។ គាត់ក៏បានរៀបរាប់ផងដែរ អំពីការក្ដាប់យ៉ាងណែនដែលមេដឹកនាំការដ្ឋាននេះ បានធ្វើ ដោយគាត់និយាយថា ខ្ញុំសូមដកស្រង់៖ "គេកំណត់យើងថា ជាជនក្បត់ ហើយគេត្រួតត្រា ឲ្យធ្វើអី គឺត្រូវឲ្យហើយ បើហ៊ានតថ្លៃ យើងមានទោស ឬបាត់ខ្លួន។ ប៉ុន្តែកងខ្ញុំ ទាំងអស់គ្នាដែលនៅជិតគ្នានុ៎ង មិនដែលពីណាហ៊ានតថ្លៃ ឬក៏បញ្ជាក់ដោយប្រការណាមួយទេ។ ប្រើអី គឺទៅធ្វើហ្នឹងហើយ ធ្វើមិនរួច ធ្វើល្ងាចទៀត ល្ងាចមិនរួច ធ្វើយប់ទៀត ធ្វើទាល់តែរួចការងារនុ៎ង។"

លោក លោកស្រីចៅក្រម ភស្ដុតាងមួយចំនួនក្នុងចំណោមភស្ដុតាងដ៏ខ្លាំងក្លា ឬប្រកបដោយប្រសិទ្ធភាពបំផុត ដែលបញ្ជាក់ថាប្រជាជនត្រូវបានធ្វើឲ្យទៅជាទាសករនៅតាមទីតាំងទាំងអស់នេះ គឺជាអ្វីដែលបានកើតឡើងចំពោះអ្នកដែលបានព្យាយាមរត់គេច ឬគេចខ្លួន។ ក្នុងករណីទីតាំងព្រលានយន្តហោះខេត្តកំពង់ឆ្នាំងនេះវិញ យើងមានឯកសារនៅសេសសល់ ដែលឆ្លើយសំណួរនោះ និងបញ្ជាក់ហួសពីវិមតិសង្ស័យលើសក្ខីកម្មដែលលោក លោកស្រីចៅក្រម បានស្ដាប់ពីសាក្សីនានា។ *ស្លាយ*៩៤ អ៊ុំ! សូមទោស ៩៨, ៩៤ដល់៩៨។ នេះគឺជារបាយការណ៍ប្រចាំខែរបស់ភូមិភាគបស្ចិមសម្រាប់ខែកក្កដា ឆ្នាំ១៩៧៨ ដកស្រង់៖ "វារៀបរាប់ពីរបៀបដែលកងទ័ពតំបន់បានរកឃើញខ្មាំងបីនាក់ ដែលបានព្យាយាមរត់គេចពីទីតាំងព្រលានយន្តហោះខេត្តកំពង់ឆ្នាំង នៅម៉ោងមួយ សាមសិបនាទីព្រឹក ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៧៨។ ភូមិភាគបានរាយការណ៍ថា កងទ័ពនេះបានបាញ់កម្មករទាំងនោះ និងបានចាប់ខ្លួនពួកគេ និងថាកម្មករម្នាក់ក្នុងចំណោមកម្មករដែលត្រូវបានចាប់ខ្លួននោះ ត្រូវបានបញ្ជូនទៅកន្លែងអប់រំ ហើយសួរចម្លើយបន្តទៀត។" របាយការណ៍ភូមិភាគបស្ចិមពីខែមុន មានផ្នែកទាំងមូលមានចំណងជើងថា "សកម្មភាពលួចរត់ចេញពីសហករណ៍"។

[១១:១៦:១០]

*ស្លាយ*៩៩ ហើយនេះគឺជារបាយការណ៍ខែឧសភា ឆ្នាំ១៩៧៥ ពីភូមិភាគពាយ័ព្យទៅកាន់អង្គការទាក់ទងនឹងតំបន់៥ តំបន់តែមួយដែលតំបន់ត្រពាំងថ្មមានទីតាំងស្ថិតនៅ។ វារៀបរាប់អំពីវិធានការដែលបានធ្វើប្រឆាំងនឹងប្រជាជនប្រាំបួននាក់ ដែលបានលួចរត់ពីសហករណ៍ក្នុងតំបន់នោះ។ "នៅតំបន់៥មានខ្មាំងប្រាំបួននាក់រត់ចូលព្រៃ ប្រុសប្រាំមួយ ស្រីបី បានរត់ចូលព្រៃនៅម្ដុំព្រៃដូនខៀវ ខាងត្បូងកំបោរ ពួកនេះដែលរត់ចេញពីកងចល័ត ហើយកំពុងដេញតាមរាល់ថ្ងៃ បានជួបវាម្ដងបាញ់ជ្រុះកាំមែល អង្ករ ត្រីងៀត ឪឡឹក នៅកន្លែងវាសម្រាក តែមិនត្រូវវា ហើយកំពុងដេញតាមវាតទៀត។ ក្រៅពីនេះមានចលនា

រត់ទៅថៃខ្លះដែរ។ តែបើប្រៀបធៀបពីខែមុន ឃើញថាមានចំនួនតិចជាងមុនច្រើនណាស់ ហើយអ្នកដែលរត់ច្រើន ៗកម្ទេចបានផង។" ភូមិភាគផ្សេងគ្នាក្នុងឆ្នាំខុសៗគ្នា ប៉ុន្តែការឆ្លើយតបដូចគ្នាបេះបិទទៅនឹងអ្នកដែលបានព្យាយាមរត់គេចពីសហករណ៍ ឬការដ្ឋានរបស់ពួកគេ បានរាយការណ៍ទៅកាន់មេដឹកមជ្ឈិមបក្សនៅភ្នំពេញ។ ប្រសិនបើសហករណ៍ និងការដ្ឋានទាំងឡាយមិនមែនជាគុកឥតជញ្ជាំង ដូចដែលមេធាវីការពារក្តីបានអះអាងនោះ ហេតុអ្វីបានជាអ្នកដែលព្យាយាមចាកចេញទាំងនោះ ត្រូវបានតាមប្រមាញ់ បាញ់សម្លាប់ និងកម្ទេចចោលទៅវិញ។

លោកប្រធាន លោក លោកស្រីចៅក្រម បានស្តាប់សក្ខីកម្មអំពីកម្មករជាច្រើននៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ដែលត្រូវបានចាប់ខ្លួននិងបញ្ជូនចេញពីទីតាំងនោះ កែវ គីន ដែលបានធ្វើការនៅជិតមន្ទីររបស់អ្នកត្រួតពិនិត្យការដ្ឋានឈ្មោះ ល្វៃ បានឃើញការចាប់ខ្លួនទាំងនោះដោយផ្ទាល់ភ្នែក គាត់បានរៀបរាប់អំពីរបៀបដែលកម្មករត្រូវបានហៅទៅកាន់មន្ទីររបស់ ល្វៃ ត្រូវបានចងដោយអ្នកយាម ដោយភ្ជង់នឹងកាំភ្លើង បោះដាក់ឡានរបស់កងពល ហើយបានបើកចេញពីទីតាំងនោះបាត់ទៅ។ ការចាប់ខ្លួនទាំងនេះ បានកើតឡើងខណៈដែល ល្វៃ ដែលជាអនុបញ្ជាការកងពលលេខ៥០២ មានវត្តមាននៅទីនោះ។ កម្មករម្នាក់ក្នុងចំណោមកម្មករទាំងនោះត្រូវបានចាប់ខ្លួន និងបញ្ជូនចេញពីព្រលានយន្តហោះខេត្តកំពង់ឆ្នាំងនោះគឺឈ្មោះ យឹម សំអុល ហៅ ញ៉ា ដែលបានចូលមន្ទីរស-២១ នៅថ្ងៃ១៩ ខែធ្នូ ឆ្នាំ១៩៧៨។ គាត់មានលេខរៀង១៤.៦៩៣ នៅក្នុងបញ្ជីឈ្មោះអ្នកទោស ស-២១ របស់សហចៅក្រមស៊ើបអង្កេត ហើយប្រវត្តិរូបស-២១របស់គាត់ បញ្ជាក់ថា គាត់ត្រូវបានបញ្ជូនមកពីព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។

[១១:១៩:២៥]

ភស្តុតាងពាក់ព័ន្ធនឹងសហករណ៍ស្រុកត្រាំកក់។ *ស្លាយ*លេខ១០២ ត្រាំកក់ជាស្រុកមួយក្នុងចំណោមស្រុកទាំងបី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែល នួន ជា និង ខៀវ សំផន និងគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានទទួលស្គាល់ និងកោតសរសើរថាជាស្រុកគំរូ និងជាឧទាហរណ៍សម្រាប់ស្រុកទាំងអស់ផ្សេងទៀត។ *ស្លាយ*១០៤ ក្នុងឆ្នាំ១៩៧៧ គណៈមជ្ឈិមបានប្រគល់រង្វាន់ដល់ស្រុកត្រាំកក់ នូវទង់ក្រហមកិត្តិយសចំពោះការកសាងសង្គមនិយម និងបេសកកម្មរបស់បក្ស ដើម្បីសម្រេចបានបីតោនក្នុងមួយហិកតា។ ហើយនៅក្នុងសេចក្តីសម្រេចដែលបានអនុម័តនៅក្នុងសុន្ទរកថាជាច្រើនធ្វើឡើងដោយ ខៀវ សំផន នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ ស្រុកត្រាំកក់ ជាថ្មីម្តងទៀតត្រូវបានលើកឡើងជាឧទាហរណ៍ ឬជាគំរូសម្រាប់កងផលិតនៅទូទាំងប្រទេស។ នៅដើមឆ្នាំ១៩៧៧ នួន ជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

និងខៀវ សំផន បានទស្សនាសហករណ៍ឃុំលាយបូរ ក្នុងស្រុកត្រាំកក់ជាមួយនឹង ប៉ុល ពត និង តាម៉ុក។ ដូចដែលបានផ្តល់សក្ខីកម្មនៅក្នុងសវនាការ ដើមបណ្តឹងរដ្ឋប្បវេណីពីររូបដែលបានបញ្ជាក់ដោយអតីតលេខាស្រុកឈ្មោះ ពេជ្រ ជឹម។

លោកប្រធាន លោក លោកស្រីចៅក្រម បានស្តាប់សក្ខីកម្មអស់រយៈពេល៤ខែ នៅពេលចាប់ផ្តើមដំបូងបង្អស់នៃការជំនុំជម្រះពីប្រជាជន និងកម្មាភិបាលដែលបានរស់នៅក្នុងស្រុកគំរូរបស់បក្សកុម្មុយនីស្តកម្ពុជានេះ។ ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ សក្ខីកម្មនោះបានមកពីប្រជាជនមូលដ្ឋាន ប្រជាជនថ្មី ដែលត្រូវបានបញ្ជូនទៅស្រុកត្រាំកក់ និងត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងសហករណ៍នានារបស់ស្រុកនេះ អតីតមេឃុំចំនួនបីនាក់ កម្មាភិបាលម្នាក់ដែលបានធ្វើការអនុប្រធានមន្ទីរពេទ្យស្រុក អ្នកទោសរស់រានមានជីវិត និងអ្នកយាមមកពីមន្ទីរអប់រំស្រុកក្រាំងតាចាន់ និងអតីតលេខាស្រុកនោះចំនួនពីរនាក់។

[១១:២១:៤០]

លើសនោះទៀត ឯកសារសហកាលរាប់រយមកពីស្រុកត្រាំកក់ គឺជាភស្តុតាងបង្ហាញដែលកត់ត្រាឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងស្រុកនោះ ក្នុងអំឡុងពេលរបបខ្មែរក្រហម និងគាំទ្រសក្ខីកម្មរបស់សាក្សី ចំពោះអ្វីដែលបានកើតឡើងនៅក្នុងស្រុកគំរូនេះ។ នៅក្នុងស្រុកគំរូរបស់បក្សកុម្មុយនីស្តកម្ពុជានេះ បក្សបានអនុវត្តការគ្រប់គ្រងដាច់ខាត លើរាល់ទិដ្ឋភាពទាំងអស់នៃការរស់នៅរបស់ប្រជាជន ការងាររបស់ពួកគាត់ ផ្ទះរបស់ពួកគាត់ អាហាររបស់ពួកគាត់ ជីវិតគ្រួសាររបស់ពួកគាត់ រាល់ការគិត និងការសម្លាប់ ការបន្លាស់ទីរបស់ពួកគាត់ត្រូវបានគ្រប់គ្រងដោយអង្គការ។ នៅក្នុងកំណត់ហេតុដែលបានរក្សាទុកដោយដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី នៅក្នុងអំឡុងពេលរបបនោះ គាត់បានសរសេរថា ៖ “មិនហ៊ានច្រៀង មិនហ៊ានរាំ មិនហ៊ានសើចក្អាកក្អាយ សកម្មភាពដែលយើងធ្វើជាប្រចាំគឺដេក ស៊ី ធ្វើការតែប៉ុណ្ណឹងឯង -- ធ្វើការតែប៉ុណ្ណោះឯង។” ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មថា សូម្បីនៅបន្ទប់ទឹក រូបគាត់ អ្នកផ្សេងទៀតនៅក្នុងកងចល័តរបស់គាត់ ចាំបាច់ត្រូវទទួលការអនុញ្ញាតពីប្រធានកងរបស់ខ្លួន និងត្រូវប្រាប់គាត់ថា នឹងចំណាយពេលអស់ប៉ុន្មាន ដើម្បីធានាដល់ការត្រួតត្រារបស់ពួកគេឲ្យបានដាច់ខាត បក្សកុម្មុយនីស្តកម្ពុជាបានដកហូតនូវទ្រព្យសម្បត្តិឯកជនទាំងអស់ពីប្រជាជន។ ធ្វើអ្វីក៏ដោយ ក៏ត្រូវមានការអនុញ្ញាតពីអង្គការដែរ សូម្បីតែបេះផ្លែស្វាយមួយ ឬចាប់កង្កែបនៅតាមវាលស្រែ។

លោក លោកស្រីចៅក្រមបានឮហើយអំពីវិបាកទាំងឡាយសម្រាប់អ្នកដែលឃ្លាន ហើយហ៊ាន

ទទួលទានអាហារដ៏សម្បូរបែបដែលបានដុះនៅលើទឹកដីនៃប្រទេសនេះ។ ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន បានរៀបរាប់អំពីកូនប្រុសរបស់គាត់ដែលទើបតែមានអាយុ១៣ឆ្នាំ ត្រូវបានគេចាប់ចង និងយកទៅសម្លាប់ដោយសារតែគេបានលួចដកដំឡូងគេហូប។ បេង បឿន បានផ្តល់សក្ខីកម្មអំពីវាសនារបស់សាច់ថ្លៃរបស់គាត់ម្នាក់ដែលហ៊ានបេះផ្លែដូងមួយផ្លែថា៖ “ខ្ញុំក៏ដើរៗទៅមើលគោ ដេញគោក៏ប្អូនថ្លៃមួយទៀត ដេញគោក៏ប្អូនថ្លៃមួយទៀត ប្អូនថ្លៃខាងប្រពន្ធបង្កើតហ្នឹង ក៏វាឡើងបេះដូង ១ពេលនោះ វាឃើញខ្ញុំក៏បោះដូងឲ្យខ្ញុំមួយ បោះឲ្យមកស្រាប់តែវាចុះដល់ក្រោម មានគេដឹកដៃទៅទៀត។ ដល់ពេលខ្ញុំមកដល់សហករណ៍វិញ បានមើលឃើញទៅ គេចងស្លាបសេកពីក្រោយអូសទាញទៅទាំងថ្ងៃត្រង់។

លោក លោកស្រីចៅក្រមបានឮដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធឹម និងសាក្សីផ្សេងទៀត អំពីរបៀបដែលក្រុមគ្រួសារនានាត្រូវបានបំបែកបំបាក់នៅក្នុងស្រុកគំរូរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយមនុស្សប្រុសត្រូវបានគេយកទៅដាក់នៅក្នុងកងបុរស ប្រពន្ធត្រូវបានគេដាក់ក្នុងកងនារី ចំណែកកូនៗរបស់គេត្រូវបានយកទៅចេញទៅបាត់ ដាក់នៅក្នុងកងកុមារ។ លោក លោកស្រីចៅក្រមបានឮពីកុមារទាំងនោះខ្លះផងដែរគឺ មាស សុខា និង អ៊ឹម វណ្ណៈ ដែលធ្លាប់ត្រូវបានគេវាយពេលគេចាប់បាន ពេលដែលពួកគេកំពុងព្យាយាមរត់ទៅជួបឪពុកម្តាយរបស់ពួកគេ។ នៅក្នុងស្រុកគំរូនេះ ដូចគ្នានឹងការដ្ឋាន និងសហករណ៍ទាំងអស់ដទៃទៀតរបស់កម្ពុជាប្រជាធិបតេយ្យដែរ គឺប្រជាជនត្រូវខិតខំធ្វើការយ៉ាងខ្លាំងចាប់ពីព្រលឹមស្រាងរហូតដល់យប់ និងសូម្បីស្ត្រីមានគភ៌ ក៏ត្រូវបានគេបង្ខំឲ្យធ្វើការងារជាទម្ងន់ដែរ។

*ស្លាយ*លេខ១០១ លោក លោកស្រីចៅក្រម បានឮនៅក្នុងសវនាការនេះពីស្ត្រីនោះ ទាំងនោះមួយចំនួនរួចហើយ រួមទាំង ជាំង ស្រីមុំ ផងដែលបានផ្តល់សក្ខីកម្មដូចខាងក្រោមដែលរៀបរាប់អំពីបទពិសោធន៍របស់គាត់ ខ្ញុំសូមដកស្រង់៖ “មានផ្ទៃពោះពីរបីខែអ៊ីចឹង ខ្ញុំគេឲ្យសហករណ៍ គេឲ្យរើសអាចម៍គោ រែកដីដំបូង អ៊ីចឹងចាក់ស្រែ ចាក់អ៊ីចឹង។ ដើររើសអាចម៍ និងដើរថ្លឹងមួយថ្ងៃបានប៉ុន្មានគីឡូ។ ដើរបានតិចតួចៗ គេកសាងយើង។ ហើយម្យ៉ាង ខ្ញុំហូបបាយវាចាញ់កូន ហូបបាយអត់កើត ឈឺឡើងស្គមអ៊ីចឹងហើយ គេកសាងយើងហើយ គេថា យើងធ្វើសតិអារម្មណ៍ខ្ជិលធ្វើការ។ អ៊ីចឹងខ្ញុំមានអារម្មណ៍មួយពិបាកចិត្តណាស់ ពិបាកចិត្តណាស់។ ខ្ញុំធ្វើការអត់កើត។ ហើយដល់ពេល -- ហើយអាហារអត់គ្រប់គ្រាន់ទៀត។ ធ្វើការម៉ោងបួន ដល់ម៉ោងបួនទៀបភ្លឺ ការងារវេទនាអ៊ីចឹង។”

ដូចនៅតាមតំបន់ដទៃទៀតដែរ របៀបអាហារនៅក្នុងស្រុកត្រាំកក់មិនគ្រប់គ្រាន់ឡើយ ដើម្បីទ្រទ្រង់ជីវិតមនុស្ស។ លោក លោកស្រីចៅក្រម បានឮរួចហើយដែរអំពីការពិតនៃសហករណ៍គំរូនៅ

លាយបបូរ ពីដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡន ដែលគាត់បានពិពណ៌នាអំពីភាពស្រេកឃ្លានរបស់គាត់ ដោយសារតែគេឲ្យតែមួយវែកៗម្នាក់ និងអស់ប៉ុណ្ណឹងឈប់ហើយ និងបានផ្ដល់សក្ខីកម្មថា អាកូនតូចគាត់ហ្នឹងក៏ហូបអត់ឆ្អែត។ ប៊ុន សារឿន បានផ្ដល់សក្ខីកម្មពីរបៀបដែលប្រជាជនត្រូវក្រោកតាំងពីព្រលឹម និងខំធ្វើការយ៉ាងខ្លាំង គឺវាមិនអាចសមនឹងកម្លាំងដែលធ្វើការហ្នឹងទេ។ ជាលទ្ធផល ជំងឺកង្វះខាតអាហារ និងការងារលើសកម្លាំង ធ្វើឲ្យប្រជាជននៅស្រុកត្រាំកក់ធ្លាក់ខ្លួនឈឺ និងនៅពេលប្រជាជនឈឺពួកគេត្រូវបានមេដឹកនាំស្រុកប្រព្រឹត្តចំពោះគេ កាន់តែអាក្រក់ថែមទៀត ដូចដែល ចាន់ ធីម បានរៀបរាប់ដូចតទៅ៖ "គឺអាខ្លះក៏គ្នាឈឺអីចឹងទៅ។ អាក្បាលជង្គង់ត្រម៉ែងត្រម៉ោង ក្បាលជង្គង់ធំជាងភ្លៅទៀត។ ដើរយោងតែអាគ្នាមិនចង់រួចផង បាទ។ ហើយអាខ្លះក៏ឈឺទៅ គេថាឈឺសតិអារម្មណ៍ ឈឺសតិអារម្មណ៍អី? ដល់រួចទៅ គ្នាឈឺពិតប្រាកដ។ ដល់រួចទៅ គេថា យី!ទុកក៏មិនចំណេញ ដកចេញក៏មិនខាត យកទៅបាត់អស់ទៅ។ ពួកគេដែលមិនធ្វើការមិនបានហ្នឹងគឺអាហារ បើតាមដែលខ្ញុំដឹងគឺគេបន្ថយទៀត។ គេថា ឈឺ ហើយត្រូវតែបន្ថយ ឲ្យគ្នាហូបបបររាវហើយហ្នឹងណា។ ហើយបើតាមពិតទៅ គេថាថាយើងអត់មានពលកម្មអី មិនចេញធ្វើការងារអី មិនបាច់ហូបច្រើនទេ ហូបបន្តិចៗបានហើយ។"

[១១:២៩:១០]

លោកប្រធាន លោក លោកស្រីចៅក្រមបានឮផងដែរថា រៀល សន ដែលជាអតីតអនុប្រធានមន្ទីរពេទ្យស្រុកត្រាំកក់ គាត់បានរៀបរាប់ថា ឈឺហើមខ្លួនត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ។ ប្រជាជនខ្វះអាហាររូបត្ថម្ភ និងរាករូស។ គាត់បានផ្ដល់សក្ខីកម្មថា ការស្លាប់ដោយសារការខ្វះអាហាររូបត្ថម្ភកាន់តែអាក្រក់ទៅ។ នៅពេលដែលរបបមួយនេះដើរទៅមុខ ដោយបានថ្លែងថា កាលពីប៉ុន្មានខែមុន ខ្ញុំសូមដកស្រង់៖ "កាប់រណ្ដៅកប់រហូត ម៉ែ្វៗប្អូនដប់ម្ភៃសាមសិបនាក់អីចឹងទៅ។" រៀល សន ក៏បានរៀបរាប់ផងដែរ ពីការប្រជុំមួយជាមួយនឹងគណៈស្រុកដែលគាត់ត្រូវបានសួរថា ហេតុអ្វីបានជាមានមនុស្សឈឺច្រើនម្ល៉េះនៅក្នុងមន្ទីរពេទ្យ? នៅពេលដែលគាត់បានឆ្លើយទៅកាន់មេដឹកបក្សកុម្មុយនីស្តកម្ពុជា អំពីស្រុកគំរូនេះ ពីព្រោះប្រជាជនហូបម្ហូបអាហារមិនគ្រប់គ្រាន់ ហើយពួកគាត់ខ្វះអាហារូបត្ថម្ភ គាត់ត្រូវបានចោទប្រកាន់ថា គាត់វាយប្រហារសហករណ៍ ហើយសំណើរបស់គាត់សុំបង្កើនរបបអាហារត្រូវបានបដិសេធ។ នៅក្នុងស្រុកគំរូរបស់បក្សកុម្មុយនីស្តកម្ពុជានេះ ប្រជាជនជាច្រើនដែលហ៊ានត្អូញត្អែរពីការខ្វះខាតម្ហូបអាហារ ឬលក្ខខណ្ឌការងារពិបាកត្រូវបានចាប់ខ្លួនថាជាខ្មាំង បញ្ជូនទៅមន្ទីរអប់រំ ហើយមិនដែលបានឃើញមុខម្ដងទៀតទេ។ រឿងនេះរាប់ទាំងអ្នកធ្វើការជាមួយគ្នាមួយចំនួនផង ដូចជាអ្នកធ្វើការ

ជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡុន ដែលត្រូវបានចាប់ខ្លួននិងបាត់ខ្លួនតែប៉ុន្មានថ្ងៃបន្ទាប់ពីដំណើរទស្សនកិច្ចរបស់ នួន ជា និង ខៀវ សំផន ទៅកាន់សហករណ៍លាយបូរ។

[១១:៣១:០៥]

ការចាប់ខ្លួនមនុស្សដែលបានត្អូញត្អែរ អំពីលក្ខខណ្ឌការងារត្រូវបានបញ្ជាក់ដោយកំណត់ត្រានៅសល់ដែលបានមកពីស្រុក។ *ស្លាយ*១០៩៖ បញ្ជីឈ្មោះអ្នកទោសនៅក្រាំងតាចាន់ រួមមានប្រជាជនដែលត្រូវបានចោទប្រកាន់ថា បានត្អូញត្អែរថាឲ្យស៊ីតែបបររាវៗ។ *ស្លាយ*១១១៖ នៅក្នុងលិខិតមួយចុះថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៨ ពីត្រាំងកក់ ប្រធានឃុំ ទន់ ផ្ញើទៅក្រាំងតាចាន់ ប្រធានឃុំ ទន់ បានសរសេរថា "យើងខ្ញុំចង់បញ្ជូនប្រជាជនថ្មីម្នាក់ឈ្មោះ សុខ សែ នៅភូមិត្រាំកក់ ឃុំត្រាំកក់។ ឈ្មោះ សុខ សែ នេះបានលើកទំនាស់ថា កាលពីថ្ងៃ១៤ មករា គេប្រើដូចសត្វតិរិច្ឆាន ធ្វើស្រូវបានចុកជម្រុកឲ្យបាយស៊ីមិនឆ្អែត។ ហើយរឿងនេះបក្សស្រុកបានសម្រេចឲ្យយើងធ្វើការចាប់បញ្ជូនមកកន្លែងសមមិត្តបង។"

*ស្លាយ*១១២៖ និងនៅក្នុងឯកសារថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៧៧ មេឃុំញ៉ៀងញ៉ង បានរាយការណ៍ពីស្ត្រីប្អូននាក់ទៅកាន់បក្ស ពីព្រោះស្ត្រីទាំងនេះបានត្អូញត្អែរពីបដិវត្តន៍ និងបាននិយាយថា ខ្ញុំសូមដកស្រង់៖ "សម្បូរណាស់តែរកអីស៊ីមិនឃើញ ស៊ីតែបបរព្រឹកល្ងាច បដិវត្តន៍ស្អីគេ នេះរកស៊ីមិនឃើញដូចពីសង្គមចាស់ទេ។ ពីសង្គមចាស់សប្បាយណាស់ ចង់ស៊ីគុយទាវ ស៊ីនំ បានគ្រប់គ្រាន់ មិនដូចបដិវត្តន៍ស្អីគេនេះទេ។"

លោកប្រធាន លោក លោកស្រីចៅក្រមនេះជាការពិតស្ដីពីជីវិតនៅក្នុងស្រុកគំរូរបស់បក្សកុម្មុយនីស្តកម្ពុជា។ ឧក្រិដ្ឋកម្ម អំពីការធ្វើឲ្យទៅជាទាសករ និងអំពើមនុស្សធម៌ត្រូវបានបង្ហាញពីសក្ខីកម្មយ៉ាងជាក់លាក់ហួសពីវិមតិសង្ស័យ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ សូមភាគីជ្រាប។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:០១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ ហើយតទៅនេះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាជាតិ ដើម្បីបន្តការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

**លោកស្រី ជា លាង៖**

លោក លោកស្រីចៅក្រម ភាគីទាំងអស់ និងអង្គសវនាការសាជាថ្មី។ ឥឡូវនេះ ខ្ញុំចូលទៅដល់ប្រធានបទការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកជន។ ដោយសារតែជនជាប់ចោទ ក៏ត្រូវបានចោទប្រកាន់នៅក្នុងស្រុកត្រាំកក់ អំពីការធ្វើទុក្ខបុកម្នេញលើសាសនា ទាក់ទងនឹងពុទ្ធសាសនិកជនដែរនោះ មុនពេលចូលទៅកាន់អាពាហ៍ពិពាហ៍ដោយបង្ខំ ខ្ញុំសូមលើកឡើងដោយសង្ខេបអំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ក្នុងការហាមឃាត់ព្រះពុទ្ធសាសនា និង ភស្តុតាងចំពោះអ្វីដែលបានកើតឡើងទាក់ទងនឹងវត្តអារាម ព្រះសង្ឃ និង ការអនុវត្តព្រះពុទ្ធសាសនានៅក្នុងស្រុកត្រាំកក់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មិនអាចមានមន្ទិលសង្ស័យទៀតនោះទេ ដែលថាគោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំងឡាយដែលត្រូវបានអនុវត្តដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺការបំបិទវត្តអារាម ការផ្សឹកព្រះសង្ឃ និងការហាមឃាត់ ការអនុវត្តព្រះពុទ្ធសាសនា ភស្តុតាងមិនបានផ្អែកទៅលើពាក្យចចាមអារ៉ាម ដូចដែលបានអះអាងឡើងដោយមេធាវីការពារក្តីនោះទេ។ ប៉ុន្តែផ្អែកលើបទពិសោធន៍ផ្ទាល់របស់ប្រជាជនកម្ពុជា ដែលបានរស់នៅឆ្លងកាត់ និងបានរស់រានមានជីវិតពីរបបខ្មែរក្រហម ហើយដែលបានទទួលរងគ្រោះពីការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងមូលដ្ឋាននៃជីវិតក្នុងប្រទេសកម្ពុជា។ នៅពេលដែលវត្តអារាមនៅក្នុងតំបន់របស់ពួកគាត់ត្រូវបានបិទ ព្រះសង្ឃត្រូវបានផ្សឹក ហើយគេលែងអនុញ្ញាតឲ្យពួកគាត់ធ្វើសក្ការ និងអនុវត្តសាសនារបស់ខ្លួនតទៅទៀតនោះទេ។

[១៣:៣២:៣៤]

លោកប្រធាន លោក លោកស្រីចៅក្រម បានស្ដាប់សាក្សីរាប់រយនាក់នៅក្នុងបន្ទប់សវនាការនេះ និងរាប់ពាន់នាក់ផ្សេងទៀត ត្រូវបានស្ដាប់ចម្លើយ និង ហាក់ដូចជាមិនមានភស្តុតាងគួរឲ្យជឿជាក់បាន ដូចអ្វីដែលមេធាវីបានលើកឡើងនោះទេ។ តែផ្ទុយទៅវិញ មានភស្តុតាងជាច្រើនលើសលុបដែលបញ្ជាក់ថា ព្រះពុទ្ធសាសនាត្រូវបានលុបបំបាត់ពីសង្គមកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ យើងបានដាក់នៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់យើង នូវបញ្ជីឈ្មោះសាក្សីនានា មកពីភូមិភាគ និងតំបន់នីមួយៗនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានផ្ដល់ភស្តុតាងបញ្ជាក់អំពីការលុបបំបាត់ព្រះពុទ្ធសាសនានៅក្នុងតំបន់របស់ពួកគេ គឺឧបសម្ព័ន្ធ “ង” ភ្ជាប់ទៅនឹងសារណារបស់យើង។

មេធាវីការពារក្ដីហាក់ដូចជា បានធ្វើឲ្យលោក លោកស្រីចៅក្រមជឿថា វាគ្រាន់តែជាការគាបជួនតែប៉ុណ្ណោះ ថាគ្រប់វត្តអារាមត្រូវបានត្រូវបានបិទ – គាបជួនប៉ុណ្ណោះ ដែលថាវត្តអារាមត្រូវបានបិទ និងព្រះសង្ឃទាំងអស់ត្រូវបានផ្សឹក នៅក្នុងទីកន្លែងក្នុងប្រទេសនេះ ក្រោយពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានឡើងកាន់អំណាចនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ ការលើកឡើងទាំងនោះ មិនពិតនោះទេ វាគឺជាការសម្រេចមួយដែលបានធ្វើឡើងដោយ ប៉ុល ពត, នួន ជា, ខៀវ សំផន និងមេដឹកនាំកំពូលរបស់បក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀត នៅក្នុងកិច្ចប្រជុំដែលពួកគេបានធ្វើឡើងនៅទីក្រុងភ្នំពេញ ក្រោយថ្ងៃជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ ដែលគោលនយោបាយនេះក្រោយមក ត្រូវបានផ្សព្វផ្សាយដោយមេដឹកនាំកំពូលទាំងពីររូបនេះ នៅក្នុងកិច្ចប្រជុំរួមរបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលបានធ្វើឡើងចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៥។

[១៣:៣៤:៤៣]

លោកប្រធាន លោក លោកស្រីចៅក្រមបានស្ដាប់ឮពីអ្នកចូលរួមម្នាក់ក្នុងចំណោមអ្នកចូលរួមក្នុងប្រជុំនោះ ដែលនៅរស់រានមានជីវិត គឺអតីតលេខាតំបន់១០៥ ឈ្មោះ សៅ សារុន ដែលបានបញ្ជាក់ថា ប៉ុល ពត និងទាំង នួន ជា បាននិយាយអំពីការបិទវត្តអារាម។ លោកប្រធាន លោក លោកស្រីចៅក្រម ក៏បានស្ដាប់ផងដែរ អំពីរបៀបនៃសេចក្ដីណែនាំរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានអនុវត្តនៅក្នុងស្រុកត្រាំកក់។ ដូចដែលបានផ្ដល់សក្ខីកម្មដោយ ពេជ្រ ជឹម មេដឹកនាំមូលដ្ឋានម្នាក់ក្នុងចំណោមមេដឹកនាំក្នុងមូលដ្ឋាននោះ ដែលបានចូលរួមការប្រជុំថ្ងៃទី២០ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៥ នៅក្រុងភ្នំពេញ គឺជាអតីតលេខាស្រុកត្រាំកក់ ឈ្មោះ យាយខុម ដែលជាកូនស្រីរបស់ តាម៉ុក។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅពេលដែលគាត់ត្រឡប់មកពីការប្រជុំនោះវិញ គាត់បានកោះប្រជុំកម្មាភិបាលស្រុកត្រាំកក់ ដែលនៅពេលនោះ គាត់បានផ្សព្វផ្សាយទៅកាន់ប្រធានឃុំ អំពីបទបញ្ជារបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា នូវអ្វីដែលកើតឡើងចំពោះវត្តអារាម ព្រះសង្ឃ និងព្រះពុទ្ធសាសនា។ សាក្សីជាច្រើនមកពីស្រុកត្រាំកក់បានផ្តល់សក្ខីកម្មអំពីការប្រជុំនោះ និងអំពីការអនុវត្តបទបញ្ជានោះជាបន្តបន្ទាប់ ដែលយ៉ាងហោចណាស់មានព្រះសង្ឃចំនួន១០០អង្គ មកពីទូទាំងខេត្តតាកែវត្រូវបានប្រមូលផ្តុំនៅវត្តអង្គរកា ក្នុងស្រុកត្រាំកក់ ហើយត្រូវបានបង្ខំឲ្យសឹក។

លោក លោកស្រីចៅក្រម បានស្តាប់ព្រះថេរដីការបស់ព្រះសង្ឃចំនួនពីរអង្គ ក្នុងចំណោមព្រះសង្ឃទាំង១០០អង្គនោះ ព្រះសង្ឃព្រះនាម អែម ភឿង ព្រះមេគុណខេត្តកំពត និងព្រះសង្ឃព្រះនាម ខៀវ នៅ។ សាក្សីទាំងពីរអង្គបានបញ្ជាក់ថា ព្រះអង្គនិងព្រះសង្ឃផ្សេងទៀតដែលបានប្រមូលផ្តុំនោះត្រូវបានបង្ខំឲ្យលាសិក្ខាបទ។

[១៣:៣៧:០០]

*ស្លាយ*១១៥ នៅក្នុងថេរដីការបស់ព្រះតេជព្រះគុណ អែម ភឿង ខ្ញុំសូមដកស្រង់៖ "ឧបជ្ឈាកុដិអាត្មា លោកប្រាប់ថាលោក គេមិនអាចឲ្យលោកនៅបានទេ ព្រោះករុណាចាស់ហើយ ក៏គេឲ្យករុណាសឹកដែរ ប៉ុន្តែករុណាមិនទាន់ដល់ពេលវេលាសឹក លោកនៅព្រៃត្រូវសឹកមុនករុណាអស់ទៅ ព្រះអង្គរកាមិនឲ្យនៅទេ។" ខ្ញុំសូមបញ្ចប់ការដកស្រង់។ បានប្រាប់ទៀតថា ឥឡូវកុំមានទំនាស់អីជាមួយនឹងអង្គការឲ្យសោះ ប្រើអ្វី ប្រើធ្វើអ្វីឲ្យធ្វើទៅ អត់ផ្តត់ទៅ អត់បានទេ តែប៉ានទំនាស់ អង្គការគឺអង្គការវ៉ៃចោលអត់រស់ទេ ត្រូវស្លាប់។ ព្រឹត្តិការណ៍នេះក៏ត្រូវបានបញ្ជាក់ផងដែរ ដោយកម្មាភិបាលនិងប្រជាជនមូលដ្ឋានដោយរួមទាំង រៀល សន និងអតីតនីរសារស្រុក និងអ្នកយាមគុកក្រាំងតាចាន់ ឈ្មោះ វ៉ាន់ សឿន ហៅស៊ាន់។ ភស្តុតាងគឺច្បាស់ណាស់ ដែលថាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ពិតជាបានអនុវត្តនូវផែនការនេះ ទាំងក្នុងស្រុកត្រាំកក់ និងទាំងក្នុងប្រទេសកម្ពុជាទាំងមូល។ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាខ្លួនឯងផ្ទាល់ បានប្រកាសសារាចររបស់បក្សនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ ថាលោកសង្ឃក៏អស់៩០ទៅ៩៥ភាគរយ ក្នុងន័យដែលភាគច្រើនលះបង់សាសនា លែងមានតទៅទៀតហើយ។ នៅក្នុងវគ្គសិក្សា -- ក្នុងវគ្គសិក្សាខែកញ្ញា ឆ្នាំ១៩៧៨ ដឹកនាំដោយ ប៉ុល ពត និង នួន ជា ដែលបានចូលរួម និងផ្តល់សក្ខីកម្មដោយ ឌុច ប្រធានស-២១ ថា ប៉ុល ពត បានប្រកាសថា "បក្សបានជោគជ័យក្នុងការលុបបំបាត់ព្រះពុទ្ធសាសនា ជាចលនារបស់មហាជន លោកសង្ឃធ្វើទំនប់អីចឹងទៅ ដល់យូរទៅវាភ្ញាក់ខ្លួនឯង ចង់ទៅច្បាំង

នៅខាងមុខវាមានកាំភ្លើង វាមានអីកាន់ វាមានកិត្តិយស សនឹងគេ។”

ឯកសារសហកាលពីស្រុកត្រាំកក់ ក៏បានបញ្ជាក់ផងដែរ ពីការលុបបំបាត់ព្រះពុទ្ធសាសនា។ ជាឧទាហរណ៍នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៧ របាយការណ៍ស្ដីពីឃុំលាយបូរ រាយការណ៍ពីការចាប់ខ្លួនយុវជនមូលដ្ឋានម្នាក់ ដែលបានត្អូញត្អែរថា ខ្ញុំសូមដកស្រង់៖ “ពុទ្ធសាសនាក៏គ្មាន លោកក៏គ្មាន សាលារៀនក៏គ្មាន គ្រូក៏គ្មាន ផ្សារក៏គ្មាន។” ជាការផ្ទុយទៅនឹងកន្លែងដែលត្រូវធ្វើសក្ការបូជាដោយសន្តិភាព វត្តអារាមជាច្រើនបានក្លាយទៅជាមន្ទីរសន្តិសុខ និងកន្លែងសម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជា។ លោកប្រធាន លោក លោកស្រីចៅក្រមបានស្ដាប់ភស្តុតាងមួយចំនួនអំពីគុកទាំងអស់នេះក្នុងអំឡុងពេលសវនាការនេះ វត្តអូរត្រកួននៅក្នុងស្រុកកងមាស ជាកន្លែងដែលមានជនជាតិចាម និងប្រជាជនថ្មីរាប់ពាន់នាក់ត្រូវបានបញ្ជូនទៅសម្លាប់ចោលក្នុងវត្តបារាយណ៍ជាន់ដែកដែលនៅជាប់នឹងទំនប់១មករា។ ព្រះតេជព្រះគុណ អែម ភឿង បានផ្ដល់សក្ខីកម្មថា វត្តភាគច្រើននៅក្នុងតំបន់របស់លោកត្រូវបានធ្វើគុក។ ហើយ អៀវ៉ាន ហារី ត្រូវស្រាវជ្រាវជាន់ -- អ្នកស្រាវជ្រាវជាន់ខ្ពស់អំពីព្រះពុទ្ធសាសនានៅក្រោមរបបខ្មែរក្រហមបានរកឃើញថា មន្ទីរអប់រំស្រុកចំនួន១៥ក្នុងចំណោម២១នៅក្នុងភូមិភាគនិរតីធ្វើនៅក្នុងវត្ត។

[១៣:៤១:០៧]

នៅចំពោះមុខភស្តុតាងដ៏លើសលុបនេះ មេធាវីការពារក្ដីរបស់ នួន ជា បានអះអាងថា មិនមានគោលនយោបាយណាមួយដែលហាមឃាត់ដល់សាសនានោះទេ ហើយជាការគាំទ្រដល់ការអះអាងដែលកម្រនឹងជឿនេះ បានលើកឡើងពីអតីតលេខាស្រុកត្រាំកក់ ពេជ្រ ជឹម សូមអនុញ្ញាតឲ្យខ្ញុំបានបញ្ចប់អំពីអំណះអំណាងផ្នែកនេះដោយការបង្ហាញនូវលោកប្រធាន លោក លោកស្រីអំពីអ្វីដែលសាក្សី និងមេធាវីការពារក្ដីបានពឹងផ្អែក។ លើនេះបានផ្ដល់សក្ខីកម្មជាក់ស្ដែងនៅក្នុងបន្ទប់សវនាការនេះ សូមបញ្ចាំង*ស្លាយ*១១៨។ ពេជ្រ ជឹម សាក្សីដែលបានពឹងផ្អែកដោយមេធាវីការពារក្ដីបានផ្ដល់សក្ខីកម្មថា ខ្ញុំសូមដកស្រង់៖ “ប៉ុន្តែធ្វើម៉េចបានអីចឹង ព្រះពុទ្ធសាសនាស្ងួតពេក។” គាត់បានផ្លាស់ -- ផ្ដល់សក្ខីកម្មថា៖ “និយាយល្អិតទៅ ដឹងតែព្រះសង្ឃឲ្យសឹក ហើយទស្សនៈឃើញថា ទុកលោកនៅហ្នឹងហើយ ប៉ុន្តែយើងមិនប៉ានថាខ្លាំង បើថាខ្លាំង ខ្លាច។” ហើយគាត់បានផ្ដល់សក្ខីកម្មថា ខ្ញុំសូមដកស្រង់៖ “ប្រកាសប្រជុំហ្នឹង ខុម ប្រធានបក្ស ឲ្យរំលាយព្រះពុទ្ធរូបចោល។ ឃុំយកទៅអនុវត្តរៀបរយធ្វើតាមហ្នឹងទៅ។”

លោក លោកស្រីចៅក្រម ជនជាប់ចោទគឺមានពិរុទ្ធភាពអំពីការធ្វើទុក្ខបុកម្នេញខាងព្រះពុទ្ធសាសនា។ ហើយបន្តទៀតនេះ ខ្ញុំសូមឲ្យសហការីខាងជាតិលើកឡើងបន្តអំពីឧក្រិដ្ឋ -- អាពាហ៍ពិពាហ៍

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។

ដោយបង្ខំ។ ចាស សូមអនុញ្ញាត ចាស។

[១៣:៤៣:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ជាបឋម សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ជាបន្តទៅទៀតនេះ ខ្ញុំសូមលើកឡើងអំពីឧក្រិដ្ឋកម្មដែលទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

បក្សកុម្មុយនីស្តជឿជាក់ថា ពួកគេអាចប្រព្រឹត្តចំពោះប្រជាជនកម្ពុជាធម្មតា ដូចជារបស់របរមួយដែលពួកមេដឹកនាំអាចប្រើតាមតែចិត្តនឹកឃើញ។ បានបង្ហាញឱ្យឃើញថែមទៀតនៅក្នុងគោលនយោបាយបង្ខំមនុស្សឱ្យរៀបការជាប្ដី ឬប្រពន្ធ និងបង្ខំឱ្យពួកគេរួមសង្វាសដែលបានធ្វើឡើងដោយរបបនេះ។ គោលនយោបាយទាំងនេះ បង្កើតបានជាឧក្រិដ្ឋកម្មពីរដាច់ដោយឡែកពីគ្នា ដែលត្រូវបានធ្វើចំណាត់ថ្នាក់ដោយស្របច្បាប់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត។ ទី១ គឺសម្រាប់អាពាហ៍ពិពាហ៍ដោយបង្ខំ ទី២ គឺការរំលោភសេពសន្ថវៈក្នុងករណីដែលប្ដីប្រពន្ធត្រូវបានគេបង្ខំឱ្យរួមភេទដោយគ្មានការព្រមព្រៀងពីខាងស្រី ឬខាងប្រុស ឬក៏ពីអ្នកទាំងពីរ។ មានភស្តុតាងនៅក្នុងតុលាការនេះបានបង្ហាញថា ជនជាប់ចោទ និងមេដឹកនាំខ្មែរក្រហមដទៃទៀត បានស្វែងរកវិធីបង្កើនចំនួនប្រជាជនកម្ពុជាឱ្យបានឆាប់រហ័សសម្រាប់បម្រើឱ្យការងារកសិកម្ម និងការពារជាតិ។ តាមរយៈការរៀបចំឱ្យមានការរៀបការមនុស្ស ដោយគ្មានការយល់ព្រមពីពួកគាត់ ពួកគេនឹងបង្កើតគ្រួសារបដិវត្តដែលស្មោះស្ម័គ្រចំពោះតែអង្គការមួយ។ បុរសនិងស្ត្រីដែលជាទូទៅមិនធ្លាប់បានជួបគ្នាពីមុនមក ត្រូវបានគេបង្ខំឱ្យរៀបការ និងរួមភេទជាមួយគ្នាដោយផ្ទុយនឹងឆន្ទៈរបស់ពួកគេ។

[១៣:៤៥:២០]

ភស្តុតាងបង្ហាញថា គោលនយោបាយនេះត្រូវបានអនុវត្តនៅគ្រប់តំបន់ និងភូមិភាគស្វយ័តទាំងអស់នៃប្រទេស រួមទាំងនៅក្នុងកងពលធំយោធាមជ្ឈិមនៃកងទ័ពបដិវត្តន៍កម្ពុជាផងដែរ។ ទាំងលោក នួន ជា និងលោក ខៀវ សំផន សុទ្ធតែបានជួយលើកកម្ពស់ដល់គោលនយោបាយអាពាហ៍ពិពាហ៍ដោយ

បង្ខំនេះ។ ជនជាប់ចោទទាំងពីរសុទ្ធតែបានបញ្ជាក់អះអាងថា បក្សកុម្មុយនីស្តកម្ពុជាមានបំណងចង់បង្កើនចំនួនប្រជាជនកម្ពុជាឲ្យបានឆាប់បំផុតពីប្រហែល៨លាននាក់ ទៅចន្លោះពី១៥ទៅ២០លាននាក់ក្នុងរយៈពេល៥ឆ្នាំទៅដល់១០ឆ្នាំ។ សុំដាក់បញ្ចាំង*ស្លាយ*លេខ១២៨។ នៅក្នុងសៀវភៅរបស់គាត់ផ្ទាល់លោក ខៀវ សំផន បានធ្វើការកត់សម្គាល់ថា លោក ហ្វីលីព ស្សត បានមើលឃើញត្រូវនៅពេលដែលគាត់សរសេរថា ខ្ញុំសូមដកស្រង់ថា៖ "ប៉ុល ពត មិនមានបំណងអ្វីចង់បន្ថយចំនួនប្រជាជនទេ តែផ្ទុយទៅវិញ គាត់មានទិសដៅបង្កើនចំនួនប្រជាជនទ្វេជាពីរឬបីដង។ ជាក់ស្តែងគាត់ចង់ឲ្យប្រជាជនកម្ពុជាកើនទៅដល់១៥ ឬ២០លាននាក់ក្នុងរយៈ១០ឆ្នាំខាងមុខនេះ។" សូមបញ្ចប់ការដកស្រង់។

ក្នុងឆ្នាំ១៩៧៨ លោក ខៀវ សំផន បាននិយាយទៅកាន់មនុស្សប្រហែល២០.០០០នាក់ រួមទាំងតំណាងកងទ័ពបដិវត្តន៍កម្ពុជាផង ដោយបានបំផុសឲ្យកម្មាភិបាល សុំដកស្រង់៖ "ស្វែងយល់ឲ្យបានជ្រួតជ្រាប និងអនុវត្តឲ្យបានល្អនូវផែនការបង្កើនបរិមាណប្រជាជនដល់កម្រិតអតិបរិមាណរបស់ខ្លួនដើម្បីសម្រេចតាមគោលដៅឲ្យមានប្រជាជនចំនួនពី១៥ទៅ២០លាននាក់ ក្នុងរយៈពេលពី១០ឆ្នាំទៅ១៥ឆ្នាំខាងមុខ។" សូមបញ្ចប់ការដកស្រង់។ លោក នួន ជា បានទទួលស្គាល់ក្នុងបទសម្ភាសន៍ដែលធ្វើនៅឆ្នាំ១៩៨១ថា សូមដកស្រង់៖ "កម្ពុជាប្រជាធិបតេយ្យបានប្រកាន់គោលនយោបាយបង្កើនចំនួនប្រជាជនរបស់ខ្លួន ចាប់តាំងពីឆ្នាំ១៩៧៥មក កម្ពុជាប្រជាធិបតេយ្យជានិច្ចកាលត្រូវការឲ្យមានកំណើនយ៉ាងឆាប់រហ័សនៃចំនួនប្រជាជនរបស់ខ្លួន។ ដូចនេះហើយផែនការរយៈពេល៤ឆ្នាំ ឆ្នាំ១៩៧៧ដល់ឆ្នាំ១៩៨០ មានគោលបំណងបង្កើតចំនួនប្រជាជនឲ្យឡើងដល់យ៉ាងយោចណាស់១៥លាននាក់ នៅក្នុងរយៈពេល៥ទៅ១០ឆ្នាំ។" បាទ សូមបញ្ចប់ការដកស្រង់។

[១៣:៤៨:២៧]

ទស្សនាវដ្តីទង់បដិវត្តដែលលោក នួន ជា បានទទួលស្គាល់ថា គាត់មានតួនាទីដ៏សំខាន់ក្នុងការផលិតនោះ ក៏បានលើកឡើងអំពីការបង្កើនចំនួនប្រជាជនឲ្យបានឆាប់រហ័សពី១៥ទៅ២០លាននាក់ដែរ។ ទង់បដិវត្តនេះបានសរសេរនូវសុន្ទរកថាមួយដែលធ្វើឡើងដោយ ប៉ុល ពត ដោយលើកឡើងថា ខ្ញុំសូមដកស្រង់៖ "ចំនួនប្រជាជនយើងមានការកើនល្បឿនជាងកាលជំនាន់មុនរដ្ឋប្រហារ ប៉ុន្តែល្បឿននេះនៅមិនទាន់គ្រប់គ្រាន់ទេ បើប្រៀបធៀបនឹងសំណូមពររបស់បក្សដែលសំដៅឲ្យបង្កើនប្រជាជនឲ្យបានពី១៥ទៅ២០លាននាក់ក្នុងរយៈពី១០ទៅ១៥ឆ្នាំ។" សូមបញ្ចប់ការដកស្រង់។

និងមានទស្សនាវដ្តីទង់បដិវត្តមួយផ្សេងទៀតដែលបានលើកឡើងដែរថា សុំដកស្រង់៖ "យើង

ត្រូវការប្រជាជនពី១៥ ទៅ២០លាន ទើបគ្រប់គ្រាន់នឹងដីរបស់យើង។" សូមបញ្ចប់ការដកស្រង់។ ដើម្បីសម្រេចបានគោលបំណងក្នុងការបង្កើនចំនួនប្រជាជនឲ្យបានទ្វេដងនៃចំនួនប្រជាជនដែលកំពុងតែត្រូវបានគេបង្អត់អាហារ បង្ខំឲ្យធ្វើការលើសកម្លាំង និងសម្លាប់ជាប្រព័ន្ធនេះ គេនឹងត្រូវការកំណើនដែលមិនធ្លាប់មានពីមុនមកអំពីអត្រាកំណើននេះ ដើម្បីសម្រេចបានគោលដៅដែលគ្មានភាពប្រាកដនិយមទាំងនេះ អាពាហ៍ពិពាហ៍ទាំងឡាយនឹងត្រូវបានគេរៀបចំឡើង និងត្រូវបានអនុម័ត ដោយបក្សកុម្មុយនីស្តកម្ពុជា។

លោក នួន ជា បានទទួលស្គាល់ចំពោះអ្នកសរសេរប្រវត្តិរូបរបស់គាត់ដែលគាត់បានជ្រើសរើសគឺលោក ថេត សម្បត្តិ ថា ខ្ញុំសូមដកស្រង់ "ប្រុសៗតែងតែចង់ជ្រើសរើសយកស្រីស្អាត ហេតុនេះហើយបានជាយើងបង្ខំពួកគេឲ្យរៀបការ ហើយអង្គការជាអ្នករើសប្រពន្ធឲ្យ។" បញ្ចប់ការដកស្រង់។ គោលនយោបាយរៀបការដោយបង្ខំរបស់មជ្ឈិមបក្សនេះ ត្រូវបានអនុវត្តនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ ហើយពិធីរៀបការដូច្នេះ មានការចូលរួម ជាអធិបតីដោយមន្ត្រីពីថ្នាក់លើខុសៗគ្នា រួមមានដូចជាប្រធានអង្គភាពរបស់សាម៉ីជន ប្រធានភូមិ ប្រធានសហករណ៍ មេឃុំ មេស្រុក មន្ត្រីតំបន់ មន្ត្រីភូមិភាគ និងមន្ត្រីយោធាជាដើម។

ការអះអាងណាក៏ដោយដែលថា គោលនយោបាយនេះ មិនកើតចេញពីមជ្ឈិមបក្សនោះ វាគឺជាការកុហកទាំងស្រុង ខុសពីការពិត ពីព្រោះថា គោលនយោបាយនេះ ត្រូវបានអនុវត្តដោយបុគ្គលថ្នាក់ខ្ពស់បំផុតរបស់បក្ស។ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មភាគីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជា ឌៀប ដែលធ្លាប់ធ្វើការនៅក្រសួងពាណិជ្ជកម្ម។ លោកស្រី ជា ឌៀប ធ្លាប់ផ្តល់សក្ខីកម្មថា លោក ខៀវ សំផន ធ្លាប់មកថ្លែងសុន្ទរកថាជូនលោកស្រី និងកម្មការិនីដទៃទៀតនៅក្នុងក្រសួងពាណិជ្ជកម្ម។ ហើយខ្ញុំសូមចាក់ខ្សែអាត់សំឡេងរបស់គាត់ជូននូវអ្វីដែលបាននិយាយដូចតទៅ។ បាទ សូមចាក់វីដេអូលេខ៥។

[១៣:៥២:៣២]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*អ្នកស្រីបានជម្រាបអង្គសវនាការអម្បាញ់មិញថា អ្នកស្រីបានជួបលោកតា ខៀវ សំផន ពីរដង។ ចាស ម្តងគឺជួបនៅពេលប្រជុំនៅវត្តឧណ្ណាលោម។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរអ្នកស្រីថា ក្នុងពេលដែលគាត់ធ្វើប្រជុំនៅវត្តឧណ្ណាលោម តើគាត់ប្រជុំនិយាយអំពីអីដែរ អ្នកស្រី? សូមអ្នកស្រីរៀបរាប់បន្តិចមើល។ គាត់និយាយថា សុំស្នើសមមិត្តនារី យុវជនទាំងអស់ ប្រឹងធ្វើការជូនរដ្ឋ ហើយយុវជនដែលយុវជននារីដែលមានអាយុពី១៩ឆ្នាំឡើងទៅ ឲ្យតាមកម្មាភិបាល តាមមុខ -- ក្រសួងទាំងអស់ ឲ្យរៀបចំ*

*ឲ្យមានគ្រួសារទៅ គាត់ថាអ៊ីចឹង។ កុំទុកឲ្យនៅច្រើនពេក។ ចាស អរគុណ។ ចាស ដែលគាត់បានមានប្រសាសន៍ថា យុវជន យុវនារី រៀបចំឲ្យមានគ្រួសារទាំងអស់ហ្នឹង គាត់មានបាននិយាយថា យុវជន យុវនារី ចាប់ពីអាយុប៉ុន្មានត្រូវរៀបការ? ហើយអ្នកដែលរៀបការហ្នឹង លុះត្រាថាអ្នកទុំងដូចថាមានការស្រឡាញ់គ្នាស្ម័គ្រចិត្ត អត់មានការចាប់បង្ខំអីៗ គាត់មាននិយាយបញ្ហាហ្នឹងទេ? គាត់មិនបាននិយាយថា ស្រឡាញ់គ្នា ស្រឡាញ់អីទេ គាត់គ្រាន់តែប្រាប់ថា ឲ្យរៀបចំគ្រួសារទៅ តាំងពីអាយុ១៩ឡើងទៅ យុទ្ធជនអាយុ២៥អី ទុកធ្វើអីទៀត។ ស្នើតាមក្រសួងមន្ទីរទាំងអស់ ឲ្យគិតគូររៀបការឲ្យយុទ្ធជន-នារីអស់ទៅ។ គាត់គ្រាន់តែ ទុកតែក្មេងៗសិនទៅបានហើយ។ គាត់និយាយអ៊ីចឹង។ ចាស អរគុណអ្នកស្រី។ ចាស ដែលគាត់និយាយអំពីពាក្យថា យុវជន យុវនារី ដែលចាស់ៗហើយ ឲ្យរៀបការ។ អ៊ីចឹងគាត់មានដែល មានបានពន្យល់ប្រាប់នៅពេលដែលកំពុងតែនិយាយថា យុវជន យុវនារីរៀបការ រៀបការក្នុងគោលបំណងអ្វីដែរអ្នកស្រី? គាត់ថា ឲ្យរៀបការទៅដើម្បីបង្កើតកូនបង្កើតចៅឲ្យគ្នា -- បានកូនចៅច្រើនទៅ ដើម្បីជាកម្លាំងការពារប្រទេសជាតិ។ គាត់និយាយប៉ុណ្ណឹង។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៣:៥៤:៤៧]

បាទ លោកស្រី ជា ឌៀប បានផ្ដល់សក្ខីកម្មថា ភ្លាមៗបន្ទាប់ពីលោក ខៀវ សំផន បានបង្ហាញពីចំណាប់អារម្មណ៍ទាំងនោះហើយ នារីៗនៅក្នុងក្រុមរបស់គាត់ត្រូវបានរៀបការ។ ការពិតភស្តុតាងបង្ហាញពីរបាយការណ៍ជាច្រើន អំពីការរៀបការទ្រង់ទ្រាយធំ ដែលបានកើតឡើងនៅក្នុងក្រសួងពាណិជ្ជកម្មរបស់លោក ខៀវ សំផន។ ឧទាហរណ៍មួយទៀតគឺអ្នកស្រី ផាន់ ហ៊ីម ដែលជាកម្មាភិបាលនារីម្នាក់ខាងពាណិជ្ជកម្ម បានផ្ដល់សក្ខីកម្មថា មាន២១គូដែលស្ថិតនៅក្នុងក្រុមនុស្សដែលបានរៀបការជាមួយអ្នកស្រី និងថា ខ្ញុំសូមដកស្រង់នូវ*ស្លាយ*លេខ១៣៩៖ "គេថា មិត្តឯងមិនយក ក៏នៅតែអង្គការរៀបឲ្យដែរ។ មិត្តឯងមិនគោរពអង្គការវិន័យ មិត្តឯងប្រយ័ត្នខ្លួនបន្តិចទៅ។" បញ្ចប់ការដកស្រង់។ បន្ទាប់មកអ្នកស្រីបានរៀបរាប់កាលពីយប់ដែលអ្នកស្រីត្រូវបានគេប្រាប់ឲ្យរៀបការ សូមដកស្រង់៖ "ដល់ពេលយប់មួយ ស្រាប់តែប្រធានកងខាងនារី ខាងគាត់ហ្នឹងមក ខ្ញុំចេញពីធ្វើការសម្រិតសម្រាំងម៉ោងប្រហែលប្រាំបួនយប់ ស្រាប់គាត់ហៅខ្ញុំសួរ ហៅខ្ញុំសួរថា មិត្ត! អង្គការឲ្យមិត្តឯងមានគ្រួសារ តើមិត្តឯងថាម៉េចដែរ? តែអ្នកស្នើមិត្តឯងហ្នឹងគឺឈ្មោះ វ៉ាត់ នៅក្រសួងពាណិជ្ជកម្មក្រៅប្រទេស។ ខ្ញុំក៏ថា ខ្ញុំរឿងគ្រួសារខ្ញុំអត់ទាន់យកទេ។ ម៉េចបានមិនយក? ព្រោះថា ខ្ញុំឡាក់ឡើត ខ្ញុំអត់ទាន់ចង់បានទេ ព្រោះខ្ញុំចង់តែធ្វើការ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ងារ ខ្ញុំអត់ទាន់ចង់បានគ្រួសារ។ ខ្ញុំឆ្លើយអ៊ីចឹងទៅ គាត់ថា គ្រួសារដែលអង្គការឲ្យមិត្តឯងរៀបនេះ គឺមិត្តឯងមិនយក ក៏ត្រូវតែអង្គការរៀបឲ្យដែរ។ មិត្តឯងរស់នៅក្នុងសង្គមនេះ មិត្តឯងត្រូវតែគោរពអង្គការវិន័យ ត្រូវតែគោរពបក្ស តែបក្សដាក់ទិសមកឲ្យមិត្ត ដែលយកគ្រួសារ មិត្តត្រូវតែរៀប។” សូមបញ្ចប់ការដកស្រង់។

រស់ ស៊ុយ អនុប្រធានឃ្លាំងរដ្ឋក្នុងក្រសួងពាណិជ្ជកម្មបានផ្ដល់ភស្តុតាងថា ចាប់តាំងពីឆ្នាំ១៩៧៧ ក្រសួងបានទទួលផែនការ ខ្ញុំសូមដកស្រង់៖ “វិធានការតឹងរ៉ឹង”។ បញ្ចប់ការដកស្រង់។ ត្រូវរៀបការ ១០០គូក្នុង១ខែ។ រស់ ស៊ុយ ខ្លួនគាត់ផ្ទាល់ក៏ត្រូវបានគេបង្ខំឲ្យរៀបការដែរ ហើយគាត់ក៏គេតម្រូវឲ្យនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំសម្រាប់មនុស្សរាប់រយគូបន្ថែមទៀត។ អាពាហ៍ពិពាហ៍ខ្លះទៀតត្រូវបានដឹកនាំធ្វើដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មផ្ទាល់គឺឈ្មោះ វ៉ាន់ រិទ្ធ និងអនុប្រធានរបស់គាត់ឈ្មោះ ង៉ែត យូ ហៅ ហុង។

អាពាហ៍ពិពាហ៍ដោយបង្ខំក៏ត្រូវបានគេធ្វើឡើងដូចគ្នាដែរនៅក្នុងក្រសួងមួយ ដែលស្ថិតក្រោមការមើលខុសត្រូវរបស់លោក នួន ជា គឺក្រសួងសង្គមកិច្ច។ សូមបញ្ចាំង*ស្លាយ*លេខ១៤២ អ្នកស្រី ធុច ស៊ីថន បានផ្ដល់សក្ខីកម្មថា ខ្ញុំសូមដកស្រង់៖ “អ្នកដែលស្រករ១ខ្ញុំក្នុងខ្ទង់២០ឆ្នាំ នៅមន្ទីរពេទ្យក្ដី នៅក្រសួងសង្គមកិច្ចក្ដី គឺអង្គការចាប់ឲ្យ អង្គការឲ្យការ ផ្សំផ្គុំនៅ ដោយមើលអ្នកណាត្រូវជាមួយពីណា អ្នកណាត្រូវមួយពីណា។” សូមបញ្ចប់ការដកស្រង់។

[១៣:៥៩:០១]

អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានចាត់ចែងឡើងជាបុគ្គល និងអបអរសាទរដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀត ដែលជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម រួមមាន លេខាភូមិភាគនិរតី និងជាសមាជិកគណៈអចិន្ត្រៃយ៍ គឺតាម៉ុក, លេខាភូមិភាគកណ្ដាល កែ ពក, រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អៀង ធីរិទ្ធ និងអនុប្រធានរបស់គាត់ ស៊ីន ផលគុណ ហៅ ស៊ូ ព្រមទាំងមេដឹកនាំយោធាថ្នាក់កងពលធំមួយចំនួនទៀត។ លើសពីនេះ ឯកសារគោលនយោបាយមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា ស្ដីពីការកសាងគ្រួសារបានប្រកាស ទាក់ទងនឹងគ្រួសារ ខ្ញុំសូមដកស្រង់៖ “បើអង្គការសម្ងហាភាព ពិនិត្យឃើញយ៉ាងណា សម្រេចយ៉ាងណា ត្រូវតែគោរពតាមដាច់ខាត។” បញ្ចប់ការដកស្រង់។

ដូច្នេះគ្មានមន្ទិលទេថា គោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតចេញពីមជ្ឈិមបក្ស។ ភស្តុតាងបង្ហាញថា គោលនយោបាយនេះត្រូវបានអនុវត្តនៅទូទាំងប្រទេសកម្ពុជា ជាការគួរឲ្យចាប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អារម្មណ៍បំផុត ដើម្បីពិចារណាលើចំនួនពិតនៃភស្តុតាង សក្ខីកម្មដែលមាននៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងប្រទេសកម្ពុជា។ នៅក្នុងសំណុំរឿងលេខ០០២ សាក្សីដែលបានមកផ្តល់សក្ខីកម្មចំនួន៥៤នាក់ និងសាក្សីផ្សេងទៀតចំនួន១៣១នាក់ ដែលបានផ្តល់ចម្លើយនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដោយបានផ្តល់ភស្តុតាងស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍នេះផងដែរ។ ជាពិសេស មានសាក្សី២៧នាក់បានផ្តល់សក្ខីកម្មនៅក្នុងតុលាការថា ពួកគាត់ផ្ទាល់ត្រូវបានគេបង្ខំឲ្យរៀបការ ខណៈដែលចំនួន៥៩នាក់ទៀតបានផ្តល់ភស្តុតាងដូចគ្នានេះជូនការិយាល័យសហចៅក្រមស៊ើបអង្កេត។ លើសពីនេះទៀត ចំនួន២២នាក់បានផ្តល់សក្ខីកម្មថា ពួកគាត់បានឃើញផ្ទាល់នូវការរៀបការដោយបង្ខំរបស់អ្នកផ្សេង។ ហើយមានចំនួន៥២នាក់បន្ថែមទៀត បានផ្តល់ភស្តុតាងជូនការិយាល័យសហចៅក្រមស៊ើបអង្កេតថា ពួកគាត់បានឃើញដោយផ្ទាល់នូវអាពាហ៍ពិពាហ៍ដោយបង្ខំ។

[១៤:០២:០៥]

យើងបានបង្ហាញអំពីភស្តុតាងទាំងនេះ យ៉ាងទូលំទូលាយនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។ ភស្តុតាងនេះនិងភស្តុតាងផ្សេងៗទៀត ពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងសំណុំរឿងបានបង្ហាញរូបភាពយ៉ាងពិស្តារមួយ អំពីរបៀបដែលគោលនយោបាយស្តីពីអាពាហ៍-ពិពាហ៍ដោយបង្ខំត្រូវបានអនុវត្ត។ នៅក្នុងចំណោមចំណុចផ្សេងទៀត បង្ហាញឲ្យឃើញថា គូស្រករដែលគេបានផ្គូផ្គងគ្នា ដែលជាញឹកញាប់មិនធ្លាប់ជួបគ្នាពីមុនមក ជួនកាលត្រូវបានគេរៀបការឲ្យនៅក្នុងពិធីរៀបការជាហ្វូង ឬក៏ទ្រង់ទ្រាយធំ មានចំនួន៥០គូ ឬលើសពីនេះ។ វាបង្ហាញថា ការរៀបការត្រូវបានគេចាត់ចែងឡើងតាមការជូនដំណឹងក្នុងរយៈពេលខ្លី ឬគ្មានការជូនដំណឹងសោះ ហើយសមាជិកគ្រួសារ ជាពិសេសឪពុកម្តាយ គេកម្រអនុញ្ញាតឲ្យមកចូលរួមក្នុងអាពាហ៍ពិពាហ៍នេះណាស់។ វាបង្ហាញឲ្យឃើញថា គេមានវិធានស្តីពីថាតើនរណាអាចរៀបការជាមួយនរណា ដើម្បីឲ្យបុគ្គលដែលមានវណ្ណៈនយោបាយ ជាតិពិន្ទុ និងប្រវត្តិដូចគ្នាបេះបិទ ត្រូវបានគេផ្សំផ្គុំជាគូនឹងគ្នា។ ហើយវាបង្ហាញថានៅក្នុងអំឡុងនៃពិធីអាពាហ៍ពិពាហ៍ គូស្រករជាញឹកញាប់ត្រូវបានគេតម្រូវឲ្យធ្វើការដោះស្រាយដើម្បីបម្រើអង្គការ។

[១៤:០៤:០០]

ជាមួយគ្នានេះដែរ ម៉ឹង វេត ដែលជាកម្មាភិបាលខ្មែរក្រហមម្នាក់បានផ្តល់សក្ខីកម្មថា ខ្ញុំសូមដក

ស្រង់ *ស្លាយ*លេខ១៤៥៖ "ពីម្សិលមិញសួរខ្ញុំ ដល់អ៊ីចឹងមិនឲ្យមានប្រវត្តិរូបពាក់ព័ន្ធ អាហ្នឹងខ្ញុំនិយាយមិនបានជាឯកសារអីចេញមកពីណាទេ គេប្រជុំក្នុងអង្គភាព គឺដូចថា ឥឡូវគាត់ មេបញ្ជាការខ្ញុំអ៊ីចឹង ឬក៏ថ្នាក់វរសេនាធំ ឬក៏កងពលអ៊ីចឹង អាហ្នឹងមិនមែនចេញជា វាមានឯកសារក្រដាសស្នាមអីទេ គឺអង្គភាពហ្នឹងគឺកំណត់ប្រជុំថា ឥឡូវមូលដ្ឋានហ្នឹងត្រូវយកមូលដ្ឋាន មិនឲ្យពាក់ព័ន្ធជាមួយអ្នក១៧មេសា ឲ្យពាក់ព័ន្ធអីហ្នឹង ខ្លាចជាប់ប្រវត្តិរូបដែលវាមិនច្បាស់លាស់នេះ។ អាក្លាប់ប្រវត្តិរូបមិនបាននេះ ដល់អ៊ីចឹងវាពាក់ព័ន្ធនឹងទៅយកមក ដល់មើលប្រវត្តិរូបក្រោយលែងជាប់ស៊្មីគេទៅ កា.ហ្សេ.បេ។ ស្រាប់ការហើយមិនទាន់បានពីរបីថ្ងៃ ចោទទៅ សេ.អ៊ី.អា។ អ៊ីចឹងវាអស់កម្មាភិបាលត្រូវធ្លាក់ ឬក៏ជាប់ពាក់ព័ន្ធបញ្ហាហ្នឹងបញ្ហាហ្នឹងក្នុងអង្គភាពប្រជុំគឺសំខាន់ គេលះបង់ច្បាស់ត្រង់ថា ឲ្យដាច់ខាត ត្រង់ថាត្រូវគិតគូរជាមូលដ្ឋានថាឲ្យរឹងប៉ឹង នេះជាស្នូល ជាស្នូលគឺស៊្មី។ សម្ព័ន្ធយុវកក ជនចម្រើន សម្ព័ន្ធយុវកក បក្ខជន អាហ្នឹងក្នុងអង្គប្រជុំ តែមិនមានក្រដាសស្នាមអីទេ គឺជាអង្គភាពប្រជុំ។ អាហ្នឹងជាទូទៅ គឺពង្រឹងបញ្ហាហ្នឹង រឹងមាំប៉ុណ្ណឹង។ អាហ្នឹងចង់និយាយដល់អ៊ីចឹង ដូចជាការបង្ខិតបង្ខំឲ្យហើយ។ ដូចថា ឥឡូវខ្ញុំស្រឡាញ់ឈ្មោះក នារី១៧ខ្ញុំមិនអាចទៅយកបាន បើតាមការយល់នោះ ព្រោះយកម៉េច បើគេបង្ខំឲ្យទៅយកឯណោះឯណាផ្សេងអ៊ីចឹងទៅ។" សូមបញ្ចប់ការដកស្រង់។

[១៤:០៦:៤១]

អនុសាសន៍សម្រាប់ការផ្គូផ្គងគូស្រករជាញឹកញាប់ ត្រូវតែអនុម័តដោយអាជ្ញាធរថ្នាក់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ហើយរបាយការណ៍នានា ត្រូវបានគេធ្វើឡើងតាមឋានានុក្រម មទាក់ទងនឹងការរៀបការដើម្បីបង្ហាញថា គោលនយោបាយនោះបាននឹងកំពុងត្រូវបានអនុវត្ត។ នៅក្នុងស្លាយនេះជាឧទាហរណ៍ដែលយើងអាចមើលឃើញមន្ទីរភូមិភាគបស្ចិមកំពុងរាយការណ៍ជូនមជ្ឈិមបក្សថា មាន ៤២គូ បានរៀបការនៅក្នុងខែកក្កដា ឆ្នាំ១៩៧៨។ ភស្តុតាងក៏បង្ហាញផងដែរថា បក្សកុម្មុយនីស្តកម្ពុជាក្នុងការបង្កើតសហជីពគ្រួសារ ដើម្បីផលិតកូនឲ្យអង្គការ ក្នុងពេលជាមួយគ្នាក៏មានការព្រួយបារម្ភថាចំណងគ្រួសារណាដែលបានផលិតចេញមក មិនមែនជាការដណ្តើមយកនូវភាពស្មោះត្រង់របស់បុគ្គលនោះចំពោះបក្សកុម្មុយនីស្តកម្ពុជាឡើយ។

ដូចខ្ញុំបានជម្រាបជូនហើយថា ពិធីរៀបការជាញឹកញាប់មានការពាក់ព័ន្ធនឹងការសន្យាដើម្បីបម្រើអង្គការ និង ជួនកាលមានការណែនាំឲ្យ ខ្ញុំសូមដកស្រង់ "មានកូនសម្រាប់អង្គការ"។ សូមបញ្ចប់ការដកស្រង់។ បន្ទាប់ពីរៀបការរួច គូស្រករជាញឹកញាប់ត្រូវបានអនុញ្ញាតឲ្យជួបគ្នាពីរបីថ្ងៃរៀងរាល់ខែ

គ្រប់គ្រាន់សម្រាប់ការមានផ្ទៃពោះ ប៉ុន្តែមិនមែនសម្រាប់ចំណងគ្រួសារធំដុំទេ។ ចំណងបុគ្គលរឹងមាំចំពោះអ្នកដទៃ ត្រូវបានហាមឃាត់នៅក្រោមរបបនេះ ថាជាការបង្កើតនូវ សូមដកស្រង់៖ "ទ្រព្យសម្បត្តិឯកជនស្នេហា ដែលបានហាមឃាត់"។ សូមបញ្ចប់ការដកស្រង់។

លោក ខៀវ សំផន បានធ្វើបទបង្ហាញឲ្យក្រុមបញ្ញវន្តមួយក្រុមដែលទើបវិលត្រឡប់មកវិញថា ទ្រព្យសម្បត្តិឯកជន សតិអារម្មណ៍ដែលបានហាមឃាត់ដូច្នេះ រួមមាន ខ្ញុំសូមដកស្រង់៖ "ឪពុកម្តាយរបស់អ្នក សមាជិកគ្រួសាររបស់អ្នក ប្រពន្ធរបស់អ្នក"។ សូមបញ្ចប់ការដកស្រង់។

សម្តេចឪព្រះនរោត្តម សីហនុ ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការបង្ខាំងព្រះកាយនៅក្នុងផ្ទះនៅក្នុងរាជធានីភ្នំពេញ បានរំឭកអំពីអន្តរសកម្មភាពស្រដៀងគ្នា ដែលបានធ្វើជាមួយលោក ខៀវ សំផន ដែលមាននៅក្នុងវីដេអូឃ្លីបដូចតទៅ សូមបង្ហាញខ្សែវីដេអូឃ្លីបលេខ៦។

[១៤:១០:០៩]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ខ្ញុំត្រូវបានគេផ្តាច់ចេញ។ ខ្ញុំជួបតែមនុស្សម្នាក់គត់គឺ ខៀវ សំផន គឺថាខ្ញុំជួបគាត់ម្តងម្កាល នៅពេលដែលគាត់មកដល់វាំងហ្នឹង គឺដើម្បីមកគ្រាន់តែថាថ្វាយបង្គំព្រះអង្គ។សុខសប្បាយដែរទេ។ ហើយខ្ញុំពេលខ្លះខ្ញុំត្រូវសុំអនុញ្ញាតពី ខៀវ សំផន ឬក៏ពី ប៉ុល ពត ដើម្បីរៀបចំ ឧទាហរណ៍ថារៀបចំខួបចម្រើនព្រះជន្ម ឬក៏ខួបអាពាហ៍ពិពាហ៍ អាចថាខ្ញុំសូមឲ្យបុត្រ ឬក៏ចៅរបស់ខ្ញុំមកជួប។ ប៉ុន្តែជួនកាលគាត់ថាអត់ទេ អត់ឲ្យទេ ពួកគេនៅឆ្ងាយពីទីក្រុងភ្នំពេញ ពួកគេមានសុខភាពល្អទេ ដូច្នេះកុំ -- ព្រះអង្គមិនត្រូវរស់នៅបែបជាក្រុមគ្រួសារបែបនេះទេ នេះជារបបកុម្មុយនីស្តថ្មីមួយ យើងត្រូវគិតអំពីប្រទេសតែប៉ុណ្ណោះ មិនត្រូវគិតអំពីក្រុមគ្រួសារបែបនេះឡើយ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:១១:១៨]

បាទ ជា ខៀប ដែលធ្លាប់ធ្វើការនៅក្រសួងពាណិជ្ជកម្មបានរំឭកអំពីលោក ខៀវ សំផន ដែលបានណែនាំថា ខ្ញុំសូមដកស្រង់៖ "កុំអាល័យគិតតែម៉ែឪ នឹកម៉ែឪ គិតតែខំប្រឹងធ្វើការជូនបក្ស ជូនរដ្ឋទៅរឿងម៉ែឪទុកមួយឡែក។" សូមបញ្ចប់ការដកស្រង់។ ហើយគាត់បានបន្តទៀតថា អង្គការនិយាយថា ខ្ញុំសូមដកស្រង់៖ "ក្រោមការគ្រប់គ្រងរបស់អង្គការ មិនមែនទៅចាំម៉ែឪ អាល័យតែទៅរកម៉ែឪទៀតទេ គឺអង្គការម៉ែឪហើយ។" សូមបញ្ចប់ការដកស្រង់។ ខណៈដែលសេចក្តីពិស្តារអំពីរបៀបនៃការផ្គូផ្គងគូ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្រករ ដំណើរការនៃពិធីរៀបការ និងអ្វីដែលកើតនៅពីក្រោយ មានភាពស្រដៀងគ្នាយ៉ាងទូលំទូលាយជាច្រើនក៏ដោយ ដោយសារការអនុវត្តយ៉ាងរីករាលដាលនៃគោលនយោបាយនេះ តាមពិតមានភស្តុតាងអំពីការប្រែប្រួលខ្លះៗដែរ។ ខ្ញុំក៏សូមបញ្ជាក់ឲ្យបានច្បាស់ផងដែរថា វាមិនមែនជាគោលជំហររបស់អយ្យការទេដែលថា គ្រប់គូស្រករទាំងអស់ នៅក្នុងការរៀបការទាំងអស់ ក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ សុទ្ធតែត្រូវបានបង្ខំឲ្យរៀបការនោះទេ។ តាមពិតមានភស្តុតាងបញ្ជាក់ថា មានកម្មាភិ-បាលមានសំណាងខ្លះ ឬក៏បុគ្គលដែលមានការអនុគ្រោះខ្លះ ត្រូវបានអនុញ្ញាតឲ្យរៀបការជាមួយដៃគូតាមជម្រើសរបស់ពួកគេផងដែរ។ ប៉ុន្តែវាសឹងតែជាទូទៅទៅហើយ ដែលថាអ្នកដែលបានរៀបការហើយ មិនមានជម្រើសណាមួយ ថាតើត្រូវរៀបការឬអត់នោះទេ ទោះបីអ្នកនោះជាកម្មាភិបាលថ្នាក់ខ្ពស់ ឬជាប្រជាជនថ្មីដែលងាយរងគ្រោះក៏ដោយ។

ម៉ឹង វ៉េត បានផ្តល់ភស្តុតាងថា មានគូស្រករខ្លះត្រូវផ្គូផ្គងឲ្យរៀបការដោយសារកម្មាភិបាលបុរស ជាអ្នកជ្រើសរើសដៃគូណាមួយ។ ចំណែកអ្នកផ្សេងទៀតត្រូវបាន ខ្ញុំសូមដកស្រង់៖ “ជ្រើសរើសដោយចោះៗឲ្យមានគ្រួសារ។” សូមបញ្ចប់ការដកស្រង់។ យ៉ាងណាមិញ គាត់ច្បាស់ណាស់ថា សូមដកស្រង់៖ “នារីមិនអាចបដិសេធបានទេ” សូមបញ្ចប់ការដកស្រង់។

យើងក៏ទទួលស្គាល់ផងដែរថា ខណៈដែលគូស្រករជាច្រើន ដែលត្រូវបានបង្ខំឲ្យរៀបការបានបែកបាក់គ្នានៅក្រោយការដួលរលំនៃរបបខ្មែរក្រហម។ ហើយក៏មានអ្នកខ្លះមិនបែកបាក់គ្នាដែរ អាស្រ័យដោយមូលហេតុខុសៗគ្នាជាច្រើន។ សេចក្តីសម្រេចទាំងនោះ គឺជារឿងផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗដែលពាក់ព័ន្ធ ហើយក៏មិនជាប់ពាក់ព័ន្ធនឹងពិរុទ្ធរបស់ជនជាប់ចោទសម្រាប់ឧក្រិដ្ឋកម្មទាំងនេះដែរ។

[១៤:១៥:៥០]

នៅទូទាំងដំណើរការនៃការផ្គូផ្គងការរៀបការ និងការរួមដំណេក ជនរងគ្រោះត្រូវបង្ខំដោយជាក់ស្តែង និងមិនជាក់ស្តែង រហូតដល់កម្រិតមួយដែលធ្វើឲ្យពួកគាត់គ្មានជម្រើសពិតប្រាកដ ថាតើខ្លួនត្រូវរៀបការជាមួយនរណា? ថាតើគួររៀបការដែរឬអត់? និងថាតើត្រូវចុះសម្រុងរួមដំណេកជាមួយអ្នកដែលខ្លួនបានរៀបការដែរឬទេ? ការបង្ខិតបង្ខំបានកើតឡើងយ៉ាងជាក់ស្តែងតាមការគំរាមកំហែង ការធ្វើបាប និងការសម្លាប់ជនណាដែលហ៊ានប្រឆាំងនឹងការរៀបការ ឬមិនព្រមចុះសម្រុងក្នុងការរួមដំណេក។ ការបង្ខិតបង្ខំបានកើតឡើងមិនជាក់ស្តែងតាមរយៈបរិយាកាសគួរឲ្យភ័យខ្លាចដែលបានបង្កើត

ឡើងដោយខ្មែរក្រហម ធ្វើឲ្យមនុស្សភាគច្រើនដែលដឹងថា ខ្លួននឹងត្រូវគេរៀបចំឲ្យមានគ្រួសារមិនមានលទ្ធភាពដើម្បីបដិសេធ ហើយបើហ៊ានធ្វើដូច្នោះ ខ្លួននឹងត្រូវទទួលរងនូវការធ្វើបាបមួយយ៉ាងដំណំនៅក្នុងបរិយាកាសមួយដែលពួកគាត់កំពុងតែជួបការលំបាកសឹងតែមិនអាចរស់បាន ឬក៏ស្លាប់រួចទៅហើយនោះ។ បរិយាកាសបង្ខិតបង្ខំនេះ ត្រូវបានបង្កើតឡើងតាមរយៈវិធីសាស្ត្រខុសៗគ្នាជាច្រើន រួមមានការព្រមានមិនឲ្យសួរនាំអង្គការ ការធ្វើបាបយ៉ាងវេទនា សូម្បីតែចំពោះការប្រព្រឹត្តខុសសីលធម៌តូចតាចទោះជារឿងពិត ឬដោយការសន្មតក៏ដោយ ដូចជាការបេះផ្លែស្វាយ ឬការធ្វើឲ្យបាក់ស្លាបព្រាមួយជាដើម។ ប្រជាជននៅក្រោមគេទាំងស្រុង គ្មានសិទ្ធិ ឬអង្គការជាអ្នកតម្រង់ទិសឲ្យដែលអង្គការជាអ្នកមានអំណាច ហើយអង្គការដឹងអ្នកដែលហ៊ានប្រឆាំង ឬបដិសេធមិនព្រមរៀបការ ត្រូវបានធ្វើបាប ឬក៏សម្លាប់ចោល។

នៅក្នុងបរិយាកាសនេះ ការព្រមព្រៀងដោយខ្លួនឯងពិតប្រាកដក្នុងការរៀបការដែលកំណត់ដោយអង្គការ គឺមិនអាចទៅរួចទេ អ្នកដែលត្រូវបានណែនាំឲ្យរៀបការដោយស្របច្បាប់ភ័យខ្លាចថា បើមានការបដិសេធណាមួយ ពួកគាត់នឹងត្រូវបានគេចាត់ទុកថាជាខ្មាំង ហើយអាចទទួលលទ្ធផលនូវការផ្តន្ទាទោសយ៉ាងដំណំចំពោះការមិនគោរពអង្គការ ដូចជាត្រូវបញ្ជូនទៅកសាង អប់រំឡើងវិញ ឬក៏សម្លាប់ចោលជាដើម។ មនុស្សភាគច្រើនបំផុតដែលអង្គការបានជ្រើសរើសឲ្យមានគូស្រករមិនហ៊ានបញ្ចេញការជំទាស់របស់ខ្លួនឡើយ ដូច្នេះមានន័យថា ពួកគេត្រូវបានបង្ខំឲ្យរួមរស់នៅជាមួយគ្នានៅក្នុងសម្ព័ន្ធភាពជាប្តីប្រពន្ធ។ អ្នកណាដែលរារែក ឬហ៊ានបដិសេធចំពោះបទបញ្ជាឲ្យរៀបការ ជាញឹកញាប់តែងត្រូវបានគេគំរាមកំហែងចំៗ ឬត្រូវដាក់ទណ្ឌកម្មតែម្តង។

ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា បានរៀបរាប់ពីរបៀបដែលជាបរិយាកាសបង្ខិតបង្ខំដែលបង្កើតឡើងដោយបក្សកុម្មុយនីស្តកម្ពុជា ដែលបានធ្វើចំពោះបងស្រីគាត់ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ តាមរយៈវីឌីអូឃ្លីបដូចតទៅ។ សូមចាក់វីឌីអូឃ្លីបលេខ៧។

[១៤:១៩:១៧]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ដល់បន្ទាប់មកទៀតមក វាចាប់បង្ខំបងស្រីខ្ញុំរៀបការ បងខ្ញុំទើបចូល១៥ឆ្នាំ ចូល១៦កាលនុំង។ បងខ្ញុំអត់ព្រមទេ ម៉ាក់ខ្ញុំក៏គាត់ទៅសុំថាមិន អត់បានទៅរៀបការ ដូចថាគាត់នៅក្មេងអីចឹង មិនចង់ឲ្យរៀបការអីចឹង មានគូដណ្តឹងហើយ គាត់អត់ចង់ឲ្យ តែគេអត់ព្រមទេ បើៗយើងរឹងទទឹង យើងខ្លាចមាន*

*គេធ្វើបាប អ៊ីចឹងក៏គាត់សុខចិត្តរៀបការទៅ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:១៩:៤៧]

អ្នកស្រី ង៉ែត ចាត នៅចាំបានអំពីការដេញដោលរឿងផ្ទៃក្នុងដែលបង្ខំឲ្យគាត់សន្យានៅក្នុងពេលរៀបការថ្មីមួយ បន្ទាប់ពីប្តីទី១របស់គាត់គឺខ្មែរក្រោមដែលត្រូវបានគេយកទៅសម្លាប់ ដែលមានក្នុងវីដេអូឃ្លីបដូចតទៅ។ សូមបញ្ចាំងវីដេអូឃ្លីបលេខ៨។

[១៤:២០:២០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"គេបានឲ្យរួមដំណេកថា ខំប្តេជ្ញាចិត្តយកគ្នាទៅ ខំបង្កបង្កើតកូនឲ្យបានច្រើន ឲ្យបានមានកូនមានអី។ ខ្ញុំមានកូនអី បើមនុស្សស្គម ហូបតែបបរបានអីនឹងមានកូន បើអត់មានកម្លាំងកំហែងអីផង។ ប៉ុន្តែមិនប៊ានថាទេ ប៉ុន្តែប្តេជ្ញាចេះតែស្រែកតែប្តេជ្ញា ទះដៃអ៊ីចឹង ចេះតែទះដៃនឹងគេអ៊ីចឹងទៅ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:២០:៤៧]

លោក មូល អេង ដែលជាកម្មាភិបាលម្នាក់ បានរៀបរាប់អំពីការដែលខ្លួនគាត់ត្រូវបានគេបង្ខំឲ្យរៀបការ និងណែនាំឲ្យរៀបការអ្នកដទៃទៀត។ គាត់ពីដំបូងបានបដិសេធការរៀបការរបស់គាត់។ សូមដកស្រង់នូវ*ស្លាយ*លេខ១៥០ដល់១៥១៖ "ខ្ញុំបដិសេធដែរ ព្រោះខ្ញុំមិនស្រឡាញ់ប្រពន្ធខ្ញុំទេ តែគេមិនទទួលទេ ហើយគេថា បើយើងមិនគោរពអង្គការទេ យើងគិតខ្លួនឯងទៅ។ បាទ វាជាការព្រមាន ព្រោះខ្ញុំអាចមានគ្រោះថ្នាក់ដល់ជីវិត បើខ្ញុំមិនគោរពតាមការសម្រេចរបស់អង្គការទេ។ យើងចំបាច់ត្រូវតែរួមដំណេកជាមួយប្រពន្ធយើង ព្រោះគេនៅជិតហ្នឹង ចាំមើលសភាពការណ៍ក្រែងលោមិនស្រួល។ មូល អេង បន្ទាប់មកទៀតបានក្លាយជាលេខស្រុកមួយ (ភូមិភាគពាយ័ព្យ) ជាទីកន្លែងដែលគាត់ត្រូវបានគេណែនាំឲ្យរៀបចំការរៀបការសម្រាប់មនុស្សផ្សេងទៀត។ គាត់បានរំឭកពីតួយ៉ាងដែលមាននារីពីរនាក់បានជំទាស់នឹងការរៀបការរបស់ពួកគេ។ ហើយគាត់ត្រូវបានគេណែនាំឲ្យប្រាប់នារីពីរនាក់នោះថា វាជាភារកិច្ចស្នេហាជាតិរបស់ពួកគេ ដើម្បីរៀបការជាមួយទាហានពិការ ដែលត្រូវបានជ្រើសរើសឲ្យធ្វើជាប្តីរបស់ពួកនាង។ ក្រោយមកពួកគេព្រមរៀបការទាំងក្រៀមក្រំ។" សូមបញ្ចប់ការដកស្រង់។

រស់ ស៊ីុយ បាននិយាយថា ខ្ញុំសូមដកស្រង់៖ "អ្នកខ្លះដែលត្រូវបានគេចាត់តាំងឲ្យរៀបការ មិន

ហ៊ានប្រកែកនឹងការចាត់តាំងនោះទេ ព្រោះខ្លាចគេធ្វើបាប។ គេចេះតែឆ្លើយថា ព្រម ព្រោះខ្លាច។ ថ្វីបើមើលពីក្រៅទៅ ហាក់ដូចជាមិនមានការបង្ខំ ប៉ុន្តែតាមពិតមានការបង្ខំផ្លូវចិត្តឲ្យទទួលយក ជាពិសេសគឺខ្លួនខ្ញុំផ្ទាល់តែម្តង។ ក្នុងចំណោម២០គូដែលបានរៀបការដំណាលខ្ញុំ មានតែគូខ្ញុំទេដែលនៅដល់សព្វថ្ងៃ។" សូមបញ្ចប់ការដកស្រង់។

ជាំង ស្រីមុំ បានបន្លឺឡើងនូវមនោសញ្ចេតនាដូចគ្នាបេះបិទនេះដែរ នៅក្នុងសក្ខីកម្មរបស់គាត់ជូនចំពោះតុលាការ។ គាត់មិនចង់រៀបការទេ ប៉ុន្តែព្រមដោយសារមានការភ័យខ្លាច ដែលមាននៅក្នុងវីដេអូឃ្លីបដូចតទៅ។ សូមបញ្ចាំងវីដេអូឃ្លីបលេខ៩៖

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"គឺអង្គការ គឺសម្រេចតែរៀបចំទៅលើអ្នកណាមួយហើយ គឺយើងអត់មានប្រឆាំងជាមួយបក្សបានទេ។ ទោះបីតែយើងមិនពេញចិត្តយ៉ាងណាក៏ដោយ ក៏យើងត្រូវតែសម្រេចចិត្ត សង្រួមចិត្តនូវការក្នុងការភ័យខ្លាចរហូត។ ការស្រឡាញ់គ្នា មិនស្រឡាញ់គ្នាក៏ត្រូវតែស្រឡាញ់ដែរពេលហ្នឹង។ តែយើងដាក់ចិត្តថា រួមជាមួយក្នុងគ្រួសារមែនពិត ប៉ុន្តែចិត្តវាអត់មានទាន់ ចិត្តស៊ីចង្វាក់គ្នាចំពោះប្តីរបស់ខ្ញុំក៏អ៊ីចឹងចំពោះខ្ញុំក៏អ៊ីចឹងដែរ។ ប៉ុន្តែនៅក្នុងការភ័យខ្លាច ត្រូវតែដាក់ចិត្តនៅក្នុងពេលហ្នឹង។ បើកាលណាយើងមិនស្របទៅតាមការចាត់តាំងរបស់បក្សទេ គឺខ្ញុំដឹងប្រាកដថា ខ្ញុំមានគ្រោះថ្នាក់ដល់ជីវិត។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:២៤:៤៤]

បាទ ពៅ គឿន ជាកម្មាភិបាលបានទទួលបញ្ជាឲ្យរៀបចំការរៀបការជាច្រើនលើកច្រើនសា។ ពេលសួរថា តើមាននរណាម្នាក់បដិសេធទេ? គាត់ឆ្លើយថា ខ្ញុំសូមដកស្រង់៖ "មិនមានអ្នកណាហ៊ានប្រកែកទេ ក្រោយរៀបការហើយបើមានខាងណា ប្រុស ឬស្រី មិនព្រមចុះសម្រុង គេនឹងបញ្ជូនអ្នកនោះទៅរៀនសូត្រ តែខ្ញុំមិនដឹងគេបញ្ជូនទៅកន្លែងណាទេ។" សូមបញ្ចប់ការដកស្រង់។

មនុស្សម្នាក់ក្នុងចំណោមអ្នកទាំងឡាយដែលមិនហ៊ានប្រកែកនោះ គឺដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ដែលបានមកផ្តល់សក្ខីកម្មចំពោះមុខតុលាការ។ កុល ណែម បានប្រាប់តុលាការពីរបៀបដែលរូបគាត់មានគូដណ្តឹងហើយ តែត្រូវបានខ្មែរក្រហមផ្គូផ្គងឲ្យរៀបការជាមួយនារីផ្សេងទៀត។ សូមដាក់បញ្ចាំងវីដេអូឃ្លីបលេខ១០ បាទ។

[១៤:២៦:០២]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"គេថា អ្នាក! ក្រែងទៅមើលគេ ចុះម៉េចមិនប្រាប់ខ្ញុំថាទៅមើលគេ បើខ្ញុំអត់ដឹងផង គ្រាន់ថា ឲ្យទៅលេង។ ខ្ញុំទៅលេង មិនមើលឯណា បាទ។ អាហ្នឹងក៏ចប់ទៅ។ គេថា បើអ៊ីចឹង ឲ្យគិតទៀត ដល់ហ្នឹងបានស្អែកទៀត គេឲ្យខ្ញុំមកទៀត មកជាន់អង្ករជាមួយគេតែម្តង បាទ ជាន់អង្ករនៅកន្លែងតំបន់ ក-១១ ហ្នឹង។ ជាន់អង្ករទៅ គេបង្អាប់ចុះ បង្អាប់ឡើងបានដឹង។ ដល់ដឹង បានគេសួរខ្ញុំថា ពេញចិត្តអត់ទេ? គេថាអ៊ីចឹង។ បានខ្ញុំថា ខ្ញុំអត់ទាន់ដឹង។ អ៊ីចឹងគេកំណត់ឲ្យខ្ញុំ៣ថ្ងៃ ឲ្យគិតមើល ហ្នឹងហើយ។ បើយើងមិនយក អាហ្នឹងថ្ងៃក្រោយទទួលខុសត្រូវខ្លួនឯង គេនិយាយមួយម៉ាត់ហ្នឹង។ ខ្ញុំក៏គិត៣ថ្ងៃ ហូបបាយក៏មិនចូលដែរ។ អាហ្នឹងហើយ ផ្លូវចិត្តរបស់ខ្ញុំ ព្រោះខ្ញុំមានគូដណ្តឹងនៅស្រុក បានខ្ញុំគិតអ៊ីចឹង។ ដល់នឹកគិតយូរៗ បាន៣ថ្ងៃ ខ្ញុំថា បើគិតវែងខ្លី វែងពេក មិនបាន សុខចិត្ត បាន៣ថ្ងៃ ក៏គេមកសួរទៀត។ ដល់គេសួរ ខ្ញុំក៏ឯកភាពជាមួយគេថា ការក៏ការទៅធ្វើម៉េចទេ ប៉ុន្តែក្នុងចិត្តនៅ នៅដដែល បាទនៅក្តៅដដែល។ គេបង្ខំ ព្រោះយើងមានគូដណ្តឹងនៅស្រុក។ ដូច្នេះ ប៉ុន្តែក្នុងចិត្តថា ការក៏ការចុះក្រែងលោបានរស់ បានឃើញមេឃ ឃើញផ្កាយនឹងគេ ក្រែងលោបានដឹងសាច់រឿង សាច់ហេតុ។ អាហ្នឹងក្នុងចិត្តរបស់ខ្ញុំ ខ្ញុំនិយាយត្រង់។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:២៧:៤០]

ម៉ឹង វេត បាននិយាយថា ខ្ញុំសូមដកស្រង់៖ 'ខ្ញុំមិនដែលឃើញមានអ្នកណាហ៊ានប្រកែកទេ ព្រោះពួកគេគោរពតាមគោលការណ៍បក្ស។ ម្នាក់ៗសុទ្ធតែខ្លាចដូចគ្នា។" សូមបញ្ចប់ការដកស្រង់។ គោលបំណងចុងក្រោយនៃការរៀបការដូចដែលបានលើកឡើងរួចហើយនេះគឺដើម្បីបង្កើនចំនួនប្រជាជន តាមរយៈការបង្កើតកុមារហើយដើម្បីធ្វើដូច្នេះបាន ទាល់តែមានការរួមដំណេកនៅពេលរៀបការរួច។ ចំពោះមនុស្សជាច្រើន ពិធីរៀបការរបៀបនេះ គ្រាន់តែជាមធ្យោបាយមួយសម្រាប់ការរំលោភសេពសន្ថវៈស្របច្បាប់តែប៉ុណ្ណោះ។

សយ ណារឿន បានផ្តល់សក្ខីកម្មថា នៅក្នុងពិធីរៀបការរបស់គាត់ ខ្ញុំសូមដកស្រង់៖ 'អង្គការទាំងនោះបានហៅមួយគូៗឡើងប្តេជ្ញាចិត្ត។ មុននឹងប្តេជ្ញាចិត្ត គេបានថា បើត្រូវធ្វើតាមអង្គការកំណត់ត្រូវនិយាយតាមអង្គការដាក់ឲ្យ ឲ្យអ្នកទាំងពីរនាក់ប្តេជ្ញាចិត្ត ឲ្យស្រឡាញ់គ្នាចាប់ពីពេលនេះតទៅ បង្កបង្កើនផលឲ្យបានច្រើន ពី១ហិកតាប៉ុន្មានតោន ទៅប៉ុន្មានតោន តាមការកំណត់របស់អង្គការ។ ឲ្យបង្ក

បង្កើតឈាមមនុស្សឲ្យបានច្រើន ដោយតម្រូវទៅតាមអង្គការត្រូវការមនុស្សច្រើន ដើម្បីការពារទឹកដី។ មុននឹងខ្ញុំប្ដេជ្ញា គឺថ្នាក់លើបានណែនាំឲ្យខ្ញុំនិយាយអ៊ីចឹង និយាយឲ្យដូចគេថាអ៊ីចឹង។” សូមបញ្ចប់ការដកស្រង់។

ព្រាប យឿន បានរំឭកពីសេចក្ដីប្រកាសមួយស្រដៀងគ្នានេះ នៅក្នុងពិធីរៀបការរបស់គាត់ផងដែរ ដោយនិយាយថា ខ្ញុំសូមដកស្រង់៖ ‘មុនពេលចាប់ផ្ដើមរៀបការនេះ គឺ សូ បានប្រកាសនៅក្នុងអង្គប្រជុំទូទៅថា អង្គការត្រូវការកម្លាំងបន្ថែម ដូច្នេះគេត្រូវការឲ្យយុវជន យុវនារី រៀបការដើម្បីបង្កើតកូនបន្ថែមទៅលើកម្លាំងកសាងបដិវត្តន៍។”សូមបញ្ចប់ការដកស្រង់។

ដើម្បីធានាថាការរួមភេទនេះបានកើតឡើង គូស្រករត្រូវធ្វើតាមបែបផែន ដោយចំណាយពេលពីរបីយប់នៅជាមួយគ្នា នៅក្រោយការរៀបការ ហើយពួកគេត្រូវបានគេតាមឃ្លាំមើល ដើម្បីឲ្យប្រាកដថា ពួកគេបានរួមភេទ។

កុល សែត ដែលជាកម្មាភិបាលម្នាក់បានថ្លែងថា គាត់ត្រូវបានគេបញ្ជាឲ្យ ខ្ញុំសូមដកស្រង់៖ “ខ្ញុំទៅដើរស្ដាប់ និងស៊ើបអ្នកណាដែលទើបរៀបការ បន្ទាប់មកត្រូវរាយការណ៍ទៅឲ្យគេវិញ។ គេចង់ដឹងថា អ្នកណាខ្លះនិយាយពីអង្គការ អ្នកណាខ្លះដែលរៀបការហើយ មិនព្រមដេកជាមួយគ្នា គឺខ្ញុំត្រូវរាយ-ការណ៍ទៅគេ”។ គាត់ក៏បាននិយាយផងដែរថា៖ “ពួកអ្នកដែលប្រកែកមិនព្រមរៀបការ ឬមិនព្រមរួមដំណេកជាមួយគ្នា នឹងត្រូវបានគេយកទៅអប់រំ ហើយបន្ទាប់មកត្រូវបានបាត់ខ្លួន។” សូមបញ្ចប់ការដកស្រង់។

[១៤:៣១:២០]

គូស្រករដែលបានរួមដំណេកនៅពេលអាពាហ៍ពិពាហ៍ គឺស្ថិតនៅក្នុងសេនារីយោជាច្រើនយ៉ាងកាលណាមានការយល់ព្រម មិនត្រូវបានផ្ដល់ឲ្យដោយសេរីដោយដៃគូម្នាក់ ឬដៃគូពីរនាក់ ហើយដូច្នេះបង្កើតបានជាការរំលោភសេពសន្ថវៈ។ ទាំងបុរស និងទាំងស្ត្រី គឺជាជនរងគ្រោះ ព្រោះថាជួនកាលអ្នកទាំងពីរមានអារម្មណ៍ដឹងថា ត្រូវបានគេបង្ខំឲ្យរួមភេទ ដោយពុំមានការយល់ព្រមដោយសេរីពីពួកគេឡើយ។ មានមនុស្សជាច្រើននាក់បានយកចិត្តទុកដាក់នឹងការរួមភេទ ពីព្រោះពួកគេបានដឹងខ្លួនថា ពួកគេត្រូវបានគេតាមដានឃ្លាំមើល ហើយបើខកខានមិនបានធ្វើដូច្នោះ អាចបណ្ដាលឲ្យមានការដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ឬរហូតដល់ការសម្លាប់។ ដូចដែល ជាំង ស្រីមុំ បានផ្ដល់សក្ខីកម្មថា ខ្ញុំសូមដកស្រង់៖ “ពេលនោះ ខ្ញុំក៏ដឹងថាមានឈ្លប ខ្ញុំក៏សម្រួលចិត្ត ឥតមានបញ្ហាអីកើតឡើងជាមួយប្ដីប្រពន្ធទេ គឺដេក

ស្ងប់ ដោយស្ងប់ស្ងៀមស្ងាត់។" សូមបញ្ចប់ការដកស្រង់។

នៅក្នុងតួយ៉ាងផ្សេងទៀត ពួកបុរសបានគំរាមថា នឹងរាយការណ៍ពីប្រពន្ធរបស់គេ បើពួកគេមិនបានរួមដំណេកនឹងគ្នា។ ដោយដឹងថាការបដិសេធមិនព្រមធ្វើដូច្នេះ គឺអាចដាក់ទណ្ឌកម្មបាន ហើយពួកបុរសផ្សេងខ្លះទៀត បានបង្ខំខ្លួនគេទៅលើប្រពន្ធពួកគេ។ នៅពេលដែលគូស្រករត្រូវបានរកឃើញថាមិនបានរួមដំណេកនឹងគ្នាទេនោះ អ្នកទាំងនោះត្រូវបានគេអប់រំ គំរាមកំហែងដាក់ទណ្ឌកម្ម ឬក៏សម្លាប់ចោល។

ជាថ្មីម្តងទៀត ភស្តុតាងនៅក្នុងសំណុំរឿងលេខ០០២នៃការអនុវត្តនេះ គឺមានច្រើន។ ១០នាក់ដែលបានផ្តល់សក្ខីកម្មថា ជាជនរងគ្រោះពីការបង្ខំឱ្យរួមភេទ។ ខណៈពេលដែល១៩នាក់ផ្សេងទៀតបានផ្តល់ភស្តុតាងជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត អំពីបញ្ហាបង្ខំរួមភេទនេះដែរ។ ប្រាំមួយនាក់បានផ្តល់សក្ខីកម្មថា បានឃើញដោយផ្ទាល់ភ្នែកនូវការបង្ខំឱ្យរួមភេទ។ ខណៈដែលបីនាក់បានផ្តល់ភស្តុតាងជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងរឿងនេះដែរ។ សាក្សី២៩នាក់បានផ្តល់សក្ខីកម្មថា ការរួមភេទនៅក្រោយអាពាហ៍ពិពាហ៍ត្រូវបានគេដាក់បញ្ញត្តិ ឬឃ្លាំមើល។ ខណៈដែល៤១នាក់ផ្សេងទៀតបានផ្តល់ភស្តុតាងជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងរឿងនេះដែរ។

ព្រាប សុឃឿន បានផ្តល់សក្ខីកម្មថា នៅក្រោយការបដិសេធមិនព្រមរួមភេទនៅក្នុងអាពាហ៍-ពិពាហ៍ជាមួយនឹងប្តីពិការរបស់គាត់ គាត់ត្រូវបានគេដឹកដោយរទេះទៅកាន់ផ្ទះមួយផ្សេងទៀត ជាកន្លែងដែលគាត់ត្រូវបានគេប្រាប់ថា គាត់នឹងត្រូវបានសម្លាប់ ប្រសិនបើគាត់មិនព្រមរួមភេទទេ។ គាត់បានរៀបរាប់ជូនអង្គជំនុំជម្រះនូវអ្វីដែលកើតឡើងក្រោយមកទៀតនៅក្នុងយប់នោះ ហើយមានដូចនៅក្នុងវីដេអូឃ្លីបដូចតទៅ។ បាទ សូមបញ្ចាំងវីដេអូឃ្លីបលេខ១១។

[១៤:៣៥:២៧]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ខ្ញុំក៏ឡើងទៅលើវិញ ដល់ខ្ញុំឡើងទៅលើវិញ គាត់ចេះតែបបួលថាដេកទៅ ស្គមហើយអត់ងងុយមិត្តឯងចេះតែរត់ ខ្ញុំប្តីសោះមិត្តឯងអី១ ចេះតែលួងលោមខ្ញុំ។ ដល់ខ្ញុំអត់ងងុយពីរបីយប់ដែរ ដល់ពេលហ្នឹងក៏ខ្ញុំដេកលក់ទៅ លក់ទៅដឹងខ្លួនឡើងក៏ឃើញគាត់ឱបខ្ញុំរឹតខ្ញុំហ្នឹងទៅ ខ្ញុំរើបម្រះ ដល់រើបម្រះគាត់វាថៃដន្យថា ទឹកចិត្តបុរសពេលឃើញស្ត្រីក៏គាត់ចាប់ខ្ញុំហែកអាវ ហែកខោខ្លីខ្ញុំ អាវទ្រនាប់ខ្ញុំដាច់ឡើវអស់ទៅ ក៏គាត់ចាប់ផ្តើមរំលោភខ្ញុំ ខ្ញុំក៏យំ ខ្ញុំស្រែកទៅ គាត់ថាកុំស្រែកខ្មាស់គេ យើងប្តីប្រពន្ធទេ ហ្នឹងលើកទី*

*១ដំបូង។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:៣៦:១៧]

ព្រាប សុឃឿន បានរៀបរាប់ពីរបៀបដែលប្ដីរបស់គាត់បានសូមទោស ក្រោយពីបានរំលោភគាត់រួចហើយ ដោយបានប្រាប់គាត់ថា សូមដកស្រង់៖"ធ្វើតាមបញ្ជាអង្គការ" សូមបញ្ចប់ការដកស្រង់។ ដូចគ្នានេះដែរ ប៉ែន សុចាន់ បានរ៉ាយរ៉ាប់ជូនអង្គជំនុំជម្រះអំពីរបៀបដែលគាត់ត្រូវបានចងភ្ជាប់នឹងសសរដោយសមាជិកកងឈ្លប ហើយប្ដីរបស់គាត់បានរំលោភគាត់ បន្ទាប់ពីគាត់បានតស៊ូអស់ពីរយប់មក។ គាត់បានផ្ដល់សក្ខីកម្មថា គាត់មានឈាមហូរមួយខែជាង បន្ទាប់ពីត្រូវបានរំលោភ។ សយ ណារឿន បានផ្ដល់សក្ខីកម្មថា គាត់បានឃើញគូស្រករត្រូវបានចាប់ខ្លួន ហើយបានសន្និដ្ឋានថា ដោយសារតែពួកគាត់មិនបានត្រូវគ្នា។ ដោយសារតែមានការភ័យខ្លាចត្រូវបានចាប់ខ្លួន គាត់ក៏សម្រេចចិត្តរួមដំណេកជាមួយប្ដីរបស់គាត់ទៅ។ ខ្ញុំសូមដកស្រង់ ក្នុង*ស្លាយ*លេខ១៥៩៖ "ខ្ញុំមានអារម្មណ៍ញ័រ មានអារម្មណ៍ចុកណែនក្នុងទ្រូង ក្នុងខ្លួន ដើមទ្រូងរបស់ខ្ញុំចង់គាំងបេះដូងដុំៗ។ ដោយមួយជីវិតខ្ញុំ តាំងពីខ្ញុំដឹងក្ដីមក ខ្ញុំពុំដែលជួបប្រទះ ខ្លួនខ្ញុំជាស្ត្រីខ្មែរមួយរូប អ្វីៗក៏វាមិនសំខាន់ដល់ស្មើនឹងខ្លួនរបស់នាងខ្ញុំដែរ។ តែនាងខ្ញុំសុខចិត្តញាក់ញ័រដូចកូនសត្វ យ៉ាងណាក៏ដោយក៏នាងខ្ញុំសុខចិត្តថា នៅស្ងៀមដើម្បីឲ្យប្ដីបម្រើទៅតាមចំណង់ចំណូលចិត្តរបស់គាត់រួមភេទ ព្រោះគាត់បានប្ដេជ្ញាចិត្តនៅមុខអង្គការ។" សូមបញ្ចប់ការដកស្រង់។

[១៤:៣៨:១៧]

យូ វ៉ាន់ ដែលជាលេខាឃុំ នៅភូមិភាគកណ្ដាល បានផ្ដល់សក្ខីកម្មថា គាត់នៅចាំបានថា លេខាស្រុកបានប្រាប់គាត់ថា លេខាតំបន់បានធ្វើច្បាប់មួយថា ប្ដីនិងប្រពន្ធត្រូវតែដេកជាមួយគ្នា ដើម្បីភាពរីកចម្រើនជឿនលឿននៃប្រទេស។ យូ វ៉ាន់ ក៏បានផ្ដល់សក្ខីកម្មផងដែរថា ប្រជាជនដែលបានបដិសេធមិនព្រមរួមដំណេកជាមួយគ្នាបន្ទាប់ពីរៀបការ ខ្ញុំសូមដកស្រង់ត្រង់*ស្លាយ*លេខ១៦២ដល់១៦៤៖ "មាន ប៉ុន្តែអប់រំមួយដងជាពីរដងអ៊ីចឹងទៅ វាក៏ព្រមទៅ។" សូមបញ្ចប់ការដកស្រង់។ គាត់បានបន្តនៅក្រោយនេះបន្តិចថា សូមដកស្រង់៖ "កាលណាអប់រំទៅ គឺវាតាមទៅ វាអត់ឃើញបាត់ដែរ។" បញ្ចប់ការដកស្រង់។

តទៅនេះ ខ្ញុំសូមត្រឡប់ទៅរកការលើកឡើងអំពីអំណះអំណាងមួយចំនួន ដែលជនជាប់ចោទបានលើកឡើង ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបង្ខំរំលោភសេពសន្ថវៈនៅក្នុងសារណារបស់ពួកគាត់។ ខណៈដែលមេធាវីការពារក្ដីទទួលស្គាល់ការប៉ុនប៉ងរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បី

បង្កើនចំនួនប្រជាជន ហើយការរៀបការនោះត្រូវបានរៀបចំដោយបក្សកុម្មុយនីស្តកម្ពុជា។ ពួកគាត់អះអាងថា គោលនយោបាយរៀបការដោយបក្សកុម្មុយនីស្តកម្ពុជានោះ តម្រូវឱ្យមានការយល់ព្រមទៅវិញទៅមករវាងដៃគូទាំងសងខាង។ ពួកគាត់យកសម្អាងផ្នែកដ៏ធំនៃអំណះអំណាងរបស់ពួកគាត់ នៅលើសេចក្តីថ្លែងនៅក្នុងបញ្ជីមួយ ដែលគេហៅថា "ច្បាប់បដិវត្ត" ដែលអះអាងដោយពិតថា ភាគីទាំងសងខាងត្រូវតែយល់ស្របគ្នារៀបការ។ ពួកគាត់អះអាងថាច្បាប់ទី៦ បានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវពីចេតនារបស់បក្សកុម្មុយនីស្តកម្ពុជា មិនត្រឹមតែទស្សនៈបែបដូច្នោះទេ ដែលបដិសេធទាំងស្រុងដោយភស្តុតាងជាច្រើនឥតគណនានៃអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយការរួមសង្វាសនៅក្នុងសំណុំរឿង រួមទាំងកម្រិតខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជាផង ដែលនៅចំពោះមុខអង្គជំនុំជម្រះនេះ ប៉ុន្តែក្រឡេកមើលច្បាប់ដទៃទៀត នៅក្នុងបញ្ជីដូចគ្នាបានដាក់ឱ្យឃើញនូវភាពមិនស្មោះត្រង់នៃសេចក្តីថ្លែងផ្សព្វផ្សាយទាំងនេះ វាមានភាពខុសគ្នាទាំងស្រុងពីការពិតនៃគោលនយោបាយរបស់ខ្មែរក្រហម។

[១៤:៤១:១៧]

ជាទឹកតាង ការបញ្ជាយ៉ាងក្អេងក្អាងមួយផ្សេងទៀតនៅក្នុងបញ្ជីដដែលនោះ ខ្ញុំសូមដកស្រង់៖ "កុំធ្វើអ្វីដែលប៉ះពាល់ដល់ប្រជាជនឱ្យសោះ សូម្បីតែម្ទេសមួយគ្រាប់ ឬពាក្យមួយម៉ាត់។" សូមបញ្ចប់ការដកស្រង់។ មានភស្តុតាងបង្ហាញថា ច្បាប់ទាំងនេះ ទោះជាគោលបំណងរបស់វា នៅពេលដែលគេផ្សព្វផ្សាយនៅក្នុងឆ្នាំ១៩៧៨ក៏ដោយ ក៏វាមិនឆ្លុះបញ្ចាំងពីការពិតដែលប្រជាជនកម្ពុជាបានទទួលរងតាមទិសដៅរបស់ជនជាប់ចោទ។ ពិតមែនហើយ បើសិនជាមានការពិតណាមួយទៅនឹងសេចក្តីថ្លែងនោះដែលថាភាគីទាំងសងខាងត្រូវតែយល់ស្របទៅនឹងការរៀបការនោះ គឺនៅក្នុងវិញ្ញាណដ៏ស្ញើងរបស់ភាគីដែលត្រូវបានបង្ខិតបង្ខំឱ្យបញ្ជាក់ពីការព្រមព្រៀងរៀបការតាមរយៈការភ័យខ្លាច និងការសម្លុតគំរាមកំហែង។ ជាញឹកញយ ការមិនព្រមព្រៀងបណ្តាលឱ្យមានការដាក់ទណ្ឌកម្ម ឬការសម្លាប់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:០១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងជាតិដើម្បីបន្តការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ជាបន្តខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមម្តងទៀតនិងភាគីទាំងអស់ ដែលមានវត្តមាននៅទីនេះ។ ខ្ញុំសូមបន្តសេចក្តីសន្និដ្ឋានជាបន្តទៀត។ នួន ជា អះអាងថា មិនមានឧទាហរណ៍ជាក់លាក់ណា ឬមូលហេតុជាសត្យានុម័តអំពីមូលហេតុដែលបានព្រមព្រៀងដោយស្មោះត្រង់និងដោយសេរី មិនអាចធ្វើទៅបាននោះទេ។ យើងបានផ្តល់ជូនភស្តុតាងនេះយ៉ាងទូលំទូលាយនៅក្នុងសារណារបស់យើងខ្ញុំ ហើយខ្ញុំបានលើកយកឧទាហរណ៍មួយចំនួនរួចហើយនៅទីនេះ។ ខ្ញុំនឹងលើកបង្ហាញនូវឧទាហរណ៍មួយចំនួនទៀតដើម្បីបញ្ជាក់បង្ហាញដូចតទៅ។ ណុប ងឹម ធ្លាប់ជាអនុលេខាស្រុក ជាកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដ៏គួរឲ្យទុកចិត្តម្នាក់ប្រកបដោយប្រវត្តិកសិករល្អដូច្នេះទទួលបានបុព្វសិទ្ធិកម្រិតខ្ពស់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ ទោះជាយ៉ាងណា នៅពេលដែល តា ម៉ុក ស្នើឡើងថា គាត់ត្រូវបានរៀបការជាមួយយុទ្ធជនពិការដែលរូបគាត់មិនដែលបានជួបនោះ គាត់បានយំសោក ប៉ុន្តែមិនហ៊ានបដិសេធទេ។ គាត់បានផ្តល់សក្ខីកម្មថា យុទ្ធជនពិការខ្មែរក្រហមនោះបានបញ្ជូនមកកន្លែងរបស់គាត់ ដូច្នេះពួកគេត្រូវតែរៀបការ។ ហើយថា គាត់បានរៀបការរួមគ្នាជាមួយអ្នករៀបការចំនួន៤០គូផ្សេងទៀតនៅក្នុងពេលជាមួយគ្នានោះដែរ។ តាមសក្ខីកម្មរបស់គាត់ ៗបានរៀបរាប់អំពីអារម្មណ៍របស់គាត់ អំពីការរៀបការជាមួយយុទ្ធជនដែលបានពិការភ្នែកក្នុងពេលប្រយុទ្ធឈ្មោះ ព្រាបកប ដែលមានបង្ហាញនៅក្នុងវីដេអូឃ្លីបដូចតទៅ។ សូមចាក់បញ្ចាំងវីដេអូឃ្លីបលេខ១២៖

[១៥:០៣:៤១]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ចាស ខ្ញុំ គាត់ការនៅសំឡូត ការ៤០គូ។ តែបីម៉ោងទេ ៤០ ចាប់ដាក់ ចាប់ដាក់។ អាខ្លះយំ អាខ្លះស្រែក អាខ្លះរត់ចោល។ រត់ចោលពីរនាក់។ (ភាសាអង់គ្លេស)។ ខ្ញុំយំមែនហ្នឹង ប៉ុនអន់ចិត្តអត់ដឹងខ្លួន*

*សោះ អន់ចិត្ត អត់ចិត្តមាំណាស់ ព្រោះអីអត់ដែលឃើញ -- វាដែលឃើញ ធ្លាប់ឃើញគ្នា កាលនៅទ័ព ដូចគ្នា ប៉ុន្តែដល់ចាប់ដាក់អ៊ីចឹង ខ្ញុំអន់ចិត្ត។ ខ្ញុំចង់រត់ដែរ ប៉ុន្តែខ្លាចគេវៃចោល កុំអីរត់បាត់ហើយ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:០៤:៣៩]

ប្ដីរបស់ ណុប ងឹម ដែលមានឈ្មោះ ព្រាប កប ត្រូវបានស្ដាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេត។ ហើយគាត់បានរៀបរាប់អំពីការរៀបការ តាមទស្សនៈរបស់គាត់។ គាត់បានលើកឡើងថា គាត់គ្រាន់តែបានដឹងថា គាត់ត្រូវរៀបការនៅពេលព្រឹកនៃថ្ងៃរៀបការនោះ ពោលគឺនៅពេលដែល តាម៉ុក ប្រាប់គាត់តែប៉ុណ្ណោះ។ គាត់បានថ្លែងថា ខ្ញុំសូមដកស្រង់៖ "គ្មាននរណាសួរខ្ញុំថា ចង់រៀបការ ឬអត់ទេ? តែយើងត្រូវធ្វើតាមបញ្ជា និងការណែនាំរបស់គេ។ បើមិនដូច្នោះទេ យើងនឹងមានបញ្ហា។" សូមបញ្ចប់ការដកស្រង់។

ទាក់ទងនឹងការរួមភេទដោយបង្ខំ ឈួន សារឿន ជាកម្មករធ្វើការនៅភូមិភាគពាយ័ព្យបានប្រាប់ទៅអ្នកស៊ើបអង្កេតថា ខ្ញុំសូមដកស្រង់៖ "ក្រោយការរៀបការរួច គឺមានឈ្លបមកតាមដានដល់ផ្ទះ។ ឧទាហរណ៍ចំពោះករណីរបស់ខ្ញុំ គេបានហៅខ្ញុំទៅសួរនាំ ក្រោយពេលរៀបការថា បានរស់នៅជាមួយគ្នាចុះសម្រុង ឬអត់? ខ្ញុំបានប្រាប់គេថា យើងបានរស់នៅជាមួយគ្នាចុះសម្រុង ដោយសារនារីនោះ ជាប្អូនស្រីជីដូនមួយរបស់ខ្ញុំ។ ប៉ុន្តែប្រសិនបើភាគីបុរស បាននិយាយថា ភាគីស្ត្រី មិនព្រមរស់នៅចុះសម្រុងគ្នាទេ នោះពួកខ្មែរក្រហមបានបញ្ជាឲ្យគូស្រករនោះរួមភេទជាមួយគ្នា ដោយមានពួកឈ្លបនៅឃ្លាំមើលលួចស្ដាប់។ បើសិនស្ត្រីនៅតែបដិសេធទៀតនោះ គេនឹងយកស្ត្រីនោះ ទៅសម្លាប់ចោល។ ករណីមួយទៀត គឺប្ដីបង្ខំប្រពន្ធរួមភេទ ប៉ុន្តែប្រពន្ធបដិសេធ ហើយក្រោយមក មេកងបានហៅប្រពន្ធទៅអប់រំដោយប្រាប់ឲ្យប្រពន្ធរួមភេទជាមួយប្ដីរបស់គាត់។ ពេលនោះប្រពន្ធរបស់គាត់បានយល់ព្រមរស់នៅជាមួយប្ដី ប៉ុន្តែក្រោយឆ្នាំ១៩៧៩ ប្ដីប្រពន្ធនេះ បានលែងលះគ្នា។" សូមបញ្ចប់ការដកស្រង់។

[១៥:០៦:៥៣]

រឿងស្រដៀងគ្នាបែបនេះ មានច្រើនសន្ធឹកសន្ធាប់ណាស់ដែលត្រូវរៀបរាប់ ដូចមានភស្តុតាងនៅក្នុងសំណុំរឿងនេះហើយ។ សាក្សី ថង់ ធឿយ បានបញ្ជាក់ថា ខាងក្រុមរបស់គាត់ មានគេរៀបការរួមគ្នា ខ្ញុំសូមដកស្រង់៖ "មានស្ត្រីពីរទៅបីនាក់ ត្រូវបានឈ្លបយកទៅសម្លាប់ដោយសារស្ត្រីទាំងនោះ មិនព្រមរួមដំណេក។" បញ្ចប់ការដកស្រង់។ សាក្សី ម៉ៅ គ្រឿន បានប្រាប់អ្នកស៊ើបអង្កេតថា ខ្ញុំសូមដក

ស្រង់៖ "ខ្មែរក្រហមគំរាមថា អ្នកដែលបដិសេធមិនព្រមរួមដំណេក បន្ទាប់ពីរៀបការរួច អាចត្រូវចាប់ដាក់គុក។" បញ្ចប់ការដកស្រង់។

យោងតាមការសិក្សារបស់ ថេរេសា ដឺ ឡេងហ្គី ស្ដីពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម នៅក្នុងអត្ថបទមានចំណងជើងថា "ដូចខ្មោចប្រែរូប" ដើមបណ្ដឹងរដ្ឋប្បវេណី ចំនួន ១០៦នាក់ នៅក្នុងសំណុំរឿងលេខ០០២ បានរាយការណ៍ថា ពួកគេត្រូវបានស្នើឲ្យរៀបការក្នុងអំឡុងពេលរបបខ្មែរក្រហម ដោយមានពួកគេចំនួ១០៣នាក់ ក្នុងចំណោមពួកគេទាំងនោះ បានរាយការណ៍ថា ពួកគេបានធ្វើតាម។ អ្នកឆ្លើយតបចំនួន៧២នាក់បានរាយការណ៍ថា ត្រូវបានបង្ខំឲ្យរៀបការតាមរយៈការគំរាមកំហែង ពាក្យសម្ដីដែលមានចំនួន៧៥ភាគរយ។ ១៨នាក់ភ័យខ្លាចទណ្ឌកម្ម ដែលស្មើហ្នឹង ១៨,៨ភាគរយ និងប្រាំនាក់ ដោយសារអំពើហិង្សាលើរាងកាយ។ ភាគច្រើននៃអ្នកឆ្លើយតបបានរាយការណ៍អំពីការគំរាមកំហែង ឬការដាក់ទណ្ឌកម្មចំពោះការបដិសេធមិនព្រមរៀបការ។ ៤៨នាក់ បានរាយការណ៍ថា ត្រូវបានគេគំរាមតាមពាក្យសម្ដី ចំពោះការបដិសេធនោះ។ ប្រាំនាក់ត្រូវបានឃុំឃាំង និងពីរនាក់ ត្រូវបានធ្វើទារុណកម្ម។ ៤២,៨ភាគរយនៃអ្នកឆ្លើយតប បានរាយការណ៍ថា ត្រូវបានបង្ខំឲ្យរួមដំណេក ដោយខ្លាចបាត់បង់ជីវិត។

ក្រុមមេធាវីការពារក្ដី ព្យាយាមបន្ថយគោលនយោបាយរួមសង្វាស និងអាពាហ៍ពិពាហ៍ដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយអះអាងថា ក្នុងបរិបទវប្បធម៌របស់កម្ពុជា គោលនយោបាយទាំងអស់នេះ មិនបង្កគ្រោះថ្នាក់ ឬចាកឆ្ងាយពីភាពធម្មតានោះឡើយ។ ពួកគេបានប្រៀបប្រដូចអាពាហ៍-ពិពាហ៍ដែលបានកើតឡើងទាំងនោះ ទៅនឹងដំណើរការមួយដែលឪពុកម្ដាយបានចូលរួមក្នុងការរៀបចំអាពាហ៍ពិពាហ៍ឲ្យកូនៗរបស់ខ្លួន។

[១៥:១០:០៥]

លោក ខៀវ សំផន បានយោងសំអាងភស្ដុតាងបន្ថែមទៀត ដោយអះអាងថា អាពាហ៍ពិពាហ៍តាមប្រពៃណីកម្ពុជាជាចម្បង មិនផ្អែកលើការស្រឡាញ់គ្នានោះទេ។ ក្នុងការបង្កើតអំណះអំណាងនេះ មេធាវីការពារក្ដីជាមូលដ្ឋានភ័ន្តច្រឡំអំពីឧក្រិដ្ឋភាពនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ វាមិនមែនអវត្តមានការស្រឡាញ់នោះ ធ្វើឲ្យអាពាហ៍ពិពាហ៍ដោយបង្ខំជាបទឧក្រិដ្ឋនោះទេ ហើយការចូលរួមរបស់ឪពុកម្ដាយរបស់គេក្នុងដំណើរការជ្រើសរើសដៃគូ ធ្វើឲ្យអាពាហ៍ពិពាហ៍ដោយបង្ខំនោះជាបទឧក្រិដ្ឋនោះក៏ទេដែរ។ ប៉ុន្តែអ្វីដែលពិតជាធ្វើឲ្យអាពាហ៍ពិពាហ៍ដោយបង្ខំជាបទឧក្រិដ្ឋនោះគឺ នៅពេលដែលរដ្ឋដើរតួនាទី

ក្នុងការជ្រើសរើសដៃគូគ្រួសារ និងបង្ខំទៅលើមនុស្សឲ្យយកដៃគូ ដាក់ទណ្ឌកម្មពួកគេយ៉ាងធ្ងន់ធ្ងរ ប្រសិនបើពួកគេបដិសេធជម្រើសនោះ និងបង្ខំបុគ្គលនានាឲ្យរួមសង្វាសក្នុងអាពាហ៍ពិពាហ៍បែបនោះ ដោយមិនមានការយល់ព្រមពីពួកគេ ដែលជាលទ្ធផលនាំឲ្យកើតមាននូវព្យសនកម្មផ្លូវចិត្ត និងពេលខ្លះផ្លូវកាយធ្ងន់ធ្ងរ និងទុក្ខវេទនាដល់ជនរងគ្រោះ។ អាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្មែរក្រហម និងការរំលោភសេពសន្ថវៈ មិនមានអ្វីដូចគ្នាទៅនឹងការរៀបមង្គលការតាមប្រពៃណីរបស់ខ្មែរនោះទេ។

ជាមួយគ្នានេះដែរ ការធ្វើឲ្យទៅជាទាសករ មិនដូចគ្នាទៅនឹងការងារដែលទទួលបានប្រាក់កម្រៃនោះដែរ។ គេអាចនិយាយបានថា ទាំងពីរនេះពាក់ព័ន្ធនឹងការងារដូចគ្នា ប៉ុន្តែចុងបញ្ចប់នៃភាពស្រដៀងគ្នានោះគឺមួយជាឧក្រិដ្ឋកម្ម ខណៈមួយទៀតមិនមែនជាឧក្រិដ្ឋកម្ម។ គួរឲ្យសោកស្តាយការប្រៀបធៀបមិនសមហេតុផលរបស់មេធាវីការពារក្តីក្នុងការប៉ុនប៉ងមួយដើម្បីកាត់បន្ថយព្យសនកម្ម ដែលគោលនយោបាយនេះបានបង្កឡើងលើជនរងគ្រោះនោះមិនបញ្ចប់ត្រឹមនោះទេ។

នៅក្នុងសារណារបស់គាត់ លោក នួន ជា បានប្រៀបធៀបកម្មវិធីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈទៅនឹងកិច្ចខិតខំប្រឹងប្រែង ដែលប្រទេសបានអនុវត្តដើម្បីបង្កើនកំណើនប្រជាជន តាមរយៈការផ្តល់ជូននូវមជ្ឈមណ្ឌលបន្តពូជ និងសេវាកម្មផ្គូផ្គង និងបញ្ជាក់ថា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលអនុវត្តចំពោះអនុសញ្ញាអន្តរជាតិស្តីពីការស្ម័គ្រចិត្តព្រមរៀបអាពាហ៍ពិពាហ៍។ គាត់បានរៀបរាប់អំពីការរៀបអាពាហ៍ពិពាហ៍ទ្រង់ទ្រាយធំដោយបង្ខំថា ខ្ញុំសូមដកស្រង់៖ "ជាការសម្រេចចិត្តបែបសាមញ្ញ និងសន្សំសំចៃ"។ បញ្ចប់ការដកស្រង់ និងមិនលើសពីក្តីប្រាថ្នារបស់គាត់ ដែលថាវាមានលក្ខណៈដូច្នោះ កំណត់ថាឈ្លប ដែលតាមដានគូស្រករទាំងឡាយ ដើម្បីមើលថា តើពួកគេបានរួមដំណេក ឬអត់នោះ គឺគ្រាន់តែជាកងកម្លាំងប៉ូលិសធម្មតា ដែលព្យាយាមការពារភូមិតែប៉ុណ្ណោះ។

[១៥:១៣:៥៩]

ដូចដែលខ្ញុំបានរៀបរាប់ខាងលើ កុល សែត ដែលជាឈ្លប ពិតជាមិនបានបំពេញមុខងារជាប៉ូលិសធម្មតានោះទេ នៅពេលដែលគាត់បានប្រាប់អ្នកស៊ើបអង្កេតថា រូបគាត់ទទួលបានការណែនាំថាត្រូវរាយការណ៍អំពីគូស្រករណា ដែលបដិសេធមិនព្រមរួមដំណេកជាមួយគ្នា។ សាក្សី រី ពៅ ក៏បដិសេធដែរនៅពេលគាត់ផ្តល់សក្ខីកម្មថា គាត់និងសមាជិកកងរបស់គាត់ផ្សេងទៀត ខ្ញុំសូមដកស្រង់៖ "គេណែនាំឲ្យពិនិត្យមើលសកម្មភាពរបស់គូស្រករ ដែលរៀបការហើយថ្មី ថាតើគេចុះសម្រុងជាមួយគ្នា

ល្អដែរឬទេ ឬក៏ពួកគេពិតជាបានរួមដំណេកដែរឬទេ?” បញ្ចប់ការដកស្រង់។

ចំពោះអនុសញ្ញាស្តីពីការព្រមស្ម័គ្រចិត្តរៀបការបានតម្រូវថា ខ្ញុំសូមដកស្រង់៖ “ការរៀបការត្រូវតាមច្បាប់ លុះត្រាតែមានការយល់ព្រមពេញលេញ និងដោយសេរីពីគូភាគី។” បញ្ចប់ការដកស្រង់។ របៀបរបបគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដាក់ចេញ មិនត្រូវនឹងបទដ្ឋានអន្តរជាតិឡើយ។ ចំពោះផ្នែករបស់លោក ខៀវ សំផន គាត់បានអះអាងថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាការរីកចម្រើនលើអាពាហ៍ពិពាហ៍បែបប្រពៃណី និងថាការរៀបការអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាការប្តូរបន្តិចបន្តួចពីការចូលរួមរបស់ឪពុកម្តាយក្នុងការជ្រើសរើសដៃគូសម្រាប់កូនៗរបស់ពួកគេ ទៅឱ្យរដ្ឋាភិបាលដើរតួនាទីនោះជំនួសវិញ។

សក្ខីកម្មដែលតុលាការនេះបានស្តាប់និងភស្តុតាងផ្សេងៗទៀត ទាក់ទិននឹងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងសំណុំរឿងនេះបង្ហាញថា ជនរងគ្រោះមិនបានចាត់ទុកថា អាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាការរីកចម្រើកលើអាពាហ៍ពិពាហ៍បែបប្រពៃណីនោះទេ តែជាការផ្ទុយពីនេះទៅវិញ។ ពួកគេភាគច្រើនមានអារម្មណ៍ថា ត្រូវបានគេប្លន់យកវត្ថុដ៏សំខាន់បំផុតមួយ ក្នុងជីវិតវ័យក្មេងរបស់ខ្លួន គឺសិទ្ធិជ្រើសរើសដៃគូជីវិត និងរៀបពិធីមង្គលការ ដោយមានក្រុមគ្រួសារ និងមិត្តភក្តិចូលរួម ជាប្រពៃណីដែលបានចាក់ស្រែះក្នុងមង្គលការរបស់ខ្មែរអស់រយៈពេលជាច្រើនជំនាន់មកហើយ។ ទាំងលោក នួន ជា និងលោក ខៀវ សំផន បានលើកឡើងដោយភ័ន្តច្រឡំអំពីភស្តុតាងរបស់ជំនាញ ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនេះ។ កាស៊ូមិ ណាកាហ្កាវ៉ា បានផ្តល់សក្ខីកម្មថា មិនមានគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ ដែលនេះជាការបំភ្លៃសក្ខីកម្មរបស់គាត់យ៉ាងច្បាស់លាស់។ តាមពិតអ្វីដែលអ្នកជំនាញ ណាកាហ្កាវ៉ា បានថ្លែងទាក់ទងនឹងបញ្ហានេះ គឺថារូបគាត់មិនបានស៊ើបអង្កេតឱ្យជាក់លាក់ ថាតើមានគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអត់នោះទេ។ ហើយហេតុដូច្នេះ រូបគាត់មិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីកំណត់ ថាតើមានគោលនយោបាយមួយនេះ ឬអត់នោះទេ? ទោះជាយ៉ាងណាគាត់អាចធ្វើការសន្និដ្ឋានបានថា ខ្ញុំសូមដកស្រង់៖ “មានលំនាំប្រហាក់ប្រហែលគ្នានេះ ស្តីពីការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម។” បញ្ចប់ការដកស្រង់។ គាត់ក៏បានផ្តល់សក្ខីកម្មផងដែរ ថាភស្តុតាងរបស់គាត់បានបង្ហាញថា អាពាហ៍ពិពាហ៍ដោយបង្ខំបានកើតមានឡើងនៅក្នុងបណ្តាខេត្តភាគច្រើនក្នុងប្រទេសកម្ពុជា និងថា ខ្ញុំសូមដកស្រង់៖ “នៅចុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ មានករណីទ្រង់ទ្រាយធំជាច្រើន ដែលត្រូវបានធ្វើឡើងតែរវាងក្រុមអ្នកដែលគេបង្ខំឱ្យរៀបការ។” បញ្ចប់ការដកស្រង់។

[១៥:១៨:៣១]

លោក នួន ជា ក៏បានលើកឡើងផងដែរថា អ្នកជំនាញ ផេហ្គី ឡឺវ៉ាញ បានផ្តល់សក្ខីកម្មថា មិនមានគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ ហើយលោក ខៀវ សំផន បានយោងអំណះអំណាង ផេហ្គី ឡឺវ៉ាញ សម្រាប់គំនិតដែរថា គូស្រករមិនបានចាត់ទុកថា អាពាហ៍ពិពាហ៍ជាការចាប់បង្ខំនោះទេ។ ប៉ុន្តែនេះគឺជាការសន្និដ្ឋានមិនគួរឲ្យភ្ញាក់ផ្អើលពីអ្នកដែលបានទទួលស្គាល់នៅក្នុងតុលាការថារូបគាត់បានខិតខំយ៉ាងខ្លាំងដើម្បីមិនសួរគូស្រករនៅក្នុងការសិក្សារបស់គាត់ ថាតើពួកគេមានអារម្មណ៍ថា អាពាហ៍ពិពាហ៍របស់ខ្លួនត្រូវបានបង្ខំ ឬអត់នោះ។ ដូច្នេះទស្សនៈរបស់ ឡឺវ៉ាញ បានលើកសំណួរនោះ គឺមិនមានលក្ខណៈជូនដំណឹងពេញលេញដោយការតាក់តែង ផ្តោតតាមគោលបំណងផ្ទាល់ខ្លួនរបស់គាត់នោះទេ។ គួរចាប់អារម្មណ៍ កត់សម្គាល់ថា កាទ្រីណា ណាតាលី នៅក្នុងការសិក្សារបស់គាត់ស្តីអំពីហិង្សាផ្នែកយេនឌ័រ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងខេត្តបាត់ដំបង និងស្វាយរៀង បានសម្ភាសអ្នកឆ្លើយតបចំនួន១០៤នាក់ នៅក្នុងខែកញ្ញា និងខែតុលា ឆ្នាំ២០១០ ដែលមានអាយុចន្លោះពី៤២ឆ្នាំ និង៨៤ឆ្នាំ។ ហើយទោះបីជាពួកគេមិនត្រូវបានសួរអំពីអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយក៏ ខ្ញុំសូមដកស្រង់៖ "ជិត២០នាក់ បានលើកឡើងអំពីបញ្ហានេះដោយខ្លួនឯង។ ពួកគេសង្កត់ធ្ងន់អំពីកង្វះខាតជម្រើស ដែលបុគ្គលម្នាក់ៗមានក្នុងការជ្រើសរើសគូស្រកររបស់ខ្លួន និងការភ័យខ្លាច ដែលនាំឲ្យមានមនុស្សជាច្រើនយល់ព្រមរៀបការ។ ពួកគេក៏បានត្អូញត្អែរអំពីវិធីមិនសមរម្យ ដែលពិធីរៀបការត្រូវបានធ្វើឡើង និងបានរាយការណ៍អំពីការរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនោះ។

[១៥:២១:០២]

យ៉ាងណាមិញ អ្នកឆ្លើយជាច្រើនបានកំណត់អត្តសញ្ញាណការអនុវត្តការរៀបអាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហមថា ជាទិដ្ឋភាពសំខាន់មួយនៃអំពើហិង្សាដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។" បញ្ចប់ការដកស្រង់។ ជនជាប់ចោទទាំងពីរបានចង្អុលបង្ហាញថា បុគ្គលមួយចំនួនមានជម្រើសក្នុងកម្រិតណាមួយក្នុងអាពាហ៍ពិពាហ៍របស់ខ្លួន និងថាអ្នកផ្សេងទៀតដែលស្ថិតក្នុងមុខតំណែងមានអំណាច បានអះអាងថា អាពាហ៍ពិពាហ៍ដោយបង្ខំមិនបានកើតមានឡើងនៅក្រោមការត្រួតត្រារបស់ពួកគេទេ។ ដូចដែលខ្ញុំបានរៀបរាប់ជូនអង្គសវនាការរួចហើយ វាមិនមែនជាគោលជំហររបស់ការិយាល័យសហព្រះរាជអាជ្ញានោះទេ ដែលថាអាពាហ៍ពិពាហ៍ទាំងអស់នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ចាំបាច់ត្រូវតែបានបង្ខំសម្រាប់រាល់ដៃគូទាំងអស់

ដែលបានចូលរួមនោះឡើយ។ អ្វីដែលជាគោលជំហររបស់យើងនោះ គឺថាមានគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលក្រោមគោលនយោបាយនោះ មនុស្សជាច្រើនត្រូវបានរៀបការដោយបង្ខំ។ ដូច្នេះ អាទិភាពនៃអាពាហ៍ពិពាហ៍ប្រាកដ ដែលមិនត្រូវបានបង្ខំនោះ មិនបានធ្វើអ្វីទាល់តែសោះ ដើម្បីបន្ថយភស្តុតាងដ៏ច្រើន អំពីអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនោះ។ ទោះជាយ៉ាងណា ស្ទើរតែមិនមានអ្វីដែលគួរឱ្យភ្ញាក់ផ្អើលទេ ដែលថាសាក្សីពិតប្រាកដមួយចំនួន ដែលមានតួនាទីនៅក្នុងការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ ពេលខ្លះមានបំណងកាត់បន្ថយតួនាទីរបស់ខ្លួនក្នុងន័យមួយ ដែលពួកគេយល់ថាជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរប្រឆាំងនឹងប្រជាជនកម្ពុជា។ វាមិនភ្ញាក់ផ្អើលទេថា កម្មាភិបាលទាំងនោះខ្លួនឯងផ្ទាល់ដែលបានចូលរួមក្នុងឧក្រិដ្ឋកម្មទាំងនេះ និងបន្ថយភាពធ្ងន់ធ្ងរនៃគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ឬក៏បកស្រាយសេចក្ដីថ្លែងប្ដេជ្ញាចិត្ត និងការយល់ព្រមថាជារឿងពិត។ ទោះជាយ៉ាងណា អ្នកផ្សេងទៀតដែលស្ថិតក្នុងមុខតំណែងមានអំណាចដែរនោះ ក្នុងកម្រិតណាមួយ មានភាពស្មោះត្រង់ជាងអំពីអ្វីដែលពួកគេបានជួយក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ។

[១៥:២៣:៥៩]

ខ្ញុំបានរៀបរាប់ជូនអង្គសវនាការរួចហើយ អំពីឈ្មោះ ម៉ូល អេង និងឈ្មោះ ពៅ គឿន កម្មាភិបាលទាំងពីរបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ និងដែលបានសារភាពថា គូស្វាមីភរិយាត្រូវបានបង្ខំ។ ស្រដៀងគ្នានេះដែរ។ ស៊ូ សឿន ដែលជាលេខាស្រុក និងជាប្រពន្ធរបស់លេខាភូមិភាគកណ្ដាល កែ ពក បានទទួលស្គាល់ថា ខ្ញុំសូមដកស្រង់៖“គេមិនហ៊ានប្រកែកដែរ ទាំងស្រីទាំងប្រុស” បញ្ចប់ការដកស្រង់។ ហើយនៅពេលដែលសួរថា តើមាននារីណាក្នុងក្រុមរបស់គាត់បានបដិសេធការរៀបការឬអត់នោះ គាត់បានឆ្លើយថា ខ្ញុំសូមដកស្រង់៖ “មិនមានទេ កម្រណាស់ ទោះបីជាគេមិនពេញចិត្តក៏ដោយ ហើយក្រោយមកអ្នកទាំងនោះបានលែងលះគ្នា ក្រោយពីរបបខ្មែរក្រហមត្រូវបានដួលរលំ។” បញ្ចប់ការដកស្រង់។

លោក នួន ជា បានអះអាងថា មិនមានភស្តុតាងត្រូវបានផ្ដល់ក្នុងពេលសវនាការអំពីគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងភូមិភាគបូព៌ា ភូមិភាគបស្ចិម និងភូមិភាគពាយ័ព្យទេ។ ការណ៍នេះ ជាក់ស្ដែងមិនពិតនោះទេ។ មានសាក្សីប្រាំរូបបានផ្ដល់សក្ខីកម្មអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលបានកើតមានឡើងនៅក្នុងភូមិភាគបូព៌ា គឺឈ្មោះ អែម អឿន, សុះ រំលី, សៀង ចាន់ថី, អ៊ិន យឿង និង ម៉ី សាវឿន។ សាក្សីពីរនាក់បានផ្ដល់សក្ខីកម្មអំពីអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងភូមិភាគបស្ចិមគឺមានឈ្មោះ ប្រាក់ ឡឿន និង ឃិន វ៉ាត។ ហើយមានសាក្សីបួននាក់នៅក្នុងភូមិភាគពាយ័ព្យ គឺឈ្មោះ ផាន

វ៉ាន, កុល ណែម, ជិន សារឿន និង ស៊ុន វុធ។ លើសពីនេះទៀត សាក្សីចំនួន១២នាក់បានផ្តល់ភស្តុតាងទៅឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត អំពីអាពាហ៍ពិពាហ៍ដោយបង្ខំដែលបានកើតឡើងនៅក្នុងភូមិភាគបូព៌ា។ ពីរនាក់ក្នុងភូមិភាគបស្ចិម និងពីរនាក់នៅក្នុងភូមិភាគឦសាន។ តាមពិតនោះទាក់ទិនទៅនឹងភូមិភាគឦសាន លោក នួន ជា ហាក់ដូចជាបានបំភ្លេចអំពីសាក្សីម្នាក់ដែលគាត់ខ្លួនឯងផ្ទាល់បានស្នើសុំគឺមានឈ្មោះថា ជិន សារឿន។ គាត់បានផ្តល់ភស្តុតាងអំពីអាពាហ៍ពិពាហ៍ដែលបានរៀបចំឡើងនៅក្នុងខេត្តមណ្ឌលគិរី ដែលមាននៅក្នុងវីឌីអូឃ្លីបដូចតទៅ។ សូមចាក់បញ្ចាំងវីឌីអូឃ្លីបលេខ១៣។

[១៥:២៧:០៧]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"បាទ សូមអរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំ ១ចង់បញ្ជាក់ពីរឿងការរៀបការរបស់លោកបន្តិច។ លោកអំមិញបានបញ្ជាក់ជូនសហព្រះរាជអាជ្ញាជាតិហើយថា លោករៀបការនៅឆ្នាំប្រហែល ១៩៧៧ ថាតើពេលដែលលោករៀបការនោះ លោកស្គាល់ប្រពន្ធលោកមុន ឬក៏អត់ស្គាល់ទេ គេចាប់ផ្សំផ្គុំលោក? បាទ ចំពោះខ្ញុំផ្ទាល់ គឺស្គាល់គ្នាមុន បាទស្គាល់គ្នាមុន គឺមូលហេតុអី? គឺមេហ្នឹងគាត់ស្រឡាញ់ខ្ញុំ បាទ រាប់អានខ្ញុំជាប្អូនធម៌អីចឹងគឺគាត់ប្រាប់មុន។ ក្រោយមកឯងស្រឡាញ់អត់ នេះមិត្តនេះ អីចឹងគឺដឹងគ្នាហើយ។ ឯក្រៅពីហ្នឹង ហៅមកសួរបណ្តោយ បាទព្រមមិនព្រមអីគឺត្រូវតែព្រម។ អីចឹងបានន័យថាជាសំណាងតែលោកមួយទេ ក្រៅពីហ្នឹងអ្នកដទៃត្រូវបានគេបង្ខំ អីចឹងមែនទេបាទ? (ភាសាបារាំង) បាទស្គាល់ បាទស្គាល់គ្នាទៅវិញទៅមក ប៉ុន្តែគ្រាន់តែថាមួយណាជាគូអ្នកណា គឺអត់ដឹងទាំងអស់ ទាល់តែថ្ងៃដែលមេបញ្ជាការគាត់ហៅទាំងពីរហ្នឹងមក ទល់គ្នាហ្នឹង។ ឧបមាថាលោក ក ឯង ស្រឡាញ់នាង ខ អត់? អីចឹងគឺអត់ហ៊ានប្រកែកទេ ត្រូវតែស្រឡាញ់អីចឹងឯង បាទហ្នឹងគឺនៅជួបគ្នាគឺរៀបហ្នឹង សួរល្ងាចហ្នឹងស្អែកឡើងការទៅបណ្តោយ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:២៩:១៣]

ម៉ៅ ផាត់ ក៏បានផ្តល់ភស្តុតាងអំពីអាពាហ៍ពិពាហ៍ដោយបង្ខំនៅភូមិភាគឦសានផងដែរ។ គាត់បានប្រាប់អ្នកស៊ើបអង្កេតថា ខ្ញុំសូមដកស្រង់៖ "ឯការរៀបការគឺធ្វើឡើងដោយបង្ខំ មិនមានការស្ម័គ្រចិត្តពីគូភាគីទេ។" បញ្ចប់ការដកស្រង់។ ភូមិភាគបូព៌ាគឺជាភូមិភាគមួយផ្សេងទៀតដែលលោក នួន ជា ថ្លែងថាមិនមានសក្ខីកម្មទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំទេ។ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ម៉ី សារឿន

បានផ្តល់សក្ខីកម្មទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនៅភូមិភាគបូព៌ា ក៏ដូចជាថា តើបានប៉ះពាល់ដល់រូបគាត់យ៉ាងដូចម្តេច សូមអញ្ជើញទស្សនាវីដេអូឃ្លីបដូចតទៅ។ សូមបញ្ចាំងវីដេអូឃ្លីបលេខ១៤។

[១៥:៣០:០០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"មេកងចល័តហ្នឹង គឺកងចល័តនារីហ្នឹងគឺមានប្អូន-គ។ មួយ "គ"ហ្នឹងគឺមាន១០០នាក់។ ហើយកងចល័តប្រុសហ្នឹងគឺមានតែ១០០នាក់ទេ។ តែខ្ញុំហ្នឹងគឺនៅក្នុងចំណោត់ដែលគេចុះឈ្មោះថាយើងជាអ្នកទោសជាប់គុកហើយ គឺសន្តិសុខគេតាមរហូត គឺគេប្រមាញ់យើងរហូតបណ្តោយ។ ប៉ុន្តែដល់ពេលនោះ គឺកងចល័តហ្នឹងក៏មិនដឹងជា គេនឹកឃើញយ៉ាងម៉េចទេ ដែលខ្ញុំមានជាប់ប្រវត្តិរូបអ៊ីចឹងទៅ គេឲ្យយករៀបចាប់បង្ខំឲ្យរៀបការនៅកន្លែងសហករណ៍ព្រៃឈរហ្នឹងខេត្តព្រៃវែង ចំនួន៦១គូ។ ហើយខ្ញុំទើបតែបានមុនថ្ងៃរៀបការគេប្រកាសឲ្យរៀបការហ្នឹងមួយថ្ងៃគត់។ គេថាគូរបស់ខ្ញុំហ្នឹងគឺឈ្មោះ គង់ សុផាត។ ខ្ញុំហ្នឹងក៏នឹកឃើញស្រាវជ្រាវឈ្មោះ គង់ សុផាត ហ្នឹងគឺវាគ្នាច្រើនកងនារីប្អូនគងណោះ មិនដឹងមួយណាទេ។ សួរៗទៅបានដឹង ឃើញមុខ ហើយមិនបានដល់មួយថ្ងៃផង ដល់ម៉ោងគេហៅទៅជួបជុំរៀបការនៅកន្លែងរោងបាយជិតវត្តព្រះធាតុហ្នឹង។ រៀបការហ្នឹង លោកដែលធ្លាប់មានទំនាក់ទំនងស្នេហ៍ ពាក្យស្នេហ៍សម័យខ្មែរក្រហម ពាក្យដណ្តឹងចុះ ប្រើសម័យនេះ ជាមួយនឹងនារី សុផាត ហ្នឹងដែរទេ? ហើយតើមានការពេញចិត្តដែរទេ? ខ្ញុំអត់មានពេញចិត្តទេលោកមេធាវី ពីព្រោះខ្ញុំអត់មានកម្លាំងពលំអី ដើម្បីហៅថាស្រឡាញ់នារីកែទទេ គឺពេលនោះគេឲ្យធ្វើការងារហួសកម្លាំង វាគ្មានអារម្មណ៍អីចង់បានប្រពន្ធ ហើយក៏ស្រឡាញ់រៀបការតាមផែនការរបស់គេ។ ប៉ុន្តែជាល្បិចកលរបស់គេគឺគេចំណោទខ្ញុំថា ចោទថាជាជនបម្រុងគេដាក់គុកហើយ ក៏ខ្ញុំមិនហ៊ានប្រកែកជាមួយគេទាំងអស់។ គេឲ្យធ្វើអី ខ្ញុំធ្វើហ្នឹងទាំងអស់ លោកប្រធាន។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:៣២:៥៣]

ក្រោយមកនៅរសៀលនោះ លោក ម៉ី សារឿន បានរៀបរាប់ពីវិធីដែលបានកើតឡើងនៅក្រោយរៀបការដូចមាននៅក្នុងវីដេអូឃ្លីបបន្តទៅនេះ។ បាទ សូមបញ្ចាំងវីដេអូឃ្លីបលេខ១៥៖

[១៥:៣៣:១១]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"(ភាសាបារាំង)។ សុំមានយោបល់ ពេលនោះគឺឲ្យតែចាប់ផ្តើមមេកងធំ និងមេកងចល័ត មេកងតូចហ្នឹងគឺគេរៀបចំហើយ គឺគេដាក់ភ្នាក់ងារល្អបហ្នឹងគឺតាមដាន ៗគ្រប់គូទាំងអស់ គឺគេមានឈ្មោះនៅក្នុងបញ្ជីរបស់គេ គឺបែកចែកកម្លាំងចុះ។ បើយើងមិនរស់នៅជាមួយគ្នាទេ គេនឹងមាន នឹងមានផែនការ ល្បិចកលយ៉ាងម៉េចទេ ខ្ញុំមិនបានប្រឆាំងដែរ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:៣៤:១២]

ចុងបញ្ចប់ដោយការប្រឆាំងទៅនឹងទម្ងន់នៃភស្តុតាង លោក នួន ជា អះអាងថា កងល្អបដែលតាមដានមើលអ្នកដែលរៀបការថ្មីគឺដើម្បីមើលឲ្យដឹងថា បើពួកគាត់មិនបានរួមភេទជាមួយគ្នានោះ វាប្រឆាំងនឹងបទដ្ឋានវប្បធម៌ទាក់ទងនឹងផ្លូវភេទ។ វាគឺជាការគ្រប់គ្រាន់ហើយ ក្នុងការកត់សម្គាល់ថា ការរំលោភលើបទដ្ឋានវប្បធម៌ គឺជាបទដ្ឋានសម្រាប់បក្សកុម្មុយនីស្តកម្ពុជា។ តួយ៉ាងវាក៏ជាការរំលោភលើបទដ្ឋានវប្បធម៌ក្នុងការដែលសម្រាតស្បង់ចីវរព្រះសង្ឃ ហើយបង្ខំឲ្យលោករៀបការ និងធ្វើការ។ តែទោះជាយ៉ាងណាក៏ដោយ រឿងនោះមិនបានបញ្ឈប់បក្សកុម្មុយនីស្តកម្ពុជានោះទេ។ តាមពិត នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ទាំងមូលនេះ ត្រូវបានស្ថាបនាឡើងដោយបក្សកុម្មុយនីស្តកម្ពុជាដើម្បីរំលោភលើបទដ្ឋានវប្បធម៌។

លោកប្រធាន លោក លោកស្រីចៅក្រម ភស្តុតាងដែលមាននៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ គឺមានយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលជាស្ថានទម្ងន់។ មានទាំងការឈឺចាប់ និងដែលមិនអាចប្រកែកបាន។ វាជាការមិនត្រឹមត្រូវទេ ដែលមេធាវីការពារក្តីលើកអំណះអំណាងនៅក្នុងសារណារបស់ពួកគាត់។ ដូច្នេះ យើងសូមស្នើឲ្យលោកប្រធាន លោក លោកស្រីចៅក្រមទាំងអស់ សម្រេចថា លោក នួន ជា និងលោក ខៀវ សំផន មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀតដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើរំលោភសេពសន្ថវៈ នៅក្នុងអាពាហ៍ពិពាហ៍ទាំងនោះ។

ជាបន្តទៅទៀតនេះ ខ្ញុំសូមឲ្យសហការីរបស់ខ្ញុំគឺលោក ឌេល លីសាក់ ដើម្បីលើកឡើងបន្តទៀតអំពីមន្ទីរសន្តិសុខ។ បាទ សូមអរគុណលោកប្រធាន។

[១៥:៣៦:២៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបាទ!

**លោក ឌេល លីសាក់៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ភាគីទាំងអស់។ កម្មវត្ថុដែលខ្ញុំនឹងពិភាក្សានៅរសៀលនេះ ហើយនិងបន្តទៅដល់ព្រឹកស្អែក គឺនិយាយអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខ ឬក៏មន្ទីរអប់រំកែប្រែទាំងបួន។ ទី១ គឺគុកស្រុកត្រាំកក់ដែលគេហៅថា ក្រាំងតាចាន់។ ទី២ គឺគុកកងទ័ព កងពល៨០១ នៅរតនគិរីដែលគេហៅថា អូរកន្សែង និងមន្ទីរសន្តិសុខតំបន់ ១០៥ នៅក្នុងខេត្តមណ្ឌលគិរី ហើយនិងដែលគេហៅថា ភ្នំក្រោល និងមួយទៀតគឺ គុក ស-២១ នៅភ្នំពេញ។ នេះគឺជាមន្ទីរសន្តិសុខបួនក្នុងចំណោម មន្ទីរសន្តិសុខ១៩៦ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញនៅក្នុងគម្រោងកំណត់ផែនទីរបស់ពួកគេ ដែលនិយាយថា ជាគុកដែលមានដំណើរការ មានប្រតិបត្តិការនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំសូមបង្ហាញនូវ*ស្លាយ*ទី១ ផែនទីនេះ បង្ហាញអំពីទីតាំងរបស់គុក និងទីតាំងសម្លាប់មនុស្សនៅទូទាំងប្រទេសនេះ។ មនុស្សរាប់សែននាក់ត្រូវបានគេសម្លាប់នៅទីនេះ។ ការសម្លាប់ដែលបណ្តាលឲ្យមានស្លាកស្នាមរហូតមកដល់ពេលនេះ ហើយដែលធ្វើឲ្យប្រជាជនកម្ពុជានៅតែទទួលរងផលប៉ះពាល់រហូតមកដល់ពេលនេះ។ ប៉ុន្តែ<ប៉ុន្មានខែកន្លងមក>អ្វីដែលខ្ញុំចាប់អារម្មណ៍ជាងគេ គឺ<ជាផ្នែកសំខាន់ដែលត្រូវលើកឡើង>នៅក្នុងពេលនេះដែរ។ នៅក្នុងខែមេសា អង្គការលើកលែងទោសអន្តរជាតិ បានចេញរបាយការណ៍ប្រចាំឆ្នាំ អំពីចំនួនសរុបនៃការសម្លាប់នៅទូទាំងប្រទេស កាលពីឆ្នាំទៅ។ ហើយនៅក្នុងឆ្នាំ២០១៦ ដោយមិនរាប់បញ្ចូលប្រទេសចិន ព្រោះថា មិនមានទិន្នន័យដែលអាចជឿជាក់បាន គឺមានការសម្លាប់មនុស្សនៅទូទាំងពិភពលោក ចំនួន១.០៣២នាក់ <ចេញដោយអង្គការលើកលែងទោសអន្តរជាតិ>។ ចំនួននៃការសម្លាប់មនុស្សច្រើនជាងគេបំផុតគឺមកពីប្រទេសអ៊ីរ៉ង់ ដែលធ្វើការសម្លាប់មនុស្ស៥៦៧នាក់។ បន្ទាប់មកទៀតគឺ អារ៉ាប់ប៊ីសាអូឌីត មានការសម្លាប់មនុស្ស១៥៤នាក់។ <អ្នកដែលគាំទ្រសិទ្ធិមនុស្សអន្តរជាតិ>មានការព្រួយបារម្ភ<ចំពោះចំនួនសម្លាប់នេះ>។ ចំពោះខ្ញុំវិញ <វា>ជាការរំឭក<មួយអំពី>ឧក្រិដ្ឋកម្ម<ដ៏មហិមា>ដែលយើងកំពុងតែធ្វើការជំនុំជម្រះ<ផងដែរ>។

[១៥:៣៩:៥២]

ក្នុងរយៈពេល១ខែគឺនៅក្នុងខែឧសភា ឆ្នាំ១៩៧៨ <យ៉ាង>ហោចណាស់ក៏មាន<អ្នកទោសចំនួន១.០៧៤>នាក់ ត្រូវបានសម្លាប់នៅ ស-២១ គឺច្រើនជាងចំនួនមនុស្ស ដែលគេសម្លាប់នៅទូទាំងពិភពលោកក្នុងឆ្នាំ២០១៦ម្ល៉េះ។ ហើយមានការសម្លាប់មួយ ដែលកើតឡើងនៅក្នុងថ្ងៃទី២៧ ឧសភា គឺមាន

ចំនួន៥៨២នាក់ គឺច្រើនជាងចំនួនសម្លាប់មនុស្សប្រចាំឆ្នាំនៅក្នុងប្រទេស ដែលសម្លាប់ច្រើនជាងគេតាមរបាយការណ៍អង្គការលើកលែងអន្តរជាតិទៅទៀត <គឺសម្លាប់ក្នុងរយៈពេលមួយថ្ងៃ នៅក្នុងគុកមួយ>។ តួលេខនៃការសម្លាប់នៅមន្ទីរស-២១ ដែលជាតួលេខតំណាងតែមន្ទីរសន្តិសុខមួយក្នុងចំណោមមន្ទីរសន្តិសុខជិត២០០នាក់ ដែលមានដំណើរការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទំហំនៃការសម្លាប់គឺ<មានភាពព្រៃផ្សៃខ្លាំងណាស់ដែលយើង>មិនអាចធ្វើឲ្យយើងនឹកស្រមៃដល់បាន<>។ អ្នកណាម្នាក់ក៏និយាយដែរថា ការជំនុំជម្រះមេខ្មែរក្រហម គឺជា<ជ័យជម្នះ>យុត្តិធម៌ <ឬក៏ជាការបដិសេធដាច់ខាតចំពោះភាពព្រងើយកន្តើយចំពោះតថភាពនៃ>ទំហំអំពើសាហាវព្រៃផ្សៃ ដែលបានកើតឡើង<នៅក្នុងប្រទេសនេះ>។

<កាលនោះ> មិនមានការជំនុំជម្រះនោះទេ នៅពេលដែលអ្នកទោសស-២១ ត្រូវបានគេបណ្ដើរយកទៅកន្លែងកប់សពរួមនៅជើងឯង<>ក្នុងខែឧសភា <ឆ្នាំ១៩៧៨> ហើយត្រូវបានគេវ៉ៃសម្លាប់នៅលើក្បាល <និងអារក>។ មិនការជំនុំជម្រះ មិនមានការប្ដឹងសាទុក្ខ មិនមានមេធាវី មិនមានច្បាប់នោះទេ។ ជនរងគ្រោះជាច្រើន<ក្នុងខែនោះគឺជាប្រជាជន>មកពីភូមិភាគបូព៌ា ត្រូវបាននាំមកស-២១ ហើយ<ចុះបញ្ជី-->ពួកគេត្រូវបាន -- បន្ទាប់មកទៀតត្រូវបានបញ្ជូនតាមឡានយកទៅជើងឯង<ដើម្បីសម្លាប់>។ <ដូចដែលយើបានដឹងពីឈ្មោះ ឌុច ហើយថា>ទាំងអស់នេះត្រូវបានធ្វើឡើងតាមការបញ្ជារបស់មនុស្សតែម្នាក់ ដែលកំពុងតែនៅក្នុងការជំនុំជម្រះ ហើយក៏ដូចជានៅក្នុងសាលសវនាការថ្ងៃនេះដែរគឺ នួន ជា គឺជាបងធំទី២ ជាអតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។

ឥឡូវនេះខ្ញុំសូមបង្ហាញផងដែរនូវរូបថតនៃជនរងគ្រោះជាង១.០០០នាក់ ដែលត្រូវបានគេសម្លាប់នៅក្នុង<រយៈពេលតែមួយខែនោះ>នៅក្នុងគុកនេះ។ នេះគឺ ដឹក សាបាន <ជានារី>អាយុ២៤ឆ្នាំ ដែលជាប្រធានកងចល័តនៅឃុំឈើទាល ស្រុកស្វាយរៀង។ គាត់ត្រូវបានគេបញ្ជូនទៅស-២១ នៅថ្ងៃ១៧ ឧសភា ឆ្នាំ១៩៧៨ ហើយត្រូវបានសម្លាប់នៅថ្ងៃដដែលនោះ។

[១៥:៤២:៥៣]

កួវ វណ្ណា គឺអាយុ២៥ឆ្នាំជាស្មៀនមកពីមន្ទីរស្រុករមាសហែក។ គាត់ត្រូវបានគេសម្លាប់នៅថ្ងៃទី០៥ ខែឧសភា។ ជា សាន គឺជាអតីតទូតរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំសហភាពសូវៀត ហើយគាត់ជាអ្នកទោសមួយក្នុងចំណោមអ្នកទោស៥៨០នាក់ ដែលត្រូវបានគេសម្លាប់នៅថ្ងៃ២៧ ឧសភា ៧៨។ ហើយរូបថតនេះ គឺជារូបរបស់ រិន ធីង៉ុក ជាក្មេងស្រីអាយុ១៣ឆ្នាំ ជនជាតិវៀតណាមមកពីស្វាយរៀង

ដែលគាត់ចូលស-២១ នៅថ្ងៃ០៦ ឧសភា ៧៨ ហើយគាត់ត្រូវបានគេសម្លាប់១សប្តាហ៍ក្រោយ គឺនៅថ្ងៃ ១៤ ឧសភា។ ប្អូនប្រុសរបស់គាត់អាយុ៨ឆ្នាំ ហើយនិងឪពុករបស់គាត់ត្រូវបានគេសម្លាប់នៅពេលក្រោយ <គឺក្នុងខែជាមួយគ្នាហ្នឹង ក្នុងអំឡុងពេល>សម្លាប់រួមនៅថ្ងៃ២៧ ខែឧសភា។

ទោះបីថា ខ្ញុំនិយាយតែអំពីមន្ទីរសន្តិសុខចំនួនបួនរបស់កម្ពុជាប្រជាធិបតេយ្យនៅ<ក្នុងសំណុំរឿងរបស់យើងក្នុង>ថ្ងៃនេះក៏ដោយ ប៉ុន្តែយើងមិនត្រូវយល់ច្រឡំទេថា <>ហេតុ<ការណ៍>ដូចគ្នាហ្នឹងវា<ក៏>កើតឡើងនៅទូទាំង នៅគ្រប់កន្លែងនៅទូទាំងប្រទេស នៅគ្រប់ភូមិភាគ នៅគ្រប់កងពល នៅគ្រប់ក្រសួង គឺធ្វើឡើងស្របទៅតាមមាគ៌ាបក្ស ឬក៏គោលនយោបាយរបស់បក្ស ដែល<បានបង្កើតហើយ>ដឹកនាំមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅក្នុងទីក្រុងភ្នំពេញ។

[១៥:៤៤:៤០]

ឯកសារមួយនេះគឺ E3/1094 គឺជារបាយការណ៍ប្រចាំខែរបស់<>ភូមិភាគបស្ចិមផ្ញើជូនអង្គការ ខែកក្កដា ឆ្នាំ៧៨ គឺជាឯកសារដែលមាន១៤ទំព័រ ហើយមាននូវរបាយការណ៍លម្អិតខ្លាំងសម្រាប់ឱ្យមេដឹកនាំមជ្ឈិមបក្ស ស្តីពីខ្មាំងដែលត្រូវចាប់ខ្លួន ឃុំខ្លួន សួរចម្លើយ និងត្រូវបានកម្ទេចនៅក្នុងតំបន់ និងស្រុកនីមួយៗរបស់ភូមិភាគនោះ។ នៅទំព័រទី១ គឺផ្នែកមួយដែលមានចំណងជើងថា "សកម្មភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង"។ ហើយផ្នែកនេះ គឺសរសេរអស់ប្រហែលជាពាក់កណ្តាលនៃរបាយការណ៍ទាំងមូលតែម្តង។ គឺថាចាប់ផ្តើមឡើងដោយនិយាយយោងទៅលើ "សមាសធាតុរបស់១៧មេសា រួមមានអ្នករដ្ឋការ និងពួកយួន និងពួកចិន"។ ហើយបន្ទាប់មកទៀត បានបញ្ជាក់ច្បាស់អំពីគោលនយោបាយបក្ស<យ៉ាងច្បាស់>ដែលភូមិភាគត្រូវទទួលបានឱ្យអនុវត្តទាក់ទងចំពោះខ្មាំងទាំងអស់នេះ។ ហើយខ្ញុំសូមដកស្រង់៖ "យើងមានផែនការដែលត្រូវអនុវត្ត ដើម្បីអនុវត្តមាគ៌ាបក្ស<ជាប្រចាំ> ដើម្បីដកចេញ ត្រួតពិនិត្យ ហើយនិងបោសសម្អាតពួក<វា>។"

[១៥:៤៦:២៤]

ហើយបន្ទាប់មកទៀត គឺថានៅក្នុងរបាយការណ៍នេះដដែល គឺមានទំព័រសរសេរជាច្រើនអំពីមនុស្សដែលគេចាត់ទុកថា បានចូលរួមក្នុងសកម្មភាពខ្មាំង។ របាយការណ៍ទាំងនេះ <ក៏មានសរសេរ> អ្នកដែលរិះគន់គោលនយោបាយរៀបការរបស់បក្ស រួមមានដូចជា អ្នកធ្វើការនៅរោងចក្ររបស់ភូមិភាគដែលប្រាប់ស្ត្រីម្នាក់ថា "ប្រសិនបើអ្នកឯងស្រឡាញ់ម៉ែឪ កុំរៀបការជាមួយនឹងកម្មាភិបាល។" ហើយក៏មាននារីម្នាក់ដែលបារម្ភថា នៅពេលអនាគតអង្គការនឹងរៀបចំឱ្យបុរសម្នាក់រៀបការជាមួយស្ត្រី

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រាំនាក់។ របាយការណ៍នេះ ក៏បាននិយាយអំពីមនុស្សដែលប៉ាននតវ៉ាអំពីការដែលពួកគាត់ធ្វើការធ្ងន់ធ្ងរពេក ឬក៏មិនមានអ្វីហូបគ្រប់គ្រាន់ ឬក៏ថាអង្គការបំបែកពួកគាត់ចេញពីគ្រួសារ ឬក៏បំបែកពួកគាត់ចេញពីកូនចៅជាដើមនោះ។<>វាយការណ៍<នេះក៏សរសេរ>អំពីបុរសម្នាក់ដែលគេបញ្ជូនទៅមន្ទីររៀនសូត្រ ព្រោះថាគាត់ -- ព្រោះគេរកឃើញថាគាត់មានសញ្ជាតិបារាំង ហើយក្នុងរបបមុនហ្នឹង គាត់គឺជាអ្នកតន្ត្រីដែលច្រៀង ហើយនិងសរសេរបទភ្លេងឱ្យជនបរទេស។ គឺថាវាមានរបាយការណ៍ជាច្រើន ដែល<បានឃើញ> មានមនុស្សជាច្រើនដែលគេកំណត់ថាជាទាហានរបស់របបមុនជាដើមនោះ។

ហើយនៅក្នុងផ្នែកដែល<លោក លោកស្រីចៅក្រមបានស្តាប់ហើយនោះ គឺជាចំណុច>សំខាន់<ខ្លាំងណាស់ ពេលយើងអានរបាយការណ៍ពីតំបន់៣៧ ក្នុងភូមិភាគបស្ចិម។> ខ្ញុំសូមដកស្រង់៖ “កម្ទេចជនជាតិយួន១០០នាក់ រួមមានទាំងចាស់ ធំតូច ក្មេងចាស់។ កម្ទេចមនុស្ស៦០នាក់ ដែលជាក្រុមអ្នកមានឋានន្តរស័ក្តិ ក៏ដូចជាពួក សេ.អ៊ី.អា ចក្រពត្តិអាមេរិកដែលបង្កប់ខ្លួននៅក្នុងសហករណ៍ និងនៅក្នុងអង្គការ។” ហើយបន្ទាប់មកទៀតនិយាយអំពីសមាសធាតុដែលខ្ជិលច្រអូសប្រឆាំងអង្គការ ជេរប្រមាថប្រជាជន ហើយត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពជាច្រើន ថាជាខ្មាំង ហើយនិងអ្នកដែលមិនព្រមធ្វើការ។

[១៥:៤៨:៥៨]

ហើយបន្ទាប់មកទៀត រៀបរាប់អំពីវិធានការដែលភូមិភាគគ្រោងនឹងធ្វើ ចំពោះសកម្មខ្មាំងទាំងអស់នេះ ហើយខ្ញុំសូមដកស្រង់បន្ត៖ “បន្តស្វែងរកគ្រប់បណ្តាញរបស់ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ហើយបោសសម្អាតជាបន្តបន្ទាប់ និងដាច់ខាតចេញពីមូលដ្ឋាន អង្គភាព មន្ទីរ ហើយនិងផ្នែកជាច្រើនផ្សេងៗគ្នា។”

លោក លោកស្រីចៅក្រម ចំណុចសំខាន់មួយទៀត អំពីពេលវេលារបស់របាយការណ៍នេះ គឺថារបាយការណ៍នេះត្រូវបានគេបញ្ជូននៅ<ដើមខែសីហា> ឆ្នាំ៧៨ គឺប្រហែលជា៤ខែ ក្រោយពេលមជ្ឈិមបានបោសសម្អាត ហើយបញ្ជូនទៅស-២១ នូវអតីតលេខាភូមិភាគបស្ចិមគឺ ជូ ជេត ។ ហើយនៅក្នុងរបាយការណ៍នេះ គឺមកពីមេដឹកនាំថ្មីដែល<ថ្នាក់ដឹកនាំ> ប៉ុល ពត, នួន ជា និង ខៀវ សំផន <និងអ្នកផ្សេងទៀត ទុកចិត្ត> ហើយឱ្យគ្រប់គ្រងទៅលើភូមិភាគ និងអនុវត្តគោលនយោបាយរបស់មជ្ឈិម។ ហើយនេះគ្រាន់តែជារបាយការណ៍មួយប៉ុណ្ណោះ <ចេញ>ពីភូមិភាគមួយ<សម្រាប់>រយៈពេលមួយខែ។ នៅក្នុង ប្រសិនបើយើងគិតទៅ គឺរបបនោះមានរយៈពេលទៅដល់ជាង៣ឆ្នាំកន្លះ។ ជនជាប់ចោទគឺ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានដឹងច្បាស់អំពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេសនេះ។ ព្រះរាជអាជ្ញាជាតិបាននិយាយអំពីបញ្ហានេះរួចហើយ។ ហើយនៅថ្ងៃនេះ គឺព្រះរាជអាជ្ញាជាតិក៏បានលើកផងដែរ អំពីឯកសារសំខាន់គឺរបាយការណ៍គណៈមជ្ឈិម ថ្ងៃ០៨ មីនា។ ហើយចំណុចសំខាន់នៃរបាយការណ៍ថ្ងៃ០៨ មីនា ៧៦ នេះគឺថាកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ហ្នឹង <មានលេខឯកសារ E3/232។ អ្វីដែលសំខាន់នោះ យើងដឹងថា> មិនមែន<>ចូលរួមត្រឹមតែ នួន ជា <តែប៉ុណ្ណោះទេ តែលោក>ខៀវ សំផន <ក៏ចូលរួម>ផងដែរ ហើយគាត់បានទទួលស្គាល់អំពីចំណុចនេះជាមួយនឹង<ការិយាល័យសហចៅក្រមស៊ើបអង្កេតផងដែរ>។ វត្តមានរបស់ពួកគាត់ត្រូវបានបង្ហាញនៅក្នុង<កំណត់ត្រា>កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ផងដែរ។

[១៥:៥១:៣២]

ដូច្នេះមិនមានអ្វីគួរឲ្យសង្ស័យទៀតនោះទេ ដែលថាជនជាប់ចោទទាំងពីរហ្នឹងបានចូលរួមនៅក្នុងកិច្ចប្រជុំមួយដែលពួកគេបានទទួលរបាយការណ៍មកពីមេដឹកនាំភូមិភាគតំបន់ អំពីស្ថានភាពខ្មាំងនៅក្នុង<ទឹកដី>របស់ពួកគេ។ ចំណុចទាំងអស់នេះត្រូវបានបញ្ជាក់ច្បាស់នៅក្នុងកំណត់ហេតុកិច្ចប្រជុំ នៅពេលដែលមេដឹកនាំភូមិភាគ <និង>តំបន់មកប្រជុំនៅទីក្រុងភ្នំពេញ។ ហើយពួកគេបានរាយការណ៍អំពីខ្មាំង ដែលត្រូវបានចាប់ខ្លួន។ <>ពួកគេស្នើសុំការណែនាំពីអង្គការ ហើយអង្គការបានផ្តល់ការណែនាំដែលតម្រូវឲ្យធ្វើការសួរចម្លើយបន្ថែមទៀត ហើយរាយការណ៍<>អំពីចម្លើយហ្នឹងទៅថ្នាក់លើ។ មិនមានអ្វីគួរឲ្យសង្ស័យទៀតនោះទេ <លោកចៅក្រមជាទីគោរព> ដែលថាជនជាប់ចោទគឺពួកគាត់ទាំងពីរនាក់ហ្នឹងបានដឹង ហើយបានចូលរួមនៅក្នុងហេតុការណ៍ទាំងអស់នេះ។

វាជារឿងល្អមួយដែរ ដែលថារបាយការណ៍ទាំងអស់នេះ ក៏ដូចជាសារទូរលេខមួយចំនួន<មាន>នៅសល់<>ទោះបីថា ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាព្យាយាមបំផ្លាញឯកសារទាំងអស់នេះ<បិទបាំងឧក្រិដ្ឋកម្មរបស់ខ្លួន>។ ឯកសារទាំងអស់នេះ គឺបានច្រានចោលនូវការអះអាងរបស់ជនជាប់ចោទ ដែលថាពួកគេមិនបានដឹង<ថាមានអ្វីកើតឡើងនោះ។ តាមពិត> ពួកគេបានដឹង ហើយគេដឹងយ៉ាងច្បាស់ថែមទៀតផង។ ដូច្នេះ រាល់ការលើកឡើងដែលថាភូមិភាគ<ធ្វើ>ប្រតិបត្តិការដោយស្វយ័តដោយស្វ័យភាព<ផ្ទុយពីឆន្ទៈរបស់មជ្ឈិម >គឺមិនអាច<>ឡើយ។ គឺយើងឃើញនៅក្នុងសារទូរលេខដែលបានរាយការណ៍យ៉ាងច្រើន ដែលផ្ញើពីភូមិភាគទៅមជ្ឈិម។ ហើយជាទូទៅរបាយការណ៍នេះគឺផ្ញើឡើងសឹងតែរៀងរាល់ថ្ងៃទៀតផង។ ប្រសិនបើយើងចង់ដឹងការពិតអំពីរបបនេះ យើងអាចពិនិត្យមើលទៅលើឯកសារទាំងអស់នេះបាន គឺថាឯកសារនេះអាចប្រាប់យើងបាន។ យើង<ក៏មានសំណាង>មួយ

ផងដែរ ដែលថាក្នុងចំណោមមន្ទីរសន្តិសុខ១៩៦ ដែលដំណើរការនៅក្នុងរបបខ្មែរក្រហមនោះគឺមានមន្ទីរសន្តិសុខចំនួនពីរ ដែលមិនបានកម្ទេចឯកសារកំណត់ត្រាមុនពេលដែលកងទ័ពវៀតណាមចូលមកដល់។

[១៥:៥៤:០៦]

នៅក្នុងនោះគឺស-២១ ហើយនិងមន្ទីរសន្តិសុខក្រាំងតាចាន់។ វាជាផ្នែកសំខាន់មួយ ព្រោះថាដោយសារតែកំណត់ត្រាទាំងអស់ដែលនៅសល់នោះ<ហើយ ទើប>វាមានការបង្ហាញ<ដោយមិនបាច់ប្រកែក>អំពីឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងគុកទាំងអស់នោះទេ។ ហើយម្យ៉ាងទៀត គឺយើងមានភស្តុតាងសំខាន់ៗ <ដែលស៊ីគ្នានឹង>ព័ត៌មាន<ទាំងឡាយ>របស់អ្នកដែល<នៅ>រស់រានមានជីវិតពីគុកទាំងអស់នោះបាននិយាយ។

តាមពិតទៅក្រុមមេធាវីការពារក្តីមួយក្រុម គឺក្រុម ខៀវ សំផន បានយល់ស្របនៅក្នុងសារណារបស់ពួកគាត់ថា ភស្តុតាងមកពីមន្ទីរសន្តិសុខស-២១ បានបង្ហាញពីការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌នានា ដូចជាការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញ ដែលផ្អែកលើមូលដ្ឋាននយោបាយជាដើម។

នៅក្នុងសារណារបស់ខ្ញុំថ្ងៃនេះ ហើយនិងបន្តរហូតដល់ទៅដល់ថ្ងៃស្អែកនោះ ខ្ញុំនឹងនិយាយអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលខ្ញុំជឿជាក់ថា ពាក់ព័ន្ធសំខាន់បំផុតជាមួយនឹងមន្ទីរសន្តិសុខ។ <នោះ>គឺជាឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌នានាទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ការធ្វើទារុណកម្ម ហើយចុងក្រោយគឺអំពើមនុស្សឃាត និងការសម្លាប់រង្គាល។ ហើយខ្ញុំនឹងនិយាយអំពីភស្តុតាងមកពីមន្ទីរសន្តិសុខទាំងអស់នេះ ដែលជាភស្តុតាងដែលបង្ហាញយ៉ាងច្បាស់លាស់អំពីឧក្រិដ្ឋកម្មទាំងអស់នេះ។ ហើយខ្ញុំសូមលើកឡើងនូវសារណាមួយចំនួនអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងពីរចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ។

ឥឡូវនេះ ខ្ញុំសូមចាប់ផ្តើមនិយាយអំពីឧក្រិដ្ឋកម្មនៃការដាក់<>ឃុំ<ខ្លួន>។ លោក លោកស្រីចៅក្រម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំងគឺមានន័យថា ជាការដកហូតនូវសេរីភាពរបស់បុគ្គលម្នាក់ដោយតាមអំពើចិត្ត ដោយមិនមានមូលដ្ឋានផ្លូវច្បាប់ដែលអាចធ្វើយុត្តិកម្មបាន ឬក៏មិនមានដំណើរការយុត្តិធម៌ដ៏សមស្របមួយ។ មានការជំទាស់ខ្លះផ្អែកទៅលើភស្តុតាងដែលថាជនរងគ្រោះរាប់ពាន់នាក់ត្រូវបានដកហូតនូវសេរីភាពរបស់ពួកគេ ហើយត្រូវបានឃុំដោយបង្ខំនៅក្រាំងតាចាន់ ភ្នំក្រោល អូរកន្សែង និងស-២១។ ក្នុងចំណោមសាក្សីរាប់រយនាក់ដែលយើងបានស្តាប់ មិនមានសាក្សី

សូម្បីមួយរូបអះអាងថាមានតុលាការ មានចៅក្រម មានស្ថាប័ន<យុត្តិធម៌> ឬក៏មានច្បាប់ព្រហ្មទណ្ឌ ឬក៏នីតិវិធីព្រហ្មទណ្ឌនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ សូម្បីតែអតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដែលស្មោះត្រង់បំផុត ក៏មិនបានអះអាង<ថាមានស្ថាប័ន>បែបនេះដែរ គឺមេដឹកនាំបក្ស ហើយមានតែមេដឹកនាំបក្សតែម្នាក់ប៉ុណ្ណោះដែលសម្រេចថាតើអ្នកណាត្រូវចាប់ខ្លួន ត្រូវបញ្ជូនទៅមន្ទីរសន្តិសុខ និងត្រូវកម្ទេចនោះ។

[១៥:៥៧:៣៦]

អ្វីៗដែលបានកើតឡើង គឺប្រាកដណាស់ជាការធ្វើឡើងតាមអំពើចិត្ត និងការដាក់ក្នុងមន្ទីរឃុំឃាំង និងសម្លាប់ក្រៅផ្លូវតុលាការ។ បន្ថែមពីលើសាក្សីដែលបានមកផ្ដល់សក្ខីកម្មថាមិនមានតុលាការថែមទៀតនោះ គឺថាជនរងគ្រោះដែលត្រូវបានគេចាប់ខ្លួន និងឃុំខ្លួនគឺមិនមានឱកាសក្នុងការការពារខ្លួនពួកគេឡើយ។ ហើយជាទូទៅ ពួកគេមិនបានទទួលសូម្បីតែមូលហេតុដែលគេចាប់ខ្លួននោះ<ផង>។ ហើយក៏មានឯកសារនៅសេសសល់ដែលបង្ហាញ<ពីតថភាពចំនួន>ជនរងគ្រោះ<>ត្រូវបានគេចាត់ទុកថាជាខ្មាំង<។> ហើយពួកគេត្រូវបានដកហូតនូវសេរីភាព <ហើយជាច្រើនករណី រួមទាំងជីវិតរបស់ពួកគេផងដែរ>។

នៅអូរកន្សែង គឺយើងបានស្ដាប់ព្ញត៌មានពីអ្នកដែលនៅរស់រានមានជីវិតពីរនាក់គឺ ផាន់ ថុល ហើយនិង មឿង ចាន់ឌី។ <ពួក>គេគឺជាអ្នកធ្វើការនៅចម្ការកៅស៊ូភូមិភាគពាយ័ព្យ ហើយនៅក្នុងពាក់កណ្ដាលខែមិថុនា ៧៧ ពួកគាត់ត្រូវបានគេចាប់ខ្លួនជាមួយនឹងពលករ១០នាក់ទៀតមកពីសហជីពចម្ការកៅស៊ូ។ មឿង ចាន់ឌី នៅពេលនោះគាត់មានទម្ងន់។ ពួកគាត់មិនបានដឹងអំពីមូលហេតុនៃការចាប់ខ្លួននោះឡើយ គេគ្រាន់តែប្រាប់ថា ពួកគាត់ទៅរៀនជាមួយអង្គការប៉ុណ្ណោះ។ ហេតុអ្វីបានជាគេចាប់<ខ្លួន>កម្មករចម្ការកៅស៊ូ<ទាំង>នេះ? ឥឡូវនេះ ខ្ញុំសូមបង្ហាញនូវសារទូរលេខមួយដែលគេផ្ញើដោយលេខាភូមិភាគពាយ័ព្យឈ្មោះ រ៉ី ផ្ញើជូនទៅមេដឹកនាំបក្សនៅភ្នំពេញនៅថ្ងៃ១៥ មិថុនា ១៩៧៧ គឺនៅពេលដែលកម្មករទាំងអស់នេះត្រូវបានគេចាប់ខ្លួន។ នៅក្នុងសារទូរលេខនេះ លេខាភូមិភាគបានសរសេរថា ខ្ញុំសូមដកស្រង់៖ “សម្រេចថា សមមិត្ត ធី សម្រេចថា ត្រូវចាប់ពួកខ្មាំងបង្កប់នៅក្នុងចម្ការកៅស៊ូ និងនៅក្នុងចម្ការកប្បាស <ក៏ដូចជាក្នុងកងចល័តដែរ>។” <បើសិនណាយើងអានសារទូរលេខនេះ យើងដឹងថា>គោលដៅនៃការបោសសម្អាតនេះ គឺទាក់ទងទៅនឹងបណ្ដាញរបស់មនុស្សបួននាក់ដែលគេចាត់ទុកថាជា <>អា។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោក លោកស្រីចៅក្រម នេះមិនមែនជាយុត្តិកម្មស្របច្បាប់សម្រាប់ការចាប់ខ្លួន និងការឃុំខ្លួនមនុស្សដោយសារតែពួកគេជាបណ្តាញរបស់អ្នកណាម្នាក់ ឬក៏ដោយសារតែពួកគេធ្វើការឲ្យអ្នកណាម្នាក់ ឬក៏ពួកគេមានទំនាក់ទំនងជាមួយអ្នកណានោះឡើយ។ ដូច្នេះមិនអាចចោទប្រកាន់ពិរុទ្ធភាពដោយសារតែមានការទំនាក់ទំនងប៉ុណ្ណោះទេ។ ប៉ុន្តែ ផាន់ ចុល ហើយនិង មឿង ចាន់ឌី គ្រាន់តែជាមនុស្សពីរនាក់ក្នុងចំណោមជនរងគ្រោះរាប់ពាន់នាក់ ដែលត្រូវបានគេបោសសម្អាតនៅក្នុងគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាដែលស្វែងរកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងដែលគេធ្វើឡើងនៅក្នុងឆ្នាំ១៩៧៧ និង ១៩៧៨តែប៉ុណ្ណោះ។ ខ្ញុំគិតថា ប្រសិនលោកប្រធានអនុញ្ញាត ខ្ញុំសូមសម្រាកត្រឹមប៉ុណ្ណោះសិន។

[១៦:០១:០៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ នាពេលនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី ១៥ ខែមិថុនា ឆ្នាំ២០១៧ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង ០០២/០២ ដែលនឹងបន្តធ្វើឡើងសហព្រះរាជអាជ្ញា សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន៕

សម្រាកចុះ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*